សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ចៅក្រមស៊ើបសួរ

## (ក្នុងប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជា)

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **រ៉ែន សីហា**
**អុល សំអាង**

សាស្ត្រាចារ្យណែនាំ
**លោក ឡើក ពិដោរ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **២២**

ឆ្នាំចូលសិក្សា **២០១៨**
ឆ្នាំសរសេរសារណា **២០២២**

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងយើងខ្ញុំបាទទាំងពីឈ្មោះ **វ៉ន សីហា** និង **អុល សំអាខ** ជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី ២២ ក្នុងឆ្នាំសិក្សា ២០១៨-២០២២ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាស្ត្រសេដ្ឋកិច្ច សូមដឹងគុណ និងគោរពដល់អ្នកមានគុណទាំងអស់ដូចខាងក្រោម៖

សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាវជ្រៅចំពោះ **លោកឪពុក និង អ្នកម្តាយ** ជាទីគោរពដែលបានផ្តល់កំណើត ការចិញ្ចឹម ថែក្សា និង អប់រំ ទូន្មាន ដោយសេចក្តីស្រលាញ់ មេត្តា ដែលធ្វើឱ្យពួកយើងមានថ្ងៃនេះ ព្រម **ទាំងលោកតា លោកយាយ អ៊ុំ ពូ មីង បងប្អូនទាំងអស់** យើងខ្ញុំសូមគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុត។

សូមថ្លែងអំណរគុណដល់ **ថ្នាក់ដឹកនាំ ក្រសួង អប់រំ យុវជន និងកីឡា និង សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលមានគោលនយោបាយក្នុងការបណ្តុះបណ្តាលយុវជនប្រកបដោយគុណភាព។

សូមថ្លែងអំណរគុណដល់ **ឯកឧត្តមសកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ លោកសាស្ត្រាចារ្យ និង លោកស្រីសាស្ត្រាចារ្យ** នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់នូវចំណេះដឹង និងការអប់រំដល់យើងខ្ញុំ។

សូមថ្លែងអំណរគុណដល់ **គណៈគ្រប់គ្រងបណ្ណាល័យនីតិសាស្ត្រ** បានគ្រប់គ្រងឯកសារ រៀបចំឯកសារ សៀវភៅ ដើម្បីសម្រួលដល់ការសិក្សា ស្រាវជ្រាវរបស់និស្សិត។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងក្រៃលែងដល់ **លោកសាស្ត្រាចារ្យ ឡឿក ពិដោរ** ជាដែលសាស្ត្រាចារ្យដឹកនាំសរសេរសារណា ដោយបានចំណាយពេលវេលាដ៏មានតម្លៃ កម្លាំងកាយ ចិត្ត ដើម្បីផ្តល់នូវចំណេះដឹង គំនិត យោបល់ ការកែតម្រូវ បង្ហាត់បង្ហាញ ដល់យើងខ្ញុំរហូតដល់សរសេររួចជាស្ថាពរ។

យើងខ្ញុំសូមសម្តែងនូវការដឹងគុណដល់ អ្នកមានគុណទាំងអស់ឥតឧបមា និងសូមជូនពរឱ្យជួបនូវសេចក្តីសុខ សុភមង្គលក្នុងក្រុមគ្រួសារ សុខភាពល្អ និងបានសម្រេចគ្រប់បំណងប្រាថ្នា។

# អារម្ភកថា

សូមគោរពជម្រាបសួរដល់លោកគ្រូ អ្នកគ្រូ និស្សិតបរិញ្ញាបត្រ ជំនាន់ទី ២២ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងអ្នកដែលកំពុងអានជាទីគោរព និងជាទីរាប់អាន។ ឆ្លងតាមរយៈការសិក្សាកន្លងមកយើងខ្ញុំយល់ថានីតិវិធីព្រហ្មទណ្ឌពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការរស់នៅក្នុងសង្គម។ ជាទូទៅមនុស្សគ្រប់គ្នាមានទំនាក់ទំនងជាមួយគ្នាគ្រប់វិស័យ និង មានសកម្មភាពជាមួយគ្នា ជាហេតុធ្វើឱ្យមនុស្សតែងតែមានកំហុស និង អាចបង្ករឱ្យមានបទល្មើស។ សកម្មភាពដែលបង្ករជាបទល្មើសនេះហើយតម្រូវឱ្យមានការទទួលខុសត្រូវចំពោះទង្វើលរបស់ខ្លួន ប៉ុន្តែមុននឹងឈានដល់ការទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌតម្រូវឱ្យធ្វើតាមនីតិនៃច្បាប់ឱ្យបានត្រឹមត្រូវ ដើម្បីស្វែងរកការពិតជៀសវាងមានភាពស្រពិចស្រពិលដែលនាំឱ្យការសម្រេចដាក់ទោសទៅលើជនណាម្នាក់ មានភាពមិនប្រាកដច្បាស់លាស់ ឬ មិនគ្រប់ជ្រុងជ្រោយ។ ដូច្នេះហើយតាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិបែងចែកដំណាក់កាលនៃការវិនិច្ឆ័យទោសទៅលើបុគ្គលណាម្នាក់ ឬ ច្រើននាក់បានកំណត់ជា ៤ (បួន) ដំណាក់ ទី ១ (មួយ) ដំណាក់កាលនគរបាលយុត្តធម៌ ទី ២ (ពី) ដំណាក់កាលអយ្យការ ទី ៣ (បី) ដំណាក់កាលស៊ើបសួរ និង ទី ៤ (បួន) ដំណាក់កាលជំនុំជម្រះ។ ដំណាក់កាលទី ៣ (បី) គឺដំណាក់កាលស៊ើបសួរ មានលក្ខណៈសំខាន់ និង ពិសេសមួយដែលមិនអាចមើលរំលងបានទេនៅក្នុងការស្វែងរកការពិតមុននឹងឈានដល់ការសម្រេចក្តីរបស់ចៅក្រម ឬ តុលាការ។

អាស្រ័យហេតុខាងលើនេះហើយទើប យើងខ្ញុំបាទបានសម្រេចជ្រើសរើសយកប្រធានបទ ចៅក្រមស៊ើបសួរ (ក្នុងប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជា) នេះមកស្រាវជ្រាវ និង ចងក្រងជាឯកសារនេះឡើងដើម្បីពង្រឹងនូវ សមត្ថភាពយល់ដឹងបន្ថែម ក៏ដូចជាបន្សល់ទុកនូវឯកសារមួយដើម្បីជាប្រយោជន៍ដល់អ្នកអាន អ្នកសិក្សាស្រាវជ្រាវដទៃទៀត។ យើងខ្ញុំដឹងច្បាស់ថាឯកសារនេះមានចំណុចខ្វះខាតមិនដល់កម្រិតនៃគោលដៅច្បាប់ ឬ ស្មារតីច្បាប់ ដោយព្រោះការយល់ដឹងនៅមានកម្រិតរបស់យើងខ្ញុំ ហើយយើងខ្ញុំជានិស្សិតមិនទាន់ឆ្លងកាត់ការអនុវត្តជាក់ស្តែង ដូច្នេះកំហុសឆ្គង និង ការខ្វះចន្លោះជារឿងមួយដែលមិនអាចជៀសវាងបាន យើងខ្ញុះជានិស្សិតសូមទទួលយកនូវមតិរិះគន់ស្ថាបនាគ្រប់មជ្ឈដ្ឋានដើម្បីកែលម្អឱ្យកាន់តែប្រសើរ និង គ្រប់ជ្រុងជ្រោយ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់មតិរិះគន់ ស្ថាបនា និង ថ្លែងអំណរគុណដល់អ្នកអាន អ្នកសិក្សាទាំងអស់ដែលបានអានសារណាមួយនេះ ។

# មាតិកា

ទំព័រ


**សេចក្ដីផ្ដើម** ............ ១

**ជំពូក១ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ** ............ ៤

**ផ្នែកទី១ សញ្ញាណទូទៅ** ............ ៤

**១.១ ការចាត់តាំងដោយប្រធានសាលាដំបូង** ............ ៥

១.១.១ ការបែងចែកសំណុំរឿងដោយប្រធានតុលាការ ............ ៥

១.១.១ ការដកហូតសំណុំរឿង ............ ៥

**១.២ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ** ............ ៦

១.២.១ សមត្ថកិច្ចដែនដី ............ ៦

១.២.២ សមត្ថកិច្ចតាមសាច់រឿង ............ ៧

**១.៣ ការសម្ងាត់នៃការស៊ើបសួរ** ............ ៧

**ផ្នែកទី២ មូលហេតុដែលនាំឱ្យមានការបើកការស៊ើបសួរ** ............ ៨

**២.១ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ** ............ ៨

**២.២ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី** ............ ៩

**ជំពូក២ អំណាចរបស់ចៅក្រមស៊ើបសួរ** ............ ១២

**ផ្នែកទី១ អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ............ ១២

**១.១ នីតិវិធីនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ............ ១២

១.១.១ ការដាក់ឱ្យនៅក្រោមការពិនិត្យ ............ ១៣

ក បុគ្គលដែលអាចដាក់ឱ្យនៅក្រោមការពិនិត្យ ............ ១៣

ខ បែបបទនៃការដាក់ឱ្យនៅក្រោមការពិនិត្យ ............ ១៣

១.១.២ ការសួរចម្លើយជនត្រូវចោទ ............ ១៤

១.១.៣ ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ............ ១៥

១.១.៤ ការស្ដាប់ចម្លើយសាក្សី ............ ១៦

១.១.៥ ការសួរតទល់ ......................................................................................... ១៧
១.១.៦ ការឆែកឆេរ និង ការចាប់យកវត្ថុតាង ......................................................... ១៧
១.១.៧ កោសលវិច័យ .......................................................................................... ១៨
១.១.៨ ការស្តាប់ទូរស័ព្ទ ......................................................................................... ១៩
**១.២ ដីកាចាត់ឱ្យស៊ើបសួរជំនួស** ........................................................................ ២០
១.២.១ ការស៊ើបសួរជំនួសដោយចៅក្រម ................................................................ ២១
១.២.២ ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌ ............................................ ២១
**ផ្នែកទី២ អំណាចបង្ខំរបស់ចៅក្រមស៊ើបសួរ** ........................................................ ២៣
**២.១ វិធានការនិរន្តរាយ** ...................................................................................... ២៣
១.១.១ ដីកាបង្គាប់ឱ្យចូលខ្លួន ................................................................................ ២៤
១.១.២ ដីកាបង្គាប់ឱ្យនាំខ្លួន ................................................................................... ២៤
១.១.៣ ដីកាបង្គាប់ឱ្យចាប់ខ្លួន ................................................................................ ២៦
១.១.៣ ដីកាបង្គាប់ឱ្យឃុំខ្លួន ................................................................................... ២៨
**២.២ ការរក្សាជនត្រូវចោទឱ្យនៅក្រោមការចាត់ចែងរបស់តុលាការ** ............................... ២៨
២.២.១ ការឃុំខ្លួនបណ្តោះអាសន្ន ............................................................................ ២៩
ក លក្ខខ័ណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ................................................................ ២៩
ខ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ................................................................ ៣០
គ នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន .................................................................... ៣២
ឃ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន .................................................................. ៣២
ង ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ............................................................... ៣៤
២.២.២ ការត្រួតពិនិត្យតាមផ្លូវតុលាការ ...................................................................... ៣៦
ក ការគោរពកាតព្វកិច្ចរបស់ជនត្រូវចោទ ................................................................. ៣៧
ខ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ............................................................ ៣៨
គ ការគេចវេះពីកាតព្វកិច្ចរបស់ជនត្រូវចោទ ............................................................ ៣៩

**ផ្នែកទី៣ ការត្រួតពិនិត្យកិច្ចការរបស់មន្ត្រីស៊ើបសួរដោយសភាស៊ើបសួរ**.................. ៣៩
**៣.១ អំណាចរបស់សភាស៊ើបសួរ**................................................................................ ៣៩
**៣.២ អំណាចផ្ទាល់របស់ប្រធានសភាស៊ើបសួរ**.............................................................. ៤១
**៣.៣ បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ**................................................ ៤២
**៣.៤ ការប្តឹងសុំមោឃភាព** ............................................................................................ ៤៤
**ជំពូក៣ ការបិទការស៊ើបសួរ** ........................................................................................ ៤៧
**ផ្នែកទី១ កិច្ចដាបឋមនៃការបិទការស៊ើបសួរ**.............................................................. ៤៧
**១.១ ការជូនដំណឹងដល់ភាគី** ..................................................................................... ៤៧
**១.២ ការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម**................................................................ ៤៨
១.២.១ ការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយព្រះរាជអាជ្ញា ............................................ ៤៨
១.២.២ ការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយជនត្រូវចោទ............................................... ៤៨
១.២.៣ ការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយដើមបណ្តឹងរដ្ឋប្បវេណី .................................. ៤៩
**ផ្នែកទី២ ដីកាដំណោះស្រាយ** ....................................................................................... ៤៩
**២.១ ដីកាលើកលែងការចោទប្រកាន់**............................................................................ ៤៩
២.១.១ មូលហេតុនៃការលើកលែងការចោទប្រកាន់............................................................. ៥០
២.១.២ នីតិវិធីនៃការចេញដីកាលើកលែងការចោទប្រកាន់.................................................. ៥០
២.១.៣ អានុភាពនៃដីកាលើកលែងការចោទប្រកាន់............................................................ ៥០
**២.២ ដីកាបញ្ជូនទៅជំនុំជម្រះ** .................................................................................... ៥១
២.២.១ មូលហេតុដែលនាំឱ្យមានការចេញដីកាបញ្ជូនទៅជំនុំជម្រះ........................................ ៥១
២.២.២ នីតិវិធីក្នុងការចេញដីកាបញ្ជូនទៅជំនុំជម្រះ............................................................ ៥១
២.២.៣ អនុភាពនៃដីកាបញ្ជូនទៅជំនុំជម្រះ ........................................................................ ៥២
**សេចក្តីសន្និដ្ឋាន**.......................................................................................................... ៥៣
**អនុសាសន៍**................................................................................................................. ៥៥
**ឯកសារយោង**

# ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១ លំនាំបញ្ហា

មនុស្សគ្រប់រូបរស់នៅក្នុងសង្គមតែងមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ទំនាក់ទំនងជាសមក្មភាពដែលខ្វះពុំបានរបស់មនុស្សគ្រប់គ្នា ប៉ុន្តែនៅក្នុងទំនាក់ទំនងនេះទង្វើលខ្លះនៃទំនាក់ទំនងក៏បានបង្ករបានជាចលាចល ខូចសណ្តាប់ធ្នាប់ និង អសន្តិសុខសង្គមផងដែរ។ ដូច្នេះសង្គមចាំបាច់ត្រូវមានច្បាប់ដើម្បីគ្រប់គ្រងទំនាក់ទំនងនេះ ជៀសវាងនូវការកើតមានបទល្មើស និង រៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ ទំនៀមទំលាប់ល្អក្នុងសង្គម។ ក្នុងន័យនេះប្រទេសកម្ពុជាបានខិតខំបង្កើតនូវវិធានច្បាប់ និង វិធានការជាច្រើនដើម្បីថែរក្សា ការពារសុខសន្តិភាព សុវត្ថិភាព បង្ការ ការពារ ប្រឆាំងនូវបទល្មើសដែលកើតមាននៅក្នុងសង្គម ក៏ដូចជាការពារផលប្រយោជន៍សង្គម ឬ មនុស្សក្នុងសង្គម។ ជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៧ ដែលជាវិធាននីតិវិធីក្នុងការកំណត់ ការបំពេញតួនាទី ឬ ការធ្វើសកម្មភាពរបស់តុលាការព្រហ្មទណ្ឌគ្រប់ជាន់ថ្នាក់ ជាពិសេសកំណត់អំពីនីតិវិធីស្តីពីការស៊ើបអង្កេត នីតិវិធីចោទប្រកាន់ នីតិវិធីស៊ើបសួរ នីតិវិធីជំនុំជម្រះ ព្រមទាំងបានកំណត់អំពីសិទ្ធិអំណាចរបស់ចៅក្រម ព្រះរាជអាជ្ញា មេធាវី មន្ត្រីនគរបាល គូភាគី សាក្សី អ្នកជំនាញ ជាអាទិ៍។ ក្រមនីតិវិធីព្រហ្មទណ្ឌនេះ ជានីតិវិធីក្នុងការធ្វើសកម្មភាព ឬ ដំណើរការនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌ ដែលអនុវត្តដោយអ្នកវិជ្ជាជីវៈត្រឹមត្រូវ និង មានជំនាញច្បាស់លាស់នៅក្នុងការបំពេញតួនាទីនេះ។

ដូចដែលបានដឹងហើយថាបទល្មើសព្រហ្មទណ្ឌ ជាការប្រព្រឹត្តផ្ទុយច្បាប់ព្រហ្មទណ្ឌ ដែលបង្កឱ្យមានភាពចលាចលដល់សង្គម គ្មានសណ្តាប់ធ្នាប់ និង ហានិភ័យដល់សង្គម ដូច្នេះបុគ្គលណាដែលប្រព្រឹត្តបទល្មើសត្រូវទទួលខុសត្រូវលើអំពើរបស់ខ្លួនដោយមិនអាចឱ្យនរណាម្នាក់មកទទួលខុសត្រូវលើអំពើរបស់ខ្លួនបានទេ ដោយក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ថា វាជាគោលការឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ[1]។ ដូច្នេះវាពិតជាមានសារៈសំខាន់ណាស់នៅក្នុងការស្វែងរកការពិតដើម្បីផ្តន្ទាទោសជនដែលបានប្រព្រឹត្តបទល្មើស ហើយអំណាចក្នុងការស្វែងរកការពិតនេះក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានប្រគល់សិទ្ធិអំណាចទៅឱ្យចៅក្រមស៊ើបសួរនៅក្នុងការស្វែងរក រែកមុខ ប្រមូលភស្តុតាង ព័ត៌មាន ទំហំព្យាសនកម្ម ជនពាក់ព័ន្ធផ្សេងៗជុំវិញការប្រព្រឹត្តអំពើដែលនាំឱ្យមានពាក្យបណ្តឹង ឬ ដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាប្តឹងមកចៅក្រមស៊ើបសួរនេះ។ ក្នុងន័យនេះហើយចៅក្រមស៊ើបសួរមានសិទ្ធិអំណាចពេញលេញ តាមរយៈការផ្តល់ឱ្យដោយក្រមនីតិវិធីព្រហ្មទណ្ឌ

[1] មាត្រា២៤ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

កម្ពុជា។ ហេតុនេះដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរនេះ ពិតជាមានសារៈសំខាន់នៅក្នុងការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅ ។

## ២ ចំណោទបញ្ហា

ដើម្បីសិក្សាទៅលើប្រធានបទចៅក្រមស៊ើបសួរនេះឱ្យបានស៊ីជម្រៅ ត្រូវដឹងជាមុនសិនថាតើចៅក្រមស៊ើបសួរជានរណា? តើចៅក្រមស៊ើបសួរអាចបំពេញតួនាទីដោយវិធីណាខ្លះ? តើគាត់មានសិទ្ធិអំណាចអ្វីខ្លះដើម្បីឱ្យដំណើរការនៃនីតិវិធីព្រហ្មទណ្ឌងាយស្រួលក្នុងការស្វែងរកការពិត ភស្តុតាង ជនដែលពាក់ព័ន្ធ? តើភាគីពាក់ព័ន្ធមានសិទ្ធិអំណាចអ្វីខ្លះ? តើអ្នកណាជាអ្នកធានារ៉ាប់រងការប្រព្រឹត្តទៅដ៏ល្អរបស់មន្ទីរស៊ើបសួរ? តើចៅក្រមស៊ើបសួរបិទបញ្ចប់ការស៊ើបសួររបស់ខ្លួនវិធីណាខ្លះ?

## ៣ គោលបំណង

គោលបំណងក្នុងការស្រាវជ្រាវប្រធានបទ **ចៅក្រមស៊ើបសួរ** នេះគឺចង់យល់ដឹងឱ្យច្បាស់ និង ស៊ីជម្រៅអំពី សញ្ញាណនៃចៅក្រមស៊ើបសួរ ការបើកការស៊ើបសួរ ដំណើរការនៃនីតិវិធីក្នុងការស៊ើបសួររបស់ចៅក្រមស៊ើបសួរ សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ និង ការបិទបញ្ចប់ការស៊ើបសួរ។ ដោយសារតែចៅក្រមស៊ើបសួរមានលក្ខណៈពិសេសមិនអាចខ្វះបានក្នុងការស្វែងរកការពិតនៃរឿងព្រហ្មទណ្ឌ ហើយដំណាក់កាលរបស់ចៅក្រមស៊ើបសួរក្នុងនីតិវិធីព្រហ្មទណ្ឌមានលក្ខណៈស្មុគស្មាញ និង វិសាលភាពធំទូលាយ។

## ៤ ដែនកំណត់

ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌមាន ៤ (បួន) ដំណាក់កាលធំៗសំខាន់ៗ ប៉ុន្តែដែនកំណត់នៃការស្រាវជ្រាវមួយនេះគឺធ្វើការសិក្សា ស្រាវជ្រាវតែអំពី **ចៅក្រមស៊ើបសួរ** តែប៉ុណ្ណោះ។ មានន័យថាការស្រាវជ្រាវចាប់ផ្តើមពីរ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ អំណាចរបស់ចៅក្រមស៊ើបសួរ និង ការបិទបញ្ចប់ការស៊ើបសួរ។

## ៥ សារៈសំខាន់

តាមរយៈការស្រាវជ្រាវអំពី **ចៅក្រមស៊ើបសួរ** នេះអាចនឹងទទួលបាននូវគំនិត ការយល់ដឹងបន្ថែមអំពីការបើកការស៊ើបសួរ អំណាចរបស់ចៅក្រមស៊ើបសួរ ដែលមានដូចជា អំណាចក្នុងការស្រាវជ្រាវ អំណាចបង្ខំ ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ការត្រួតពិនិត្យកិច្ចការរបស់មន្ទីរស៊ើបសួរដោយសភាស៊ើបសួរ និង បានសិក្សាអំពីការបិទការស៊ើបសួរផងដែរ។

## ៦ រចនាសម្ព័ន្ធ

នៅក្នុងការសរសេរសារណាមួយនេះយើងខ្ញុំបានរៀបចំចេញជា អារម្មណ៍កថា សេចក្តីថ្លែងអំណរគុណ មាតិការ សេចក្តីផ្តើម ខ្លឹមសារជំពូកៈ

- ជំពូកទី១ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ
- ជំពូកទី២ អំណាចរបស់ចៅក្រមស៊ើបសួរ
- ជំពូកទី៣ ការបិទបញ្ចប់ការស៊ើបសួរ

ចំពោះផ្នែកបញ្ចប់នៃសារណានេះមាន សេចក្តីសន្និដ្ឋាន អនុសាសន៍ ឯកសារយោង ឧបសម្ព័ន ។

# ជំពូក១

# សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ

# ជំពូក១

# សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ

នៅក្នុងតុលាការមានចៅក្រមច្រើនរូប ក្រឡាបញ្ជីច្រើនរូប និង បុគ្គលិកជាច្រើនផ្សេងទៀត។ ទោះបីជាចៅក្រមមានច្រើនរូបក៏ដោយ ក៏ចៅក្រមមានតួនាទី និង ផ្នែកខុសគ្នាផងដែរ ដូចជា ចៅក្រមអាសនៈ ឬ ចៅក្រមជំនុំជម្រះ ព្រះរាជអាជ្ញា និង ចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរ ជាចៅក្រមដែលបំពេញតួនាទីនៅតាមមន្ទីរស៊ើបសួរនៃតុលាការរាជធានីខេត្តក្រុងនីមួយៗ។ ចៅក្រមស៊ើបសួរជាអ្នកទទួលបន្ទុកក្នុងការស៊ើបសួរដែលធ្វើឡើងដោយគោរពសិទ្ធិរបស់ភាគី ទោះជនរងគ្រោះ ឬ ជនត្រូវចោទក៏ដោយ និយាយឱ្យចំទៅចៅក្រមស៊ើបសួរជាអ្នកស្វែងរក ប្រមូលភស្តុតាងដាក់បន្ទុក និង ដោះបន្ទុក ដើម្បីធានាឱ្យបាននូវសមភាពរវាងគូភាគី ព្រមទាំងស្វែងរកឱ្យឃើញនូវការពិត។ ដើម្បីស្វែងយល់អំពីសញ្ញាណទូទៅនៃចៅក្រមស៊ើបសួរនៅក្នុងជំពូកនេះ សូមបែងចែកជា ២ (ពី) ផ្នែក៖

- ❖ ផ្នែកទី១ សញ្ញាណទូទៅ
- ❖ ផ្នែកទី២ មូលហេតុដែលនាំឱ្យមានការបើកការស៊ើបសួរ

## ផ្នែកទី១ សញ្ញាណទូទៅ

តុលាការ ជាស្ថាប័នដែលមានអំណាចឯករាជ្យមិនស្ថិតក្រោមចំណុះរបស់ស្ថាប័នណាមួយឡើយ។ តុលាការ ជាអ្នកធានារក្សាអនាគតិ និង ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ ដើម្បីធានាប្រសិទ្ធិភាពក្នុងការស្វែងរកការពិត ឬ យុត្តិធម៌ ចៅក្រមស៊ើបសួរជាតួអង្គយ៉ាងសំខាន់មិនអាចខ្វះបាននៅក្នុងដំណើរការរឿងក្តីនៃនីតិវិធីព្រហ្មទណ្ឌ ដែលចៅក្រមស៊ើបសួរធ្វើការនៅក្នុងដំណាក់កាលស៊ើបសួរដែលធ្វើឡើងក្នុងគោលបំណងស្វែងរកការពិតក្នុងបទល្មើសនៃរឿងក្តីមួយ។ ចៅក្រមស៊ើបសួរធ្វើសកម្មភាព និង សមត្ថកិច្ចដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវរកថាមានបទល្មើសដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញាដែរឬទេ? បើកាលណាការស៊ើបសួរស្វែងរកឃើញថាពិតជាមានបទល្មើសកើតឡើងដូចដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់មែន ចៅក្រមស៊ើបសួរនឹងបញ្ជូនសំណុំរឿងដែលខ្លួនបានបំពេញកិច្ចស៊ើបសួរទៅជំនុំជំរះ ប៉ុន្តែបើកាលណាការស៊ើបសួរស្វែងរកឃើញថា មិនមានបទល្មើសកើតឡើងដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញាទេចៅក្រមស៊ើបសួរ នឹងធ្វើការលើកលែងការចោទប្រកាន់។

## ១.១ ការចាត់តាំងដោយប្រធានតុលាការ

ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមយ៉ាងតិច ០២ (ពីរ) រូប តាមដីកាសម្រេចឱ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរ នៅមន្ទីរស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង។ ដីកានេះត្រូវកំណត់ផងដែរអំពីលំដាប់លេខរៀងសម្រាប់ការទទួលបំពេញការងារ។ ក្នុងករណីពុំមានចៅក្រមស៊ើបសួរ ឬ ខ្វះចៅក្រមស៊ើបសួរ ប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមនៃតុលាការជំនាញផ្សេង ដើម្បីបំពេញមុខងារស៊ើបសួរបាន។ ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរអាចបំពេញការងារ ជាចៅក្រមនៅតុលាការជំនាញផ្សេងទៀតបាន តាមការចាត់តាំងរបស់ប្រធានសាលាដំបូង[2]។ កាលណាចៅក្រមស៊ើបសួរណាម្នាក់ ពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាក ដោយមានជម្ងឺ ឬ ដោយមានមូលហេតុដទៃផ្សេងទៀត ចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការដដែលត្រូវបានចាត់តាំងជាបណ្ដោះអាសន្ន ដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ។ ក្នុងករណីពុំមានចៅក្រមស៊ើបសួរទេ ចៅក្រមផ្សេងទៀតនៃតុលាការដដែល អាចត្រូវបានចាត់តាំងជាបណ្ដោះអាសន្ន ដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ[3]។

### ១.១.១ ការបែងចែកសំណុំរឿងដោយប្រធានតុលាការ

កាលណាមានចៅក្រមស៊ើបសួរច្រើនរូបនៅក្នុងតុលាការមួយសំណុំរឿងទាំងឡាយត្រូវបែងចែកដោយប្រធានតុលាការ[4]។ ប្រធានតុលាការរាជធានីខេត្តជាអ្នកមានសិទ្ធិអំណាចក្នុង បែងចែកសំណុំរឿង លំដាប់សម្រាប់ជំនួសក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ និងដកហូតសំណុំរឿង ដោយដីកាសម្រេចជារៀងរាល់ឆ្នាំ។ ការបែងចែករឿងក្ដីមួយ និង លំដាប់ជំនួសក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ ត្រូវបានកំណត់ទុកជាមុនជារៀងរាល់ឆ្នាំដោយដីកាសម្រេចរបស់ប្រធានតុលាការ[5]។

### ១.១.២ ការដកហូតសំណុំរឿង

ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ ដើម្បីប្រគល់ជូនចៅក្រមស៊ើបសួរម្នាក់ទៀតអាចស្នើទៅប្រធានតុលាការ ដើម្បីជាប្រយោជន៍នៃរដ្ឋបាលដ៏ល្អនៃយុត្តិធម៌ និងជៀសវាងភាពលម្អៀង។ ការស្នើសុំនេះអាចធ្វើឡើងដោយពាក្យសុំដែលមានសំអាងហេតុរបស់ព្រះរាជអាជ្ញា ដែលធ្វើឡើងដោយការផ្ដើមគំនិតផ្ទាល់ខ្លួន ឬ

2 មាត្រា២០ ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤

3 មាត្រា៥១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

4 មាត្រា៥២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

5 មាត្រា២៦ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

តាមរយៈពាក្យប្តឹងរបស់ភាគី[6]។ មូលហេតុនៃការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរគឺជាមូលហេតុនៃការប្តឹងជំទាស់ចៅក្រមអាសនៈ[7]មានដូចជា៖

- កាលណាចៅក្រម ឬ សហព័ទ្ធរបស់ចៅក្រម ឬ អតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី
- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី៦ ឬ ញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬ អតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ភាគីណាមួយ
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ
- កាលណាចៅក្រមដែលទទួលបន្ទុកក្នុងរឿងក្តី ធ្លាប់ ឬ កំពុងមានវិវាទនៅក្នុងតុលាការជាមួយភាគីណាមួយ
- កាលណាចៅក្រមបានធ្វើជាសាក្សី ឬ អ្នកជំនាញក្នុងរឿងក្តី
- កាលណាចៅក្រមជា ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តី
- កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីក្នុងនាមជាមជ្ឈត្តករចំពោះរឿងក្តី ឬ បានចូលរួមក្នុងការសម្រេចសេចក្តីនៅសាលាដំបូងដែលបានប្តឹងឧបាស្រ័យ ឬ ការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬ បង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី។

## ១.២ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ

សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរត្រូវបានផ្តល់ឱ្យយ៉ាងជាក់លាក់ដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដែលជាមូលដ្ឋានគ្រឹះនៅក្នុងការធ្វើសកម្មភាព។

### ១.២.១ សមត្ថកិច្ចដែនដី

ចៅក្រមស៊ើបសួរមានសមត្ថកិច្ចដែនដីនៅក្នុងការបំពេញតួនាទី ឬ ធ្វើសកម្មភាពដូចខាងក្រោម[8] ៖

- សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនាទីកន្លែងប្រព្រឹត្តបទល្មើស
- សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស

6 មាត្រា៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

7 មាត្រា៥៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

8 មាត្រា១២៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

– សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។

នៅក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្តឹងអំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅសភាស៊ើបសួរដើម្បីធ្វើការសម្រេចសេចក្តី។ ចំពោះវិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល ហើយការសម្រេចនេះ គឺបិទផ្លូវតវ៉ា។

### ១.២.២ សមត្ថកិច្ចតាមសាច់រឿង

ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរបានលុះត្រាតែទទួលបានពាក្យបណ្តឹងពីព្រះរាជអាជ្ញា ឬហៅថាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា និង ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវតែធ្វើឡើងដោយខានពុំបានចំពោះបទឧក្រិដ្ឋ និង អាចធ្វើការស៊ើបសួរក៏វបាន អត់ក៏បានចំពោះបទមជ្ឈិម[9]។ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចលើគ្រប់បុគ្គលទាំងអស់ លើកលែងតែរឿងព្រហ្មទណ្ឌជាសមត្ថកិច្ចរបស់តុលាការពិសេស។

### ១.៣ ការសម្ងាត់នៃការស៊ើបសួរ

ការស៊ើបសួរត្រូវតែជាការសម្ងាត់[10]។ មានន័យថារាល់បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យខាងបច្ចេកទេស ឬ វិទ្យាសាស្ត្រ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ។ ប៉ុន្តែការគោរពនូវវិជ្ជាជីវៈមិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ គឺបានសេចក្តីថានៅពេលដែលមានប្រយោជន៍ដើម្បីការពារខ្លួន បុគ្គលដែលទទួលរងការចោទប្រកាន់ខុសពីការពិត អាចនិយាយអំពីការសម្ងាត់ដើម្បីការពារខ្លួនបាន។ ម្យ៉ាងវិញទៀតព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈកាលណាខ្លួនយល់ឃើញថា ព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត។ ប្រសិនបើមានការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

9 មាត្រា១២២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

10 មាត្រា១២១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

## ផ្នែកទី២ មូលហេតុដែលនាំឱ្យមានការបើកការស៊ើបសួរ

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបញ្ញត្តិយ៉ាងច្បាស់អំពីការបើកការស៊ើបសួរក្នុងគោលបំណងធ្វើយ៉ាងណាឱ្យរឿងក្តីមួយត្រូវតែមានលក្ខណៈច្បាស់លាស់មុននឹងឈានដល់ការសម្រេចក្តី។ ការស៊ើបសួរត្រូវតែធ្វើឡើងជាដាច់ខាតចំពោះបទឧក្រិដ្ឋ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬ មិនធ្វើក៏បាន[11]។ មូលហេតុដែលអាចឱ្យចៅក្រមបើកការស៊ើបសួរបានគឺ មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

### ២.១ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ចៅក្រមស៊ើបសួរអាចធ្វើការបើកការស៊ើបសួរបានលុះត្រាតែមានបណ្តឹងពីព្រះរាជអាជ្ញា ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬ ច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញាតជន។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន[12]៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានទេ បើសិនជាគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា[13]។ បន្ទាប់ពីបានទទួលបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ។ ចំណុចនេះបានកំណត់អំពីវិសាលភាពនៃការស៊ើបសួរដោយចៅក្រមស៊ើបសួរតាមអង្គហេតុ ប៉ុន្តែចៅក្រមស៊ើបសួរមិនមានកាតព្វកិច្ចត្រូវសម្រេចតាមការកំណត់បទល្មើសដោយព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ ពោលគឺចៅក្រមស៊ើបសួរអាចកំណត់បទល្មើសបាន កុំឱ្យតែការកំណត់បទល្មើសនោះទាក់ទងនឹងអង្គហេតុថ្មីដែលពុំមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះ។ ប្រសិនបើមានលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវតែជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះតាមដីកាសន្និដ្ឋានបញ្ជូនរឿង

11 មាត្រា១២២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

12 មាត្រា៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

13 មាត្រា១២៤ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ឱ្យស៊ើបសួរបន្ថែមបាន ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាមានប្រយោជន៍ ឬ ពាក់ព័ន្ធនឹងអង្គហេតុដើមដែលបានបញ្ជូនឱ្យស៊ើបសួរនោះ ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ប៉ុន្តែបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះទេ។ ចៅក្រមស៊ើបសួរក៏អាចបើកការស៊ើបសួរដោយខ្លួនឯងបានផងដែរ ដោយមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង[14]។

## ២.២ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម អាចដាក់ពាក្យប្តឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ច ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ កាលណាការស៊ើបសួរត្រូវបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថាជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា[15]។ ពាក្យបណ្តឹងដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ អាចធ្វើឡើងដោយជនរងគ្រោះខ្លួនឯងផ្ទាល់ ឬ ដោយមេធាវីក្នុងនាមជាជនរងគ្រោះផងដែរ។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មិនមានការកំណត់ទម្រង់ណាមួយទេ ពោលគឺអាចដាក់ពាក្យបណ្តឹងតាមដោយមានលិខិត ឬ ដោយផ្ទាល់មាត់ក៏បាន។ ក្រោយពីបានទទួលបណ្តឹងដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើការកត់សម្គាល់នូវការដាក់ពាក្យបណ្តឹងតាមរយៈដីកា ហើយបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។ បន្ទាប់ពីព្រះរាជអាជ្ញាបានទទួលបណ្តឹងដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះអាចប្រឆាំងនឹងអញ្ញាតជន ឬ ចោទប្រកាន់ទៅលើឈ្មោះបុគ្គលម្នាក់ ឬ ច្រើននាក់។ ព្រះរាជអាជ្ញាក៏អាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬ ប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ក្នុងករណីដែលព្រះរាជអាជ្ញាសុំកុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ចៅក្រមស៊ើបសួរមានជម្រើស ២ គឺ៖

- ជម្រើសទី១ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសម្អាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

14 មាត្រា១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

15 មាត្រា១៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

– ជម្រើសទី ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសម្អាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។

ដើម្បីការពារកុំឱ្យមានពាក្យបណ្ដឹងដោយបំពាន និង អូសបន្លាយពេលវេលា ចៅក្រមស៊ើបសួរត្រូវកំណត់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី បង់នូវប្រាក់តម្កល់ទុកតាមដីកាសម្រេចកំណត់ចំនួនទឹកប្រាក់ត្រូវបង់ និង រយៈពេលដែលត្រូវបង់ប្រាក់។ ទោះជាយ៉ាងណាក្ដីចៅក្រមស៊ើបសួរចេញដីកាសម្រេចនេះដោយផ្អែកទៅលើធនធាននៃដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ឬ បន្ទុករបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងករណីដែលមានការបង់ប្រាក់តម្កល់ទុក ដើមបណ្ដឹងរដ្ឋប្បវេណីនឹងទទួលបានបង្កាន់ដៃដែលមានចុះហត្ថលេខាប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឱ្យបង់ប្រាក់នេះបាន។ បើកាលណាប្រាក់តម្កល់ទុកមិនត្រូវបានបង់នៅក្នុងរយៈពេលដែលបានកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវប្រកាសមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅដើមបណ្ដឹងរដ្ឋប្បវេណីជាបន្ទាន់ ឬ ក្នុងថេរវេលាយ៉ាងខ្លីបំផុត។

ប្រាក់តម្កល់ទុកនឹងត្រូវបានបង្វិលទៅសាមីខ្លួនដែលជាដើមបណ្ដឹងរដ្ឋប្បវេណីវិញនៅពេលបញ្ចប់នីតិវិធី ប៉ុន្តែប្រាក់តម្កល់ទុលមិនត្រូវបានបង្វិលទៅសាមីខ្លួនដែលជាដើមបណ្ដឹងរដ្ឋប្បវេណីវិញទេប្រសិនបើការស៊ើបសួរបានបើកបន្ទាប់ពីមានពាក្យបណ្ដឹងដោយមានការខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបិទដោយដីកាលើកលែងការចោទប្រកាន់ ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថានីតិវិធីធ្វើឡើងដោយរំលោភ ឬ ដោយអូសបន្លាយពេលវេលានោះចៅក្រមស៊ើបសួរអាចសម្រេចតាមដីកាឱ្យដើមបណ្ដឹរដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណី។ ចំនួនទឹកប្រាក់ដែលពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ ហើយដីកាសម្រេចឱ្យបង់ប្រាក់ពិន័យនេះត្រូវឱ្យដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណីឱ្យបានឆាប់បំផុត។

កាលណាការស៊ើបសួរដែលបើកបន្ទាប់ពីមានពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបិទដោយដីកាលើកលេងការចោទប្រកាន់ចូលជាស្ថាពរ បុគ្គលដែលមានឈ្មោះក្នុងពាក្យបណ្ដឹងអាចប្ដឹងទៅអ្នកដែលបានប្ដឹងខ្លួនវិញឱ្យជុះជុលសំណង បើកាលណានីតិវិធីធ្វើឡើងដោយរំលោភ ឬ ដោយអូសបន្លាយពេលវេលា។

# ជំពូក២

# អំណាចរបស់ចៅក្រមស៊ើបសួរ

# ជំពូក២

# អំណាចរបស់ចៅក្រមស៊ើបសួរ

កាលណាចៅក្រមស៊ើបសួរ ទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញារួចហើយ ចៅក្រមស៊ើបសួររូបនោះមានសិទ្ធិអំណាចក្នុងការបើកការស៊ើបសួរ ឬ មានអំណាចក្នុងការអនុវត្តនីតិវិធីរបស់ខ្លួនទៅតាមច្បាប់។ ដើម្បីស្វែងយល់អំពីអំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងជំពូកនេះ សូមបែងចែកជា ២ ផ្នែកៈ

- ផ្នែកទី១ អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ
- ផ្នែកទី២ អំណាចបង្ខំរបស់ចៅក្រមស៊ើបសួរ

## ផ្នែកទី១ អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

ដើម្បីធានាឱ្យបាននូវការស៊ើបសួរដែលមានប្រសិទ្ធិភាព និង ធានាឱ្យបាននូវភាពយុត្តិធម៌ ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់[16]។ នៅក្នុងផ្នែកនេះ សូមធ្វើការចែកជា ៣ ចំណុចធំៗគឺៈ

- ចំណុច ១.១ នីតិវិធីនៃកាស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ
- ចំណុច ១.២ ដីកាចាត់ឱ្យស៊ើបសួរជំនួស

### ១.១ នីតិវិធីនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

បន្ទាប់ពីបានទទួលពាក្យបណ្ដឹងពីព្រះរាជអាជ្ញា ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការដំណើរការនៃនីតិវិធីរបស់ខ្លួន។ ក្នុងការដំណើរការនៃនីតិវិធី ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីម្នាក់អមជានិច្ច[17] ក៏ប៉ុន្តែក្នុងករណីណាក៏ដោយក្រឡាបញ្ជីមិនអាចបំពេញកិច្ចណាមួយដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបាននោះទេ។ នៅក្នុងនីតិវិធីនៃការស្រាវជ្រាវនេះ ចៅក្រមស៊ើបសួរមានសិទ្ធិដូចជាៈ ដាក់ឱ្យនៅក្រោមការពិនិត្យ សួរចម្លើយជនត្រូវចោទ ស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ស្ដាប់ចម្លើយសាក្សី សួរតទល់ ចុះដល់កន្លែងកើតហេតុ ឆែកឆេរ និងចាប់យកវត្ថុតាង កោសលវិច័យ និង ស្ដាប់ទូរស័ព្ទ ជាអាទិ៍។

16 មាត្រា១២៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
17 មាត្រា១២៨ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

### ១.១.១ ការដាក់ឱ្យនៅក្រោមការពិនិត្យ

ចៅក្រមស៊ើបសួរត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[18]។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតក្រោមការពិនិត្យបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីចង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើសទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ បុគ្គលដែលដាក់ឱ្យស្ថិតនៅក្រោមការពិត្យក្នុងឋានៈជាចារី ជាអ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិតទៅតាមការសម្រេច ឬ ការយល់ឃើញរបស់ចៅក្រមស៊ើបសួរ។ កាលណាជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាព ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាពនោះ នឹងក្លាយជាភាគីនៃសំណុំរឿងព្រហ្មទណ្ឌ។ ចៅក្រមស៊ើបសួរ ត្រូវប្រាប់អំពីសិទ្ធិនានារបស់ជននោះ ដូចជា សិទ្ធិការពារខ្លួនតាមរយៈសិទ្ធិទទួលជំនួយពីមេធាវី សិទ្ធិចូលរួមក្នុងការការពារខ្លួនដោយឆ្លើយ ឬ មិនឆ្លើយសំណួររបស់ចៅក្រមស៊ើបសួរ សិទ្ធិត្រូវបានស្តាប់ចម្លើយដោយចៅក្រមស៊ើបសួរ សិទ្ធិទទួលបានព័ត៌មានអំពីការសម្រេចរបស់ចៅក្រមស៊ើបសួរ និងសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ជាអាទិ៍។

#### ក បុគ្គលដែលអាចដាក់ឱ្យនៅក្រោមការពិនិត្យ

ចៅក្រមស៊ើបសួរ ជាអ្នកវាយតម្លៃអំពីកាលានុវត្តភាពនៃការជូនដំណឹងពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ជាយថាហេតុបន្ទាប់ពីបានស៊ើបសួរចាំបាច់ផ្សេងៗរួចមក។

ការប៉ុនប៉ងអាចខ្លាំងចំពោះចៅក្រម និង មន្ត្រីនគរបាលយុត្តិធម៌ ដែលអនុវត្តដីកាចាត់ឱ្យស៊ើបសួរក្នុងការបន្តស្តាប់ចម្លើយក្នុងឋានៈជាសក្សីនូវបុគ្គលដែលមានតម្រុយពិរុទ្ធភាពធ្ងន់ធ្ងរ និង ស៊ីចង្វាក់គ្នាក្នុងគោលដៅពន្យាពេលទទួលជំនួយពីមេធាវី និង ដើម្បីទទួលនូវភស្តុតាងដាក់បន្ទុក ឬ ចម្លើយសារភាពដោយងាយស្រួល។ ដើម្បីគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាដែលមានតម្រុយពិរុទ្ធភាពនោះទេ។ លើសពីនេះទៅទៀត បុគ្គលដែលមានចង្អុលប្រាប់ឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា អាចត្រូវបានស្តាប់ចម្លើយដោយចៅក្រមស៊ើបសួរតែក្នុងឋានៈជាជនត្រូវចោទប៉ុណ្ណោះ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចដាក់ឱ្យស្ថិតក្រោមការពិនិត្យ។

#### ខ បែបបទនៃការដាក់ឱ្យនៅក្រោមការពិនិត្យ

ការដាក់ឱ្យនៅក្រោមការពិនិត្យ ត្រូវបានធ្វើឡើងនៅពេលដែលជនត្រូវចោទ ឬ ជនដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា ចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។

---

18 មាត្រា១២៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់រឿងរ៉ាវដែលបានចោទប្រកាន់ និង ឈ្មោះបទល្មើសដែលបានកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរត្រូវប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬ មិនឆ្លើយបានដោយសេរី[19] ហើយចៅក្រមស៊ើបសួរត្រូវទទួលចម្លើយរបស់ជនត្រូវចោទ ប្រសិនបើជនត្រូវចោទយល់ព្រមឆ្លើយ។ ចៅក្រមស៊ើបសួរក៏ត្រូវប្រាប់ជនត្រូវចោទឱ្យដឹងពីសិទ្ធិក្នុងការជ្រើសរើសមេធាវី ឬ សិទ្ធិសុំឱ្យចាត់តាំងមេធាវីដល់ខ្លួនផងដែរ ប៉ុន្តែចំពោះអនីតិជនត្រូវតែមានមេធាវីជានិច្ច។ ជនត្រូវចោទត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរឱ្យបានដឹងបើសិនជាខ្លួនបានផ្លាស់ប្តូរអាសយដ្ឋាន ហើយចៅក្រមស៊ើបសួរត្រូវចុះកំណត់ហេតុអំពីការផ្លាស់ប្តូរអាសយដ្ឋាននេះ។

### ១.១.២ ការសួរចម្លើយជនត្រូវចោទ

ការសួរចម្លើយជនត្រូវចោទ គឺជាការកោះហៅជនត្រូវចោទឱ្យចូលមកបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការសាកសួរជនត្រូវចោទនោះ បើកាលណាជនត្រូវចោទមានមេធាវីអមចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ ថ្ងៃ មុនការសួរចម្លើយ ហើយក្នុងថេរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី[20]។ ការសួរចម្លើយជនត្រូវចោទអាចធ្វើនៅចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ ប៉ុន្តែប្រសិនបើមេធាវីត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និង ម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានរបស់មេធាវីបាន ហើយនិទ្ទេសស្តីអំពីអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ។ នៅក្នុងករណីពិសេសចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយមិនចាំបាច់កោះហៅមេធាវីទេ ប្រសិនបើជនត្រូវចោទបានបោះបង់ចោលសិទ្ធិយ៉ាងជាក់ស្តែងក្នុងការមានមេធាវី។ មួយវិញទៀតក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយជនត្រូវចោទដោយមិនចាំបាច់កោះហៅមេធាវីបាន ភាពបន្ទាន់នេះត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង ហើយប្រភេទនៃភាពបន្ទាន់នេះនឹងត្រូវបានចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។

នៅពេលចៅក្រមស៊ើបសួរធ្វើការសួរចម្លើយទៅលើជនត្រូវចោទ ព្រះរាជអាជ្ញា និង មេធាវី ក៏មានវត្តមានដែរ ហើយព្រះរាជាអាជ្ញា និង មេធាវី ក៏អាចសួរសំណួរទៅកាន់ជនត្រូវចោទបានផងដែរ ប៉ុន្តែទាល់តែមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងករណីមិនអនុញ្ញាត ត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ។ បន្ទាប់ពីជនត្រូវចោទត្រូវបានសួរចម្លើយដោយចៅក្រមស៊ើបសួរ នៅពេលចូលបង្ហាញខ្លួនលើកទីដំបូង បាន

19 មាត្រា១៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

20 មាត្រា១៤៥ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

កន្លងផុតទៅ ៤ ខែរួចហើយ ជនត្រូវចោទអាចស្នើសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការសួរចម្លើយខ្លួន ឬ សួរតទល់បាន។ ប្រសិនបើរយៈពេលមួយខែបន្ទាប់ពីបានទទួលពាក្យសុំរបស់ជនត្រូវចោទហើយ ចៅក្រមស៊ើបសួរមិនព្រមធ្វើការកោះហៅទេ ជនត្រូវចោទអាចប្ដឹងទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង។ កំណត់ហេតុសួរចម្លើយនេះត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។

ក្នុងករណីដែលជនត្រូវចោទនៅក្នុងពន្ធនាគារ ឬ នៅក្នុងមណ្ឌលឃុំខ្លួន មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំអាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្ដីរបស់ខ្លួនបាន។ មេធាវីអាចអានសំណុំរឿងឱ្យកូនក្ដីរបស់ខ្លួនស្ដាប់បាន ប៉ុន្តែមិនអាចថតចម្លងលិខិតសំណុំរឿងឱ្យកូនក្ដីរបស់ខ្លួនបានទេ។ ការសន្ទនាទាំងឡាយរបស់មេធាវី និង ជនត្រូវចោទមិនអាចត្រូវបានគេស្ដាប់ ឬ ថតបានទេ។

មួយវិញទៀតចំពោះការសួរចម្លើយទៅលើអនីតិជន ត្រូវគោរពទៅតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។ បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម[21]។ ជនត្រូវចោទដែលជាអនីតិជនត្រូវមានមេធាវីអមជានិច្ចក្នុងកំឡុងពេលស្ដាប់ចម្លើយនៅមុខចៅក្រមស៊ើបសួរ ប៉ុន្តែបើគ្មានការជ្រើសរើសមេធាវី ចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវីឱ្យជនត្រូវចោទ។

### ១.១.៣ ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណីជាភាគីសំខាន់បំផុតមួយដែលចាំបាច់ត្រូវតែស្ដាប់ចម្លើយរបស់គាត់ ពីព្រោះគាត់ជាអ្នកទទួលរងនូវព្យសនៈកម្មដោយផ្ទាល់ ដូច្នេះចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយរបស់គាត់ និងលើកសំណួរទៅតាមអ្វីដែលចៅក្រមស៊ើបសួរចង់ដឹង ដូចជា ហេតុការណ៍ ឬ អង្គហេតុ ទំហំព្យសនៈកម្ម ការទាមទារ ជាដើម។ ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវី[22]។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងតិច ៥ ថ្ងៃ មុនការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ហើយនៅក្នុងចិរវេលានេះមេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន។ ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានស្ដាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ ប៉ុន្តែបើសិនជាមេធាមិនបានចូលបង្ហាញខ្លួនតាមការកោះហៅទេ ចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីបានដោយគ្មានវត្តមានមេធាវី ហើយអវត្តមានមេធាវីនេះ នឹងត្រូវបានចុះនៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី។ គួរបញ្ជាក់ផងដែរថា ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចបោះបង់សិទ្ធិក្នុងការមានមេធាវីដែរ ហើយការបោះបង់នេះនឹងត្រូវបាន

21 មាត្រា៣២ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦
22 មាត្រា១៥០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ចុះក្នុងកំណត់ហេតុដោយឡែកមួយ និង ហត្ថលេខារបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយមិនចាំបាច់កោះហៅមេធាវីបាន ភាពបន្ទាន់នេះត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង ហើយប្រភេទនៃភាពបន្ទាន់នេះនឹងត្រូវបានចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។

គួរបញ្ជាក់ថាបើជនរងគ្រោះជាអនីជន ការស្តាប់ចម្លើយត្រូវធ្វើឡើងដោយនីតិវិធីកុមារមេត្រី[23] ពោលគឺសំដៅលើដំណើរការ និង នីតិវិធីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តឱ្យអនីតិជនចូលរួមក្នុងរឿងក្តី តាមរយៈការប្រើប្រាស់ភាសា និង អាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និង ក្នុងបរិយាកាសដែលផ្តល់ឱ្យអនីតិជននូវសិរវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន។

### ១.១.៤ ការស្តាប់ចម្លើយសាក្សី

សាក្សី គឺជាបុគ្គលដែលបានឃើញ ឬ បានលឺដោយផ្ទាល់នូវបទល្មើសដែលកំពុងកើតឡើង ឬមុនពេលបទល្មើសបានកើតឡើង និងជាបុគ្គលដែលអាចផ្តល់ព័ត៌មានសម្រាប់ជាប្រយោជន៍ដល់ការបង្ហាញនូវការពិត។ សាក្សីអាចជាសាក្សីដាក់បន្ទុក ឬ សាក្សីដោះបន្ទុក។ ចៅក្រមស៊ើបសួរអាចកោះហៅបុគ្គលគ្រប់រូបឱ្យចូលមកបង្ហាញខ្លួនក្នុងឋានៈជាសាក្សី ដើម្បីនឹងស្តាប់ចម្លើយទៅតាមការចង់បានរបស់ចៅក្រមស៊ើបសួរ។ បុគ្គលដែលត្រូវបានកោះហៅក្នុងឋានៈជាសាក្សីត្រូវចូលមកបង្ហាញខ្លួនតាមការកំណត់ និង ត្រូវស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួនថានិយាយតែការពិត លើកលែងតែសាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ[24] ដូចជាឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងគ្នាហើយក៏ដោយ និង កុមារដែលមានអាយុតិចជាង ១៤ឆ្នាំ។ ផ្ទុយមកវិញ ប្រសិនបើបុគ្គលណាដែលត្រូវបានកោះហៅក្នុងឋានៈជាសាក្សីមិនព្រមចូលបង្ហាញខ្លួនតាមការកោះហៅទេ ចៅក្រមស៊ើបសួរអាចសុំឱ្យកម្លាំងសាធារណៈបង្ខំសាក្សីឱ្យចូលបង្ហាញខ្លួនបាន ដោយបញ្ជានេះត្រូវកំណត់អត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ ហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងបោះត្រា ដើម្បីឱ្យបញ្ជានេះមានភាពច្បាស់លាស់ និងទៅតាមគោលដៅដែលចង់បាន។ មួយវិញទៀតប្រសិនបើសាក្សីឈឺ ឬ មិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី អាចចុះទៅកាន់លំនៅឋាន ឬ ទីកន្លែងដែលសាក្សីនោះនៅដើម្បីទទួលចម្លើយ។

23 មាត្រា៤ ចំណុច៧ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

24 មាត្រា១៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

គួរបញ្ជាក់ផងដែរថា រាល់ចម្លើយសាក្សី គឺមានប្រយោជន៍ក្នុងការសម្តែងឱ្យឃើញនូវការពិតនៃអង្គហេតុ កាលណាចម្លើយនោះស៊ីចង្វាក់គ្នាទៅនឹងចម្លើយរបស់ជនត្រូវចោទ ឬ ចម្លើយរបស់ជនរងគ្រោះ ហើយវាជាមូលដ្ឋានមួយផ្នែកដែលមានប្រយោជន៍ដល់កិច្ចនីតិរបស់ចៅក្រមស៊ើបសួរ ប៉ុន្តែចៅក្រមស៊ើបសួរក៏ឆន្ទានុសិទ្ធិសម្រេចថា គួរជឿ ឬ មិនជឿបានផងដែរ។

### ១.១.៥ ការសួរតទល់

ការសួរតទល់គ្នាអាចឱ្យនិយមន័យបានថាជាការសួរចម្លើយ ឬ ការស្តាប់ចម្លើយបុគ្គលជាច្រើនព្រមគ្នាក្នុងគោលដៅធ្វើឱ្យលេចចេញនូវការពិតក្នុងរឿងក្តី តាមរយៈចម្លើយ និង ជំហររបស់បុគ្គលម្នាក់ៗដែលត្រូវបានសួរដោយចៅក្រមស៊ើបសួរ។ ការសួរតទល់នេះធ្វើឡើងដោយមានវត្តមានរបស់ ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង ជនត្រូវចោទ ហើយត្រូវអនុវត្តដូចនីតិវិធីនៃការសួរចម្លើយជនត្រូវចោទ ឬ នីតិវិធីស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ក្នុងករណីដែលមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា និង មេធាវី ក៏អាចលើកជាសំណួរបានផងដែរ។ កិច្ចនីតិវិធីនេះ ត្រូវបានចុះក្នុងកំណត់ហេតុនៃការសួរតទល់។

### ១.១.៦ ការឆែកឆេរ និង ការចាប់យកវត្ថុតាង

ការឆែកឆេរគឺជាការស្វែងរកវត្ថុតាងនៅទីកន្លែងណាមួយដែលចៅក្រមស៊ើបសួរយល់ឃើញថាត្រូវធ្វើការឆែកឆេរ ដើម្បីជាប្រយោជន៍ដល់ការអនុវត្តកិច្ចនីតិវិធីរបស់ខ្លួន។ ចៅក្រមស៊ើបសួរអាចធ្វើការការឆែកឆេរបាន[25]។ ការឆែកឆេរនេះចៅក្រមស៊ើបសួរត្រូវធ្វើឡើងនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដោយមានការចាត់ចាំងពីចៅក្រមស៊ើបសួរ។ សាក្សីដែលត្រូវបានចាត់តាំង មិនអាចជានគរបាល ឬ កងកម្លាំងរាជអាវុធហត្ថ ដែលរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។ ក្នុងការអនុវត្តចុះឆែកឆេរ ចៅក្រមស៊ើបសួរមិនអាចធ្វើឡើងមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោមម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច បានទេ លើកលែងតែៈ

- ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណៈជន
- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀន។

[25] មាត្រា១៥៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ប្រសិនបើការឆែកឆេរនៅក្នុងការិយាល័យមេធាវី ការឆែកឆេរនេះត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូរបស់គណៈមេធាវីនោះ។

រាល់ការឆែកឆេរ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និង ក្រឡាបញ្ជី រួមទាំងអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី ២ (ពីរ) នាក់។ កំណត់ហេតុនេះត្រូវចុះនិទ្ទេស អំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីនីមួយៗ ហើយបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬ ប្រតិភូដែលមានវត្តមាននោះ។

ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាង និងត្រូវបិទស្លាកបោះត្រាលើវត្ថុតាង[26]។ វត្ថុតាងដែលចាប់បានចៅក្រមស៊ើបសួរត្រូវបង្ហាញដល់អ្នកកាន់កាប់ទីកន្លែង និង សាក្សីទាំង ២ (ពីរ) នាក់ ហើយត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យក និង បញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលបានចាប់យក ដោយមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ ក្រឡាបញ្ជី និង អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីទាំង ២ (ពីរ) នាក់។

### ១.១.៧ កោសលវិច័យ

ការធ្វើកោសលវិច័យ គឺជាការពិនិត្យ ឬ វិភាគទៅលើវត្ថុតាង ដែលធ្វើឡើងដោយលក្ខណៈបច្ចេកទេស។ នៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬ ដោយមានពាក្យរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី[27]។ ក្នុងករណីដែលចៅក្រមស៊ើបសួរបដិសេធមិនធ្វើកោសលវិច័យតាមពាក្យសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចបដិសេធក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បើសិនជាការបដិសេធទៅលើពាក្យសុំរបស់ព្រះរាជអាជ្ញា និង ក្នុងរយៈពេល ១ (មួយ) ខែ បើសិនជាពាក្យសុំរបស់ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលដែលចៅក្រមស៊ើបសួរបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬ ដោយមានពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីក្តី ចៅក្រមស៊ើបសួរត្រូវជ្រើសរើសអ្នកជំនាញដែលមានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ ដែលបានរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តធម៌។ ចៅក្រមស៊ើបសួរក៏អាចជ្រើសរើសអ្នកជំនាញដែលមិនមានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញបានផងដែរ ដោយដីកាសំអាងហេតុជាពិសេស និង ត្រូវឱ្យអ្នកជំនាញនោះធ្វើការស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួន។ នៅក្នុងដីកាចាត់តាំងអ្នកជំនាញរបស់ចៅក្រមស៊ើបសួរ ត្រូវបានកំណត់អំពីបេសកកម្ម និង រយៈពេលដែលត្រូវបំពេញបេសកកម្មជាក់លាក់ ប៉ុន្តែបើសិនជាមានការលំបាកនៅពេលបំពេញបេសកកម្មអ្នកជំនាញក៏អាចសុំពន្យាពេលបានផងដែរ។

26 មាត្រា១៦០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
27 មាត្រា១៦២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

បេសកកម្មអាចទាក់ទងទៅនឹងបញ្ហាដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ។ អ្នកជំនាញដែលត្រូវបានចាត់តាំងអាចជាម្នាក់ ឬ ច្រើននាក់ទៅតាមកាលៈទេសៈតម្រូវ និង ត្រូវបំពេញបេសកកម្មរបស់ខ្លួន ក្រោមការត្រួតពិនិត្យរបស់ចៅក្រមស៊ើបសួរ[28]។

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបបានក្រៅពីជនត្រូវចោទ ប៉ុន្តែក្នុងករណីចាំបាច់អ្នកជំនាញក៏អាចស្តាប់ចម្លើយជនត្រូវចោទបានផងដែរ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ជនត្រូវចោទអាចសុំឱ្យអ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួន ចំពោះមុខមេធាវី ប៉ុន្តែបើជាការពិនិត្យវេជ្ជសាស្ត្រ ឬ ចិត្តសាស្ត្រ ត្រូវធ្វើដោយគ្មានវត្តមានមេធាវី។ ចម្លើយដែលអ្នកជំនាញបានទទួល មានតម្លៃត្រឹមតែជាព័ត៌មានធម្មតាប៉ុណ្ណោះ ហើយអ្នកដែលត្រូវបានស្តាប់នោះមិនចាំបាច់ស្បថទេ។

ក្រោយបំពេញបេសកកម្មរួចហើយ អ្នកជំនាញត្រូវធ្វើរបាយការណ៍ ពណ៌នាអំពីប្រតិបត្តិការរបស់ខ្លួន និង សេចក្តីសន្និដ្ឋានជូនចៅក្រមស៊ើបសួរ។ នៅពេលដែលចៅក្រមស៊ើបសួរបានទទួលរបាយការណ៍កោសលវិច័យរួចហើយ ត្រូវជូនព័ត៌មានទៅកាន់ព្រះរាជអាជ្ញា និង កោះហៅជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវី ដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃការធ្វើកោសលវិច័យ។ បន្ទាប់ពីព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី បានដឹងអំពីរបាយការណ៍កោសលវិច័យរួចហើយ អាចដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុត្រឹមត្រូវឱ្យធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យបាន ដែលចៅក្រមស៊ើបសួរបានទុកពេលឱ្យដើមម្បីអាចដាក់ពាក្យសុំ ហើយរយៈពេលនេះមិនតិចជាង ១០ (ដប់) ថ្ងៃ ហើយនៅក្នុងរយៈពេលនេះមេធាវីក៏អាចសុំពិនិត្យសំណុំរឿងដែលរួមមានរបាយការណ៍កោសលវិច័យជាដើម។ បើកាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវចេញសេចក្តីសម្រេចដែលមានសំអាងហេតុក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ចំពោះពាក្យសុំរបស់ព្រះរាជអាជ្ញា និង រយៈពេល ១ (មួយ) ខែ ចំពោះពាក្យសុំរបស់ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ ចំណែកឯសោហ៊ុយក្នុងការធ្វើកោសលវិច័យជាបន្ទុករបស់អ្នកសុំ តែបើការស្នើសុំធ្វើកោសលវិច័យធ្វើឡើងដោយចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌បន្ទុកសោហ៊ុយជារបស់រដ្ឋ[29]។

### ១.១.៨ ការស្តាប់ទូរស័ព្ទ

ការស្តាបទូរស័ព្ទ គឺជានីតិវិធីមួយដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិបុគ្គលឯកជន ហេតុនេះមានតែចៅក្រមស៊ើបសួរប៉ុណ្ណោះដែលមានសិទ្ធិអំណាចក្នុងការបង្គាប់ឱ្យស្តាប់ទូរស័ព្ទបាន។ ជាការចាំបាច់ដើម្បី

28 មាត្រា១៦៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
29 មាត្រា១៧១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

សម្តែងឱ្យឃើញនូវការពិតចៅក្រមស៊ើបសួរបង្គាប់ឱ្យស្តាប់ បង្គាប់ឱ្យចាប់ និង ថតការសន្ទនាតាមទូរស័ព្ទ គ្រប់ការឆ្លើយឆ្លងគ្នា តាមរយៈមធ្យោបាយទូរគមនាគមន៍ ដូចជា សារតាមទូរស័ព្ទ ឬ សារតាមអិនធើណែត[30] ។ ចៅក្រមស៊ើបសួរអាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការជំនាញ តាំងឧបករណ៍បច្ចេកទេស និង ធ្វើការថត ដោយដីកាសម្រេចដែលមានបញ្ជាក់អំពីប្រភេទទំនាក់ទំនងដើម្បីចាប់ ព្រមទាំងរយៈពេលក្នុងការធ្វើបេសកកម្មផងដែរ។ អង្គភាពសាធារណៈ ឬ មន្ត្រីរាជការដែលត្រូវបានចៅក្រមស៊ើបសួរចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ ហើយក្នុងពេលអនុវត្តបេសកកម្ម ត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ អំពីការប្រព្រឹត្តទៅនៃបេសកកម្មរបស់ខ្លួន និង អំពីការលំបាកបើសិនជាមាន។ នៅពេលបំពេញបេសកកម្មរបស់ខ្លួនរួចរាល់ហើយ អង្គភាពសាធារណៈ ឬ មន្ត្រីរាជការ ត្រូវចម្លងសម្លេងជាលាយលក្ខណ៍អក្សរ ហើយត្រូវប្រគល់ឯកសារ និង សម្លេងដែលបានថតជូនចៅក្រមស៊ើបសួរ និង បិទស្លាក។ ចៅក្រមស៊ើបសួរអាចចុះទៅដល់កន្លែងដែលធ្វើការចាប់ និង ថតសម្លេងនោះ បានគ្រប់ពេលវេលា ទោះបីជាកន្លែងយោធាក៏ដោយ។

### ១.២ ដីកាចាត់ឱ្យស៊ើបសួរជំនួស

នៅក្នុងការបំពេញកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ ការជួបប្រទះនូវឧបសគ្គផ្សេងៗតែងតែកើតមានជារឿយៗដែលអាចបង្ករជាបញ្ហាធ្វើឱ្យចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងបាន ដូច្នេះនៅពេលដែលមានឧបសគ្គរារាំងធ្វើឱ្យចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងបាន ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឱ្យ ចៅក្រមនៃតុលាការរបស់ខ្លួន ឬ ចៅក្រមនៃតុលាការផ្សេងទៀត និង មន្ត្រីនគរបាលយុត្តិធម៌ ឬ អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរជំនួសបាន[31]។

ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ ហើយកិច្ចដែលត្រូវបញ្ជាក់នៅក្នុងដីកានោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលបានចោទប្រកាន់ ពោលគឺដីកាចាត់ឱ្យស៊ើបសួរជំនួសមិនអាចមានលក្ខណៈជាទូទៅទេ ត្រូវណែនាំឱ្យបានច្បាស់លាស់[32]។ ចៅក្រមស៊ើបសួរកំណត់ចិរវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខា និង បោះត្រា ហើយចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេល។

30 មាត្រា១៧២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

31 មាត្រា១៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

32 មាត្រា១៧៤ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

### ១.២.១ ការស៊ើបសួរជំនួសដោយចៅក្រម

បើសិនជាចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងបានដោយមានឧបសគ្គ ឬ មានភាពចាំបាច់ណាមួយបានកើតឡើង ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬ ចៅក្រមនៃតុលាការផ្សេងទៀតដើម្បីបំពេញកិច្ចស៊ើបសួរជំនួសខ្លួនបាន។ ទោះបីជាការផ្ទេរសមត្ថកិច្ចពីចៅក្រមអាសនៈមួយទៅចៅក្រមមួយរូបទៀត ដែលស្ថិតនៅស្ថានប័នដូចគ្នា ឬ ខុសគ្នាក៏ដោយ ក៏ការផ្ទេរអំណាចត្រូវធ្វើទៅតាមដីកាចាត់ឱ្យស៊ើបសួរជំនួសដែរ ហើយដីកាដែលចាត់ឱ្យស៊ើបសួរជំនួសនេះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីកិច្ចដែលត្រូវស៊ើបសួរជំនួសផងដែរ។ ប៉ុន្តែកាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានចេញឱ្យដល់ចៅក្រមណាម្នាក់ ចៅក្រមនេះប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ[33] ដើម្បីបំពេញកិច្ចនីតិវិធីបន្តរ និង ធានាឱ្យបាននូវប្រសិទ្ធិភាពនៃការស៊ើបសួរ។

### ១.២.២ ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានប្រគល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតក្រោមអំណាចចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនតែចៅក្រមដែលបានចេញដីកាឱ្យដល់ខ្លួនតែប៉ុណ្ណោះ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចសួរចម្លើយជនត្រូវចោទ ឬ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានទេ[34]។ អំណាចដែលអាចផ្ទេរឱ្យមន្ត្រីនគរបាលយុត្តិធម៌ គឺមានតែ៖

- **ការស្តាប់ចម្លើយសាក្សី**[35] នៅមុនពេលដែលមន្ត្រីនគរបាលយុត្តិស្តាប់ចម្លើយ សាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួនថានិយាយតែការពិត ប៉ុន្តែត្រូវបានអនុញ្ញាតឱ្យរួចពីសម្បថ ចំពោះសាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ។ ដើម្បីគោរពសិទ្ធិការពារខ្លួន មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលដែលមានតម្រុយពិរុទ្ធភាពបានទេ។ នៅពេលដែលស្តាប់ចម្លើយសាក្សីបានធ្វើឱ្យលេចនូវតម្រុយពិរុទ្ធភាពលើសាក្សីនោះ មន្ត្រីនគរបាលត្រូវបញ្ឈប់ការស្តាប់ចម្លើយ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ។ បុគ្គលដែលត្រូវបានកោះហៅក្នុងឋានៈជាសាក្សីត្រូវតែចូលបង្ហាញខ្លួន ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរដែលអាចចេញបញ្ជាឱ្យសាក្សីចូលខ្លួន ដោយមានចុះអត្តសញ្ញាណនៃសាក្សីនេះ។ បញ្ជារបស់ចៅក្រមស៊ើបសួរនេះអាចឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំសាក្សីឱ្យចូលបង្ហាញខ្លួននៅមុខមន្ត្រីនគរបាលយុត្តិធម៌នេះ។

33 មាត្រា១៧៥ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

34 មាត្រា១៨០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

35 មាត្រា១៧៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- **ការឆែកឆេរ និង ចាប់យកវត្ថុតាង**[36] មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និង ចាប់យកវត្ថុតាងបាន ដោយសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ការឆែកឆេរ ត្រូវធ្វើនៅមុខសាក្សី ២ (ពីរ) នាក់ និង មិនអាចធ្វើឡើងមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និង ក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ លើកលែងតែ ករណីបទឧក្រិដ្ឋ ឬ បទមជ្ឈឹមជាក់ស្តែង ករណីដែលចាត់ទុកជាបទឧក្រិដ្ឋ ឬ បទមជ្ឈឹមជាក់ស្តែង ករណីមានសម្រែកឱ្យជួយពីក្នុងកន្លែង ករណីឆែកឆេរធ្វើនៅកន្លែងដែលបើកចំហដល់សាធាណៈជន និង ករណីឆែកឆេរនៅគ្រប់កន្លែងផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ ទាល់តែមានវត្តមានចៅក្រមស៊ើបសួរទៅជាមួយ ហើយចំពោះការឆែកឆេរកន្លែងសារព័ត៌មានមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើទៅបាន ដោយធានាមិនឱ្យប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និង មិនធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាន។ បន្ទាប់ពីការឆែកឆេរបើសិនជាអាចចាប់យកវត្ថុតាងបានមន្ត្រីនគរបាលយុត្តិបិទស្លាកបោះត្រា និង ត្រូវធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវ[37] ។
- **ការឃាត់ខ្លួន**[38] បទបញ្ញត្តិស្តីពីពីការឃាត់ខ្លួនមាត្រា ៩៦ (កៅសិបប្រាំមួយ) រហូតដល់កំណត់ហេតុសរុបនៃការឃាត់ខ្លួនមាត្រា ១០២ (មួយរយពីរ) ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានយកមកប្រើប្រាស់ដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ ប៉ុន្តែអំណាចទាំងអស់ត្រូវបានប្រគល់ឱ្យចៅក្រមស៊ើបសួរវិញដែលជាម្ចាស់ដីកាចាត់ឱ្យស៊ើបសួរជំនួស។ ចំពោះការអនុវត្តមាត្រា ១០៣ (មួយរយបី) ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន និង មាត្រា ១០៤ (មួយរយបួន) រយៈពេលនៃការឃាត់ខ្លួន ក្រមនីតិវិធីព្រហ្មទណ្ឌ នៅពេលដែលផុតកំណត់នៃការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវនាំជនដែលត្រូវបានឃាត់ខ្លួនទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។
- **ការស្តាប់ទូរស័ព្ទ**[39] កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសបានចែងអំពីការស្តាប់ទូរស័ព្ទ និង ការថតការសន្ទនាតាមទូរស័ព្ទ ឬ ការចាប់ និង ការថតគ្រប់ការឆ្លងឆ្លើយគ្នាតាមមធ្យោបាយ

36 មាត្រា១៨១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
37 មាត្រា៩២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
38 មាត្រា១៨២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
39 មាត្រា១៨៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ទូរគមនាគមន៍ ដូចជាសារតាមទូរស័ព្ទ ឬ សារតាមអិនធើណែត មន្ត្រីនគរបាលយុត្តិធម៌អាចប្រើប្រាស់អំណាចដែលប្រគល់ឱ្យចៅក្រមស៊ើបសួរបាន ដោយស្នើសុំដល់អង្គភាពសាធារណៈ និង មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និង ធ្វើការថត។

## ផ្នែកទី២ អំណាចបង្ខំរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ បានដើរតួរយ៉ាងសំខាន់នៅក្នុងការស្វែងរកការពិតមុននឹងឈានដល់ការសម្រេចក្តីថា ជនម្នាក់មានទោស ឬ គ្មានទោស។ ដោយសារតែបែបនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចដល់ចៅក្រមស៊ើបសួរក្នុងការអនុវត្តនីតិវិធីរបស់ខ្លួន ដើម្បីធានាឱ្យបាននូវប្រសិទ្ធិភាពរបស់ចៅក្រមស៊ើបសួរ ក៏ដូចជាធានាដល់ដំណើរការនៃរឿងក្តីព្រហ្មទណ្ឌទាំងមូល។ ដើម្បីសិក្សាស្វែងយល់អំពី អំណាចបង្ខំរបស់ចៅក្រមស៊ើបសួរនេះ សូមធ្វើការបែងចែកជា ៣ ចំណុចៈ

- ចំណុច ២.១ វិធានការនិរន្តរាយ
- ចំណុច ២.២ ការរក្សាជនត្រូវចោទឱ្យនៅក្រោមការចាត់ចែងរបស់តុលាការ។

### ២.១ វិធានការនិរន្តរាយ

កាលណាចៅក្រមស៊ើបសួរ បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរព្រះរាជអាជ្ញារួចហើយចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការបើកការស៊ើបសួរ ឬ មានសិទ្ធិធ្វើចំណាត់ការនីតិវិធីស៊ើបសួរបាន។ នេះជាវិធានការដ៏សំខាន់ និង ចាំបាច់មួយក្នុងចំណោមវិធានការដ៏ទៃផ្សេងទៀត ដែលប៉ះពាល់ខ្លាំងដល់ជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាព ដែលចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការប្រើវិធានការនេះទៅលើបុគ្គលទាំងអស់នោះ។ វិធានការនិរន្តរាយ សំដៅដល់វិធានការទប់ស្កាត់ដើម្បីជៀសវាងផលប៉ះពាល់ ឬ ធានាដំណើរការនៃនីតិវិធីឱ្យសម្រេចបាននូវគោលដៅស្វែងរកការពិតឱ្យបានរលូតប្រសើរ ។ នៅក្នុងវិធានការនេះចៅក្រមស៊ើបសួរ អាចចេញដីកាផ្សេងៗទៅតាមស្ថានភាពជាក់ស្តែងចាំបាច់ ឬ ទៅតាមគោលដៅចង់បានរបស់ចៅក្រមស៊ើបសួរ ដោយដីកាទាំងនោះរួមមាន ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និង ដីកាបង្គាប់ឱ្យឃុំខ្លួន[40]។

40 មាត្រា១៨៥ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

### ១.១.១ ដីកាបង្គាប់ឱ្យចូលខ្លួន

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន[41]។ ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាដីកាដែលបញ្ជាដល់បុគ្គលម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យចូលខ្លួននេះ អាចចេញទៅលើជនត្រូវចោទ ឬ ទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ជាទូទៅដីកានេះប្រើនៅពេលដែលជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាព មិនរត់គេចខ្លួន និង ត្រូវបានគេដឹងពីទីកន្លែងរបស់គាត់ ហើយជាការផ្តល់ឧកាស ឬ សេរីភាពឱ្យក្នុងការចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរដោយស្ម័គ្រចិត្ត ឬ តាមសម្រួលដោយមិនចាំបាច់មានការបង្ខិតបង្ខំ។ ដីកាបង្គាប់ឱ្យចូលខ្លួន មាននិទ្ទេសដូចតទៅ[42]៖

- អត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និង អត្ថបទច្បាប់ដែលកំណត់ និង បង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និង ទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និង ឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យចូលខ្លួននេះត្រូវមានចុះកាលបរិច្ឆេទ ហត្ថលេខារបស់ចៅក្រមស៊ើបសួរ និង បោះត្រា។

ដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ ដោយអាជ្ញាសាលា។ នៅពេលដែលបុគ្គលដែពាក់ព័ន្ធទទួលចុងដីកា ត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ។ គ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ អាជ្ញាសាលាត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យចូលខ្លួនពុំមានតម្លៃបង្ខំទេ ហេតុដូចនេះហើយការបដិសេធមិនព្រមចូលបង្ហាញខ្លួនរបស់ជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាពគ្មានមូលហេតុត្រឹមត្រូវ នាំឱ្យចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យនាំខ្លួន។ ប៉ុន្តែបើសិនជាជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាពមិនបានចូលបង្ហាញខ្លួនដោយមានមូលហេតុត្រឹមត្រូវ ឬ សមស្របអាចទទួលយកបាន ចៅក្រមស៊ើបសួរក៏អាចពន្យាពេលឱ្យចូលខ្លួនបានផងដែរ ហើយជាទូទៅដីកាបង្គាប់ឱ្យចូលខ្លួននេះ អាចត្រូវបានចេញជាលើកទី ២ (ពីរ) ឬ ទី ៣ (បី) ។

### ១.១.២ ដីកាបង្គាប់ឱ្យនាំខ្លួន

នៅពេលដែលចៅក្រមស៊ើបសួរ បានចេញដីកាបង្គាប់ឱ្យចូលខ្លួនរួចហើយ ជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាពមិនព្រមចូលមកបង្ហាញខ្លួន ហើយជននោះមិនរត់គេចខ្លួន ពោលគឺចៅក្រមស៊ើប

41 មាត្រា១៨៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

42 មាត្រា១៨៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

សួរបានដឹងអំពីកន្លែងដែលជននោះកំពុងស្ថិតនៅពិតប្រាកដ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួន[43] ដើម្បីនាំជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាពមកសួរចម្លើយ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់នូវលក្ខខ័ណ្ឌផ្សេងទៀត ដើម្បីឱ្យចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួនទេ ដូច្នេះចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យនាំខ្លួនបានដោយមិនចាំបាច់ចេញដីកាបង្គាប់ឱ្យចូលខ្លួនទេ បើចៅក្រមស៊ើបសួរយល់ថាជាការចាំបាច់។ ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និង នាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ[44]។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬ ទៅលើបុគ្គលម្នាក់ដែលមានតម្រុយពិរុទ្ធភាពតែប៉ុណ្ណោះ។ ដីកាបង្គាប់ឱ្យនាំខ្លួន មាននិទ្ទេសដូចតទៅ[45]៖

- អត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ អត្ថបទច្បាប់ដែលកំណត់ និង បង្ក្រាបបទល្មើសនេះ
- ឈ្មោះ និង ឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ព្រមទាំងបោះត្រាផង។

ការអនុវត្តត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកានេះត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានេះ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និង ក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ[46]។ នៅពេលដែលមិនអាចនាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរបាន ដោយព្រោះមានមូលហេតុនៃកាលៈទេសៈ មន្ត្រីនគរបាលយុត្តិធម៌ដែលកំពុងអនុវត្តបេសកកម្មរបស់ខ្លួនត្រូវនាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅក្នុងអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ក្នុងមណ្ឌលឃុំខ្លួន ឬ ទៅក្នុងពន្ធធនាគារ ហើយយ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់ត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ ឬ ដល់អ្នកជំនួស។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលដែលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ[47]។ គួរបញ្ជាក់ផងដែរថានៅពេលដែលជនដែលពាក់ព័ន្ធត្រូវបានបញ្ជូនខ្លួនដល់ចៅក្រមស៊ើបសួររួចហើយ

43 មាត្រា១៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
44 មាត្រា១៩០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
45 មាត្រា១៩១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
46 មាត្រា១៩២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
47 មាត្រា១៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ចៅក្រមស៊ើបសួរធ្វើការសួរចម្លើយ និង អាចឃុំខ្លួនជននោះបានដើម្បីធានាដល់ដំណើរការនៃការស៊ើបសួរស្វែងរកការពិត ឬ ធានាឱ្យបាននូវវត្តមានរបស់ជននោះនៅចំពោះមុខតុលាការ ហើយថិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើមាន[48]។

### ១.១.៣ ដីកាបង្គាប់ឱ្យចាប់ខ្លួន

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន[49]។ ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចត្រូវបានចេញទៅលើជនត្រូវចោទ ឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[50]។ ពោលគឺ ដីកាបង្គាប់ឱ្យចាប់ខ្លួននេះ ជាបញ្ជារបស់ចៅក្រមស៊ើបសួរដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និង ឱ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ព្រមទាំងជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួល និង ឃុំខ្លួនបុគ្គលនោះ។ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបានលុះត្រាតែបំពេញលក្ខខ័ណ្ឌដូចខាងក្រោម៖

- បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ
- បុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬ ស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញា និង ត្រូវចេញដីកានេះដោយមានថែងមូលហេតុ ក្រោយពីទទួលបានយោបល់ពីព្រះរាជអាជ្ញា។ ដោយយោងតាមមូលហេតុថាព្រះរាជអាជ្ញាគឺជាម្ចាស់នៃបណ្តឹងអាជ្ញា ប៉ុន្តែចៅក្រមស៊ើបសួរមិនស្ថិតក្រោមការអនុវត្តតាមយោបល់របស់ព្រះរាជអាជ្ញាទាំងស្រុងនោះទេ ពោលគឺចៅក្រមស៊ើបសួរអាចចេញដីកាបានដោយខ្លួនឯង បើខ្លួនយល់ឃើញថាចាំបាច់ត្រូវតែចេញដីកាបង្គាប់ឱ្យចាប់ខ្លួននេះ ដើម្បីធានាដល់ការស៊ើបសួរស្វែងរកការពិតឱ្យប្រព្រឹត្តទៅដោយមានសំអាងហេតុត្រឹមត្រូវ។ ព្រះរាជអាជ្ញា ធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន[51]។ ដីកាបង្គាប់ឱ្យចាប់ខ្លួនមាននិទ្ទេសដូចតទៅ[52]៖

- អត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ អត្ថបទច្បាប់ដែលកំណត់ និង បង្ក្រាបបទល្មើសនេះ

48 មាត្រា១៩៤ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
49 មាត្រា១៩៥ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
50 មាត្រា១៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
51 មាត្រា១៩៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
52 មាត្រា១៩៨ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

– ឈ្មោះ និង ឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ព្រមទាំងបោះត្រាផង។

ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌[53]។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ តាមគ្រប់មធ្យោបាយ។ ដើមដីកា ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកាក្នុងរយៈពេលយ៉ាងខ្លីបំផុត។ សិទ្ធិលំនៅឋានត្រូវបានគោរព ដោយមន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និង ក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ។ ក្នុងករណីចាំបាច់ដីកាបង្គាប់ឱ្យចាប់ខ្លួន អាចត្រូវបានផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើប្រាស់យន្តការនានាដែលមានប្រសិទ្ធភាព[54]។

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ត្រូវតែទទួល និង ឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួន[55]។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនរក្សាទុកដើមដីកា ឬ ចុងដីកាដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់។ បុគ្គលដែលពាក់ព័ន្ធនឹងត្រូវបាននាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួស ក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតនៅដំណាក់កាលស៊ើបសួរនៅឡើយ។ បើសិនជាការនាំខ្លួននេះតម្រូវឱ្យមានការផ្ទេរបុគ្គលដែលពាក់ព័ន្ធទៅពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនផ្សេង ការផ្ទេរនេះត្រូវចាត់ចែងដោយព្រះរាជអាជ្ញា។ ក្នុងករណីដែលជនដែលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ពីចាប់ខ្លួនទេ បុគ្គលនោះនឹងត្រូវបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ ហើយព្រះរាជអាជ្ញាត្រូវធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយ រួចត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។ ការឃុំខ្លួនដោយដីកាបង្គាប់ឱ្យចាប់ខ្លួន ចិរវេលានេះត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន[56]។

53 មាត្រា១៩៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
54 មាត្រា២០០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
55 មាត្រា២០១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
56 មាត្រា២០២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

### **១.១.៣ ដីកាបង្គាប់ឱ្យឃុំខ្លួន**

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យឃុំខ្លួន[57]។ ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួល និង ឃុំខ្លួនជនត្រូវចោទ[58]។ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន ពោលគឺចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបានទេ ទាល់តែចៅក្រមស៊ើបសួរបានចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទជាមុនសិន។ ដីកាបង្គាប់ឱ្យឃុំខ្លួនមានចុះនិទ្ទេសដូចតទៅ[59]៖

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- បទល្មើសដែលចោទប្រកាន់ អត្ថបទច្បាប់ដែលកំណត់ និង បង្ក្រាបបទល្មើសនេះ
- ឈ្មោះ និង ឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឱ្យឃុំខ្លួន ត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ព្រមទាំងបោះត្រាផង។

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវតែទទួល និង ឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួន រហូតទាល់តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវរក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬ ចុងដីកាដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។

### **២.២ ការរក្សាជនត្រូវចោទឱ្យនៅក្រោមការចាត់ចែងរបស់តុលាការ**

ការរក្សាជនត្រូវចោទឱ្យស្ថិតនៅក្រោមការចាត់ចែងរបស់តុលាការ គឺជាវិធានការមួយដែលចៅក្រមស៊ើបសួរអាចប្រើប្រាស់ដើម្បីធានាឱ្យបាននូវវត្តមានជនត្រូវចោទនៅចំពោះមុខតុលាការ ឬ ចៅក្រមស៊ើបសួរនៅគ្រប់ពេលដែលនីតិវិធីត្រូវការ និង បង្ការនូវការប្រព្រឹត្តបទល្មើសជាថ្មី ឬ បង្ករជាឧបសគ្គដល់ការស្រាវជ្រាវរកការពិតនៃសំណុំរឿង។ នៅក្នុងការរក្សាជនត្រូវចោទឱ្យស្ថិតនៅក្រោមការចាត់ចែងរបស់តុលាការ ចៅក្រមស៊ើបសួរមានវិធានការ ២ (ពីរ) គឺ៖ ការឃុំខ្លួនបណ្ដោះអាសន្ន និង ការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ ការមិនឃុំខ្លួនបណ្ដោះអាសន្ន។ ចៅក្រមស៊ើបសួរ ត្រូវគោរពទៅតាមបញ្ញត្តិច្បាប់ ដែលធ្វើឡើងតាមរយៈដីកាសម្រេចដោយមានសំអាងហេតុ និង សំអាងច្បាប់ត្រឹមត្រូវចំពោះការសម្រេចចេញដីកាឃុំខ្លួនបណ្ដោះអាសន្ន ហើយ

57 មាត្រា២១៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

58 មាត្រា២២០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

59 មាត្រា២២១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ចំពោះការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ ការសម្រេចចេញដីកាមិនឃុំខ្លួនបណ្តោះអាសន្ន មិនចាំបាច់មានសំអាងហេតុទេ។

### ២.២.១ ការឃុំខ្លួនបណ្តោះអាសន្ន

ជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព[60]។ សេរីភាពជាផ្នែកមួយយ៉ាងសំខាន់របស់មនុស្សគ្រប់រូប និងជាសិទ្ធិមូលដ្ឋានរបស់ពលរដ្ឋ ទោះបីបុគ្គលនោះជាជនត្រូវចោទក៏ដោយ ព្រោះតែការឃុំខ្លួនធ្វើឱ្យបាត់បង់នូវសេរីភាព និង ប៉ះពាល់ដល់កិត្តិយល និង សេចក្តីថ្លៃថ្នូររបស់ជនត្រូវចោទ។ ប៉ុន្តែនៅក្នុងករណីពិសេសចៅក្រមស៊ើបសួរក៏អាចសម្រេចចេញដីកាឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទបានផងដែរ។ ការសម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្ន អាចជាគំនិតរបស់ចៅក្រមស៊ើបសួរផ្ទាល់ និង អាចជាសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ ការសម្រេចនេះត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និង កត់សម្គាល់មធ្យោបាយការពារខ្លួនរបស់ជនត្រូវចោទ ឬ មេធាវី បើសិនជាជនត្រូវចោទមានមេធាវី។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្ន តាមរយៈដីកាដោយមានសំអាងហេតុ និង យោងតាមមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន។ ក្នុងការអនុវត្តចៅក្រមស៊ើបសួរចេញដីកាដីកាឃុំខ្លួនបណ្តោះអាសន្ន និង ដីកាបង្គាប់ឱ្យឃុំខ្លួនដើម្បីអនុវត្តការឃុំខ្លួនបណ្តោះអាសន្ននេះ។

#### ក លក្ខខ័ណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខ្លាំងមែនទែន ទោះបីបុគ្គលនោះមានឋានៈជាជនត្រូវចោទក៏ដោយ ក៏ត្រូវតែគោរពសិទ្ធិសេរីភាពរបស់គាត់ដែរ។ ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ[61] ពោលគឺដរាបណាសាលក្រមស្ថាពររបស់តុលាការមិនទាន់ចេញទៅលើជនត្រូវចោទទេ គាត់មិនទាន់ក្លាយជាមនុស្សមានទោសទេ។ ដូច្នេះហើយមុននឹងអាចឃុំខ្លួនជនត្រូវចោទបានក្រមនីតិវិធីព្រហ្មទណ្ឌមានលក្ខខ័ណ្ឌច្បាស់លាស់ដើម្បីធានានូវតម្លាភាពនៃការអនុវត្ត ដែលការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម[62] ពោលគឺការឃុំខ្លួនបណ្តោះអាសន្នមិនអាចធ្វើឡើងបានឡើយក្នុងការចោទប្រកាន់ពីបទលហុ។ ការចោទប្រកាន់នេះ គឺសំដៅដល់ការចោទប្រកាន់របស់ព្រះរាជអាជ្ញាតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលព្រះរាជអាជ្ញាបានកំណត់បទចោទប្រកាន់ទៅលើជនត្រូវចោទនោះ។ ម្យ៉ាងវិញទៀតការឃុំ

60 មាត្រា២០៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
61 មាត្រា៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
62 មាត្រា២០៤ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ខ្លួនបណ្ដោះអាសន្នអាចធ្វើទៅបានតែក្នុងករណីច្បាប់បានកំណត់ផ្ដន្ទាទោសស្មើ ឬ លើសពី ១ (មួយ) ឆ្នាំ ប៉ុណ្ណោះ វាលក្ខខ័ណ្ឌដែលត្រូវគោរពជាដាច់ខាត ចៅក្រមស៊ើបសួរមិនអាចចេញដីកាឃុំខ្លួនបណ្ដោះអាសន្ន ទៅលើជនត្រូវចោទ ដែលច្បាប់បានកំណត់ទោសដាក់ពន្ធនាគាតិចជាង ១ (មួយ) ឆ្នាំបានទេ។ ឧទាហរណ៍ ជនត្រូវចោទបានប្រព្រឹត្ត បទញុះញង់ឱ្យបោះបង់ទារក ដែលក្រមព្រហ្មទណ្ឌមាត្រា ៣៣០ (បីរយសាមសិប) បានកំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ ដូច្នេះការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចអនុវត្តបានទេចំពោះបទល្មើសមួយនេះ។ ចំពោះអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវ ឃុំខ្លួនបណ្ដោះអាសន្នទេ[63]។ អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលប្រព្រឹត្តបទល្មើសមិនត្រូវ ទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប៉ុន្តែក្នុងករណីខ្លះព្រះរាជអាជ្ញាដាក់ពាក្យបណ្ដឹងមកចៅក្រមស៊ើបសួរ ឱ្យ បើកការស៊ើបសួរដោយព្រោះព្រះរាជអាជ្ញាមិនអាចវិន័យច្ឆ័យពីអាយុរបស់ជនសង្ស័យបាន ដូច្នេះនៅពេល ដែលចៅក្រមស៊ើបសួរបានបើកការស៊ើបសួរឃើញថាជនត្រូវចោទគឺជា អនីតិជនក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរនឹងសម្រេចលើកលែងការចោទប្រកាន់ដោយដីកាលើកលែងការចោទប្រកាន់ និង មានភស្តុ តាងគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីនត្តិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ។

### ខ មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន

ដើម្បីអាចអនុវត្តការឃុំខ្លួនបណ្ដោះអាសន្នបាន ចៅក្រមស៊ើបសួរត្រូវអនុវត្តនីតិវិធីនេះដោយផ្អែកលើ មូលហេតុចំនួន ៦ (ប្រាំមួយ) ដូចខាងក្រោម[64]៖

- **ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី៖** នៅពេលមានបទល្មើសមួយកើត ឡើង បទល្មើសខ្លះបង្កជាព្យសនកម្មតិចតួចដល់ជនរងគ្រោះ និង សង្គម ប៉ុន្តែបទល្មើសខ្លះ ទៀតបង្កើតបានជាព្យសនកម្មធំធេង ឬ ធ្ងន់ធ្ងរខ្លាំង។ ដូច្នេះក្នុងករណីដែលជនត្រូវចោទនៅ បន្តរមានសេរីភាព ឬ នៅក្រៅឃុំ ជនត្រូវចោទអាចបង្កជាព្យសនកម្មបន្ថែមទៀត ឬ បង្កើត ជាបទល្មើសថ្មីបន្ថែមទៀត។
- **ដើម្បីរារាំងកុំឱ្យមានការគៀបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការ ត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និង អ្នកសមគំនិត៖** ជនត្រូវចោទដែលនៅក្រៅឃុំ ឬ មានសេរី ភាព អាចជាឧកាសក្នុងការគំរាមកំហែងដល់សាក្សី ឬ ជនរងគ្រោះ ក្នុងការមិនឱ្យនិយាយ អំពីការពិតគ្រប់យ៉ាង ឬ ផ្នែកណាមួយដែលខ្លួនបានប្រព្រឹត្តដល់ជនរងគ្រោះនៅចំពោះមុខ

---

63 មាត្រា២១២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

64 មាត្រា២០៥ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

តុលាការ។ ចំណែកឯជនត្រូវចោទ និង អ្នកសមគំនិត ក៏មានឱកាសក្នុងការត្រូវរ៉ូវគ្នា ដើម្បីបង្ករជាឧបសគ្គក្នុងការស្វែងរកការពិតរបស់ចៅក្រមស៊ើបសួរ ដោយបំផ្លាញភស្តុតាង ឬ ដោយវិធីផ្សេងដើម្បីបញ្ចៀសកុំឱ្យការពិតត្រូវបានលាតត្រដាង។

– **ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ៖** ភស្តុតាង ឬ តម្រុយជាសម្ភារៈ ពិតជាសំខាន់ក្នុងការអនុវត្តនិតិវិធីរបស់ចៅក្រមស៊ើបសួរដើម្បីបើកបង្ហាញនូវការពិតអំពីអង្គហេតុពិតប្រាកដនៃបទល្មើសមួយ។ នៅពេលដែលភស្តុតាង ឬ តម្រុយសម្ភារៈផ្សេងៗត្រូវបានបាត់បង់ឧបសគ្គនៃការស៊ើបសួរស្វែងរកការពិតកាន់តែកើនឡើងទ្វេដង ជាហេតុមួយដែលធ្វើឱ្យចៅក្រមស៊ើបសួរចាំបាច់ត្រូវឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ ដើម្បីធានានូវប្រសិទ្ធភាព និង ភាពងាយស្រួលក្នុងការស្រាវជ្រាវរបស់ខ្លួន និង ការពារកុំឱ្យជនត្រូវចោទមានឱកាសដើម្បីបំផ្លាញភស្តុតា ឬ តម្រុយសម្ភារៈផ្សេងៗ។

– **ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី៖** ជាទូទៅជនត្រូវចោទមិនចង់ទទួលខុសត្រូវចំពោះបទល្មើសរបស់ខ្លួនឡើយ ហើយតែងតែឃើញថាពួកគាត់តែងតែព្យាយាមរត់គេចចេញពីសំណាញ់ច្បាប់។ ដូច្នេះដើម្បីងាយស្រួលក្នុងការអនុវត្តនីតិវិធីរបស់តុលាការ និង ធានាជនត្រូវចោទឱ្យបាននៅចំពោះមុខតុលាការ ទៅតាមកាលបរិច្ឆេទដែលបានកំណត់តាមពេលវេលានីមួយៗ ការឃុំខ្លួនបណ្ដោះអាសន្នជាជម្រើសមួយដែលងាយស្រួល និង ធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្ត។

– **ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ៖** នៅពេលដែលបទល្មើសបានកើត និង បានបង្ករជាព្យសនកម្ម ជនរងគ្រោះ ក្រុមគ្រួសារ សាច់ញាតិ ឬ មិត្តភ័ក្រ របស់ជនរងគ្រោះប្រាកដជាមានការឈឺចាប់ និង មិនសុខចិត្តចំពោះទង្វើលរបស់ជនត្រូវចោទទេ ជាហេតុអាចបង្កើតឱ្យមានការខឹងសម្បារ ចងគំនុំ និង សងសឹកទៅលើជនត្រូវចោទ ឬ បង្ករជាបទល្មើសទៅលើជនត្រូវចោទ ដែលនាំឱ្យសង្គមមានភាពអនាធិបតេយ្យ និង គ្មានរបៀបរៀបរយ។ ច្បាប់មិនបានគាំទ្រដល់ការសងសឹងទេ ដូចនេះដើម្បីអនុវត្តទៅនីតិវិធីច្បាប់ ចៅក្រមស៊ើបសួរអនុវត្តការឃុំខ្លួនបណ្ដោះអាសន្ននេះក្នុងការបញ្ចៀសកុំឱ្យកើតមានបទល្មើសថែមទៀត និង ការពារជនត្រូវចោទ។

- **ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាល់មកពីបទល្មើស៖** បទល្មើសព្រហ្មទណ្ឌមិនត្រឹមតែបង្ករជាព្យសនកម្មដល់ជនរងគ្រោះប៉ុណ្ណោះទេ គឺបានបង្ករជាព្យសនកម្មដល់សង្គម និង មនុស្សក្នុងសង្គមទៀតផង។

ជារួមមកនៅពេលដែលចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ និង ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និង ជនត្រូវចោទ។

### គ នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្ន គឺជាការសម្រេចរបស់ចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរអាចសម្រេចចេញដីកាឃុំខ្លួនបណ្តោះអាសន្នដោយឯកឯង ឬ ដោយមានសេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញាសុំឱ្យឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ។ មុននឹងចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា និង ឱ្យដំណឹងដល់ជនត្រូវចោទ ព្រមទាំងទទួលការកត់សម្គាល់ពីជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ ក្នុងករណីដែលជនត្រូវចោទមានមេធាវី អំពីមធ្យោបាយការពារខ្លួនទៅលើបញ្ហាឃុំខ្លួនបណ្តោះអាសន្នមកលើខ្លួន ឬ កូនក្តីរបស់ខ្លួន ការកត់សម្គាល់ ឬ សេចក្តីសន្និដ្ឋាននេះត្រូវបានកត់ចុះក្នុងកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ[65] ដែលជាមូលដ្ឋានឱ្យចៅក្រមស៊ើបសួរសម្រេចថា គួរឃុំខ្លួនបណ្តោះអាសន្ន ឬ មិនឃុំខ្លួនបណ្តោះអាសន្ន។ នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រូវមានសម្អាងហេតុ និង មូលហេតុនៅក្នុងមាត្រា ២០៥ (ពីរយប្រាំ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ឃ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នត្រូវបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រែប្រួលទៅតាមស្ថានភាពអាយុរបស់ជនត្រូវចោទជា នីតិជន ឬ អនីតិជន និង ប្រែប្រួលទៅតាមប្រភេទនៃបទល្មើសគឺ បទឧក្រិដ្ឋ និង បទមជ្ឈិម។ ដើម្បីជាការងាយស្រួលក្នុងការស្វែងយល់សូមបែងចែកជាករណីដូចខាងក្រោម៖

- **ករណីនៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ និង បទឧក្រិដ្ឋសង្គ្រាម[66]៖** ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួន

65 នីតិវិធីព្រហ្មទណ្ឌ ទំព័រ៣៩ រៀបរៀងដោយ៖ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត
66 មាត្រា២១០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

បណ្ដោះអាសន្នម្ដងបាន ១ (មួយ) ឆ្នាំដោយដីកាមានសម្អាងហេតុត្រឹមត្រូវ និង ច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្ដោះអាសន្ននេះបានតែ ២ (ពីរ) ដងគត់។

- **ករណីនីតិជនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ**[67]៖ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ។ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរក៏អាចពន្យាពេលបាន ៦ (ប្រាំមួយ) ខែម្ដងដោយដីកាដែលមានសម្អាងហេតុត្រឹមត្រូវ និង ច្បាស់លាស់។ ការសម្រេចពន្យាពេលឃុំខ្លួនបណ្ដោះអាសន្ននេះ ចៅក្រមស៊ើបសួរអាចធ្វើបានតែ ២ (ពីរ) ដងប៉ុណ្ណោះ។
- **ករណីនីតិជនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិម**[68] ៖ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ។ ប៉ុន្តែ នៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នបានតែម្ដងគត់មិនឱ្យលើស ២ (ពីរ) ខែដោយដីកាមានសម្អាងហេតុត្រឹមត្រូវ និង ច្បាស់លាស់។ ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។ ឧទាហរណ៍ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឆបោក តាមរយៈក្រមព្រហ្មទណ្ឌឆ្នាំ២០០៧ បទឆបោកត្រូវបានផ្ដន្ទាទោសតាមមាត្រា ៣៧៨ (បីរយចិតសិបប្រាំបី) គឺទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ។ អប្បបរមានៃទោសគឺ ៦ (ប្រាំមួយ) ខែ ដូច្នេះមានន័យថាការឃុំខ្លួនបណ្ដោះអាសន្នមិនត្រូវលើស ៣ (បី) ខែទេ។
- **ការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋទៅលើអនីតិជនអាយុចាប់ ១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ**[69]៖ ក្នុងករណីនេះក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ចែកជា ២ (ពីរ) គឺ ទី១ អនីតិជនអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើពី ៦ (ប្រាំមួយ) ខែ បានទេ។ ទី២ អនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ។
- **ការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិមលើអនីតិជនអាយុចាប់ ១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ**[70]៖ ករណីនេះអាយុរបស់អនីតជនក៏ជាចំណុចសំខាន់ដែលដោយ ទី១ ការឃុំខ្លួន

67 មាត្រា២០៨ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
68 មាត្រា២០៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
69 មាត្រា២១៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
70 មាត្រា២១៤ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

បណ្តោះអាសន្នមិនអាចលើសពពី ២ (ពីរ) ខែបានទេកាលណាអនីតិជនមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។ ទី២ ការឃុំខ្លួនបណ្តោះអាសន្នមិនលើស ៤ (បួន) ខែបានទេ កាលណាអនីតិជនមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

ចិរវេលានៃឃុំខ្លួនបណ្តោះអាសន្ននេះទៅលើអនីតិជនដែលប្រព្រឹត្តបទមជ្ឈឹមនេះ មិនត្រូវលើសពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ពោល អនីតិជនដែលមានទោសជាប់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល[71] ។ ឧទាហរណ៍ អនីតិជនបានប្រព្រឹត្តបទលួច តាមក្រមព្រហ្មទណ្ឌកម្ពុជាត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ៣ (បី) ឆ្នាំ។ អប្បបរមានៃទោសគឺ ៦ (ប្រាំមួយ) ខែ ហេតុនេះពាក់កណ្តាលនៃអប្បបរមាសម្រាប់អនីតិជនគឺ ៣ (បី) ខែ និង ករណីដែលចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនមិនត្រូវលើស ៣ (បី) ខែទេ។

### ខ ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ

កាលណាចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា និង ដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន[72]។ ប្រសិនបើព្រះរាជអាជ្ញាមិនយល់ព្រម ជនត្រូវចោទត្រូវរក្សាទុកក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនសិន រង់ចាំការសម្រេចពីសភាស៊ើបសួរអំពីបណ្តឹងឧទ្ធរណ៍ដែលព្រះរាជអាជ្ញាបានប្តឹង ប៉ុន្តែបើព្រះរាជអាជ្ញាយល់ព្រម ជនត្រូវចោទត្រូវបានដោះលែងភ្លាម។ ការដោះលែងជនត្រូវចោទដែលកំពុងជាប់ឃុំបណ្តោះអាសន្នឱ្យនៅក្រៅឃុំ ឬ ឱ្យមានសេរីភាពវិញ អាចត្រូវបានផ្តើមឡើងដោយ ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា និង ជនត្រូវចោទ។

- **ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយឆន្ទានុសិទ្ធិចៅក្រមស៊ើបសួរ៖** ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទ ឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា[73]។ នៅពេលដែលចៅក្រមស៊ើបសួរមានបំណងចង់ដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បី សុំយោបល់ពីព្រះរាជអាជ្ញា និង បញ្ជូនសំណុំរឿងឱ្យព្រះរាជាពិនិត្យជាមុនសិន។ ការជូនព័ត៌មាននេះត្រូវធ្វើឡើងដោយ ដីកាបញ្ជូនឱ្យឆ្លើយ[74] ហើយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ឆ្លើយតបក្នុងរយៈពេលយ៉ាងខ្លីបំផុ

71 មាត្រា១៦០ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

72 មាត្រា២១៨ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

73 មាត្រា២១៥ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

74 នីតិវិធីព្រហ្មទណ្ឌ ទំព័រ៤០ រៀបរៀងដោយ៖ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត

ត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ជាធម្មតាចៅក្រមស៊ើបសួររងចាំយោបល់ពីព្រះរាជអាជ្ញាសិនមុននឹងសម្រេចដោះលែងជនត្រូវចោទដែលកំពុងនៅក្នុងឃុំ ប៉ុន្តែក្នុងករណីពិសេស ឬបន្ទាន់ ចៅក្រមស៊ើបសួរអាចសម្រេចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនចាំបាច់រង់ចាំយោបល់ពីព្រះរាជអាជ្ញាទេ តែនៅក្នុងដីកាសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំរបស់ខ្លួន ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ។ ឧទាហរណ៍ ជនត្រូវចោទ មានជំងឺធ្ងន់ធ្ងរ ត្រូវបញ្ជូនទៅមន្ទីរពេទ្យជាបន្ទាន់ ក្នុងករណីនេះបើសិនជាចាំការឆ្លើយតបពីព្រះរាជអាជ្ញា ជនត្រូវចោទនឹងមានគ្រោះថ្នាក់ដល់ជីវិត ដូច្នេះចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដោយមិនចាំបាច់រងចាំការយោបល់ពីព្រះរាជអាជ្ញាទេ ដោយគ្រាន់តែបញ្ជាក់ពីមូលហេតុបន្ទាន់នេះនៅក្នុងដីកាបស់ខ្លួន។

- **ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា៖** ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា[75]។ ការប្ដឹងសុំនេះព្រះរាជអាជ្ញាសុំទៅចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនព្រមដោះលែងតាមបណ្ដឹងរបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរត្រូវចេញសេចក្ដីសម្រេចដោយមានសម្អាងហេតុ។ ប៉ុន្តែប្រសិនបើផុតរយៈពេល ៥ (ប្រាំ) ថ្ងៃ ហើយចៅក្រមស៊ើបសួរមិនបានចេញសេចក្ដីសម្រេចទេ ព្រះរាជអាជ្ញាអាចប្ដឹងទៅសភាស៊ើបសួរឱ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។
- **ការដោះលែងឱ្យនៅក្រៅឃុំតាមបណ្ដឹងរបស់ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ៖** ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា[76] ហើយការដាក់ពាក្យសុំនេះអាចធ្វើឡើងដោយមេធាវីរបស់ខ្លួនបានផងដែរ។ ចៅក្រមស៊ើបសួរបន្ទាប់ពីបានទទួលពាក្យសុំរបស់ជនត្រូវចោទហើយ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងភ្លាមទៅព្រះរាជអាជ្ញា និង បញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ និង ផ្ដល់យោបល់ ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុតក្រោយពីបានទទួលដំណឹង និង សំណុំរឿងពីចៅក្រមស៊ើបសួរ។ នៅពេលដែលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញារួចហើយ ចៅក្រមស៊ើប

75 មាត្រា២១៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

76 មាត្រា២១៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ស្នួរត្រូវសម្រេចយ៉ាងយូរបំផុត ៥ (ប្រាំ) ថ្ងៃ អំពីពាក្យសុំឱ្យដោះលែងនៅក្រៅឃុំរបស់ជនត្រូវចោទ។ ក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន ជនត្រូវចោទអាចដាក់ពាក្យសុំសាជាថ្មីទៅចៅក្រមស៊ើបសួរ ដើម្បីសុំការសម្រេចដោះលែងឱ្យនៅក្រៅឃុំ ដោយចៅក្រមស៊ើបសួរ ត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីមានពាក្យសុំរបស់ជនត្រូវចោទ។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចបដិសេធមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ឬ មិនបានសម្រេចទេ ជនត្រូវចោទអាចដាក់ពាក្យសុំទៅសភាស៊ើបសួរផ្ទាល់ដើម្បីសុំការសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកាដែលបដិសេធមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ។

ការសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ម្យ៉ាងវិញទៀត កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរអាចសម្រេចដាក់ជននោះឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

### ២.២.២ ការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ឬ បានសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរអាចសម្រេចជ្រើសរើសយក ការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលវាគឺជាការគឺការកំណត់នូវសេរិភាពរបស់ជនត្រូវចោទដែលនៅខាងក្រៅឃុំ ដោយចងជាកាតព្វកិច្ច ឬ ការហាមឃាត់មួយចំនួន។ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូចោទនេះត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពោលគឺចៅក្រមស៊ើបសួរមិនអាចដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ បើជនត្រូវចោទមិនត្រូវបានព្រះរាជអាជ្ញាចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ ចំណែកឯអនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ[77]។

ការសម្រេចដាក់ជនត្រូវឱ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ត្រូវបានធ្វើឡើងដោយដីកាបស់ចៅក្រមស៊ើបសួរ តាមរយៈការផ្តើមគំនិតផ្ទាល់របស់ចៅក្រមស៊ើបសួរ ឬ អាចតាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។ ការចេញដីកានេះត្រូវបញ្ជាក់អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ និង ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា និង ជនត្រូវចោទក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចំពោះសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសុំឱ្យដាក់ជនត្រូវចោទក្រោមការត្រួតពិនិត្យរបស់តុលាការទៅចៅក្រមស៊ើបសួរ ហើយប្រសិនបើចៅក្រមស៊ើប

77 មាត្រា២២៤ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ស្ទួរមិនព្រមសម្រេចតាមការសុំទេ ត្រូវចេញដីកាបដិសេធក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នេះចៅក្រមស៊ើបសួរមិនបានសម្រេចទេ ព្រះរាជអាជ្ញា អាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរបាន។

**ក ការគោរពកាតព្វកិច្ចរបស់ជនត្រូវចោទ**

ជនត្រូវចោទដែលត្រូវបានចៅក្រមស៊ើបសួរសម្រេចដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ត្រូវគោរពនូវកាតព្វកិច្ចមួយចំនួន ១២ (ដប់ពី) ចំណុច[78]៖

១ មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

២ មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

៣ មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដែលកំណត់ដោយចៅក្រមស៊ើបសួរ

៤ ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៥ ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៦ ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ

៧ មិនត្រូវបើកបររថយន្ត

៨ មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

៩ ដាក់ប្រាក់ធានា ដែលចំនួនប្រាក់ធានា និង ចិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកលើធនធានរបស់ជនត្រូវចោទ

១០ មិនត្រូវកាន់កាប់ ឬ យកជាប់ខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់

១១ ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និង ជាយកថាហេតុ ដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ

១២ មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ក្នុងការអនុវត្តចំណុចទាំង ១២ (ដប់ពី) ខាងលើ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬ សកម្មភាពខាងសហជីពបានទេ។

គួរបញ្ជាក់ផងដែរថា ការអនុវត្តចំណុចទី ៦ (ប្រាំមួយ) នៅពេលដែលជនត្រូវចោទប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណដល់ក្រឡាបញ្ជី ក្រឡាបញ្ជីនឹងប្រគល់បង្កាន់ដៃមួយដែលបញ្ជាក់ថាជនត្រូវចោទ

78 មាត្រា២២៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

បានប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណរបស់របស់ដល់ក្រឡាបញ្ជី ដោយមានការចុះហត្ថលេខាដោយក្រឡាបញ្ជី។ ចំណែកឯការអនុវត្តចំណុចទី ៩ (ប្រាំបួន) ការដាក់ប្រាក់ធានា និង ទី ១០ (ដប់) ការប្រគល់អាវុធ ជនត្រូវចោទនឹងទទួលបានបង្កាន់ដៃ ដែលចុះហត្ថលេខារដោយប្រធានតុលាការ ព្រះរាជអាជ្ញា និង ក្រឡាបញ្ជី។

## ខ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ

ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាការលុបចោល កែប្រែខ្លឹមសារ ឬ បញ្ចូលកាតព្វកិច្ចថ្មីសម្រាប់ការត្រួតពិនិត្យតាមផ្លូវតុលាការទៅលើជនត្រូវចោទ ឬ ជនដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការនេះ អាចត្រូវបានធ្វើឡើងដោយចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា និង បណ្ដឹងសុំកែប្រែដោយជនត្រូវចោទ។

- **ការកែប្រែការត្រួតពិនិត្យដោយចៅក្រមស៊ើបសួរ៖** ចៅក្រមស៊ើបសួរ អាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬ បញ្ចូលកាតព្វកិច្ចថ្មី បានគ្រប់ពេលវេលា[79]។ នៅពេលដែលមានការកែប្រែចៅក្រមស៊ើបសួរត្រូវសម្រេចដោយដីកា និង ត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា និង ជនត្រូវចោទ។
- **បណ្ដឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា៖** ព្រះរាជអាជ្ញាអាចសុំទៅចៅក្រមស៊ើបសួរឱ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការទៅលើជនត្រូវចោទបានគ្រប់ពេលវេលា[80]។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ និង ត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកាសម្រេចបដិសេធមិនព្រមធ្វើតាមពាក្យសុំរបស់ព្រះរាជអាជ្ញាត្រូវមានសំអាងហេតុ។
- **បណ្ដឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនរងគ្រោះ៖** ជនត្រូវចោទអាចធ្វើពាក្យសុំឱ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា[81]។ ជនត្រូវចោទត្រូវដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរ បន្ទាប់មកចៅក្រមស៊ើបសួរបញ្ជូនពាក្យសុំនេះទៅព្រះរាជអាជ្ញា និង សំណុំរឿងដើម្បីឱ្យព្រះរាជអាជ្ញាពិនិត្យ និង ផ្ដល់យោបល់។ ចៅក្រមស៊ើបសួរនឹងធ្វើការសម្រេចអំពីពាក្យសុំរបស់ជនត្រូវចោទនេះថា គួរយល់ព្រម ឬ មិនយល់ព្រម យ៉ាងយូរបំផុតក្នុងរយៈពេល ៥

79 មាត្រា២២៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
80 មាត្រា២២៨ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
81 មាត្រា២២៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

(ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ហើយចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការសម្រេចនេះក្នុងរយៈពេលយ៉ាងខ្លីបំផុត ទៅព្រះរាជអាជ្ញា និង ជនត្រូវចោទ។ ដីកាដែលសម្រេចមិនព្រមធ្វើតាមពាក្យសុំរបស់ជនត្រូវចោទត្រូវតែមានសំអាងហេតុ ប៉ុន្តែបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរបាន។

### គ ការគេចវេះពីកាតព្វកិច្ចរបស់ជនត្រូវចោទ

ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមាដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ហើយក៏ដោយ ប៉ុន្តែការឃុំខ្លួនក្នុងករណីនេះមិនអាចលើស ៤ (បួន) ខែ បានទេចំពោះនីតិជន និង មិនអាចលើស ២ (ពីរ) ខែ បានទេចំពោះអនីតជន[82]។

## ផ្នែកទី៣ ការត្រួតពិនិត្យកិច្ចការរបស់មន្ទីស៊ើបសួរដោយសភាស៊ើបសួរ

សភាស៊ើបសួរ ជាសភាពិសេសនៃសាលាឧទ្ធរណ៍ ឬ ស្ថាប័នស៊ើបសួរជាន់ខ្ពស់នៃសាលាឧទ្ធរណ៍។ សភាស៊ើបសួរនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងពិនិត្យនិយ័តភាពនៃនីតិវិធីស៊ើបសួរទាំងអស់របស់មន្ទីស៊ើបសួរដែលនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីឱ្យប្រព្រឹត្តទៅត្រឹមត្រូវតាមការកំណត់របស់ច្បាប់។

### ៣.១ អំណាចរបស់សភាស៊ើបសួរ

ក្នុងការអនុវត្តសភាស៊ើបសួរ មិនត្រឹមតែពិនិត្យទៅលើនិយ័តភាពនៃកិច្ចស៊ើបសួរទេ សភាស៊ើបសួរក៏ពន្លាតអំណាចរបស់គាត់លើកិច្ចនីតិវិធីផងដែរ ពោលគឺមុនពេលសំណុំរឿងត្រូវបានបញ្ជូនទៅជំនុំជម្រះគឺស្ថិតក្រោមការត្រួតពិនិត្យរបស់សភាស៊ើបសួរទាំងអស់។ សភាស៊ើបសួរជាអ្នកអ្នកសមត្ថកិច្ចទទួលវិនិច្ឆ័យទៅលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាបស់ចៅក្រមស៊ើបសួរ និង បណ្តឹងសុំមោឃភាពទៅលើកិច្ចកិច្ច ឬ លិខិតណាមួយនៃនីតិវិធីរបស់ចៅក្រមស៊ើបសួរ។ ដូច្នេះនៅក្នុងការអនុវត្តពេលមានបណ្តឹងកើតឡើងយើងសង្កេតឃើញថាសភាស៊ើបសួរមានអំណាចមួយចំនួនដូចខាងក្រោមះ

- **អំណាចត្រួតពិនិត្យទៅលើកិច្ចស៊ើបសួរដែលមានលក្ខណៈជាសេចក្តីសម្រេច** សំដៅដល់កិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរដែលបានចេញសេចក្តីសម្រេចដែលមានទម្រង់ជាដីកាផ្សេងៗ។ ឧទាហរ៍ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរទៅលើជនត្រូវចោទជាដើម។ ជាគោល

82 មាត្រា២២៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ការណ៍ដើម្បីឱ្យសភាស៊ើបសួរអាចត្រួតពិនិត្យបានទៅលើកិច្ចស៊ើបសួរដែលមានលក្ខណៈជាសេចក្តីសម្រេចនេះ គឺតម្រូវឱ្យមានបណ្តឹងពីបុគ្គលដែលមានសិទ្ធិប្តឹង។

- **អំណាចត្រួតពិនិត្យនិយ័តភាពនៃនីតិវិធី** មានន័យថា សភាស៊ើបសួរពិនិត្យមើលពីនិយ័តភាពនៃនីតិវិធី និង ការប្រព្រឹត្តទៅដ៏ល្អនៃនីតិវិធី[83]។ ថាតើបានបំពេញតាមលក្ខខ័ណ្ឌដែលច្បាប់តម្រូវដែលឬទេ? ប្រសិនបើសភាស៊ើបសួរបានទទួលពាក្យបណ្តឹង និង បានពិនិត្យឃើញថាមានកំហុស សភាស៊ើបសួរមានសិទ្ធិសម្រេចធ្វើមោឃកម្មទៅលើកិច្ចដែលមានកំហុសនោះបាន។ បណ្តឹងដែលនាំឱ្យសភាស៊ើបសួរអាចពិនិត្យនិយ័តភាពនៃនីតិវិធីបាន គឺជាបណ្តឹងសុំមោឃភាពចំពោះកិច្ចណាមួយ និង បណ្តឹងពាក់ព័ន្ធនឹងដីកាសម្រេចផ្សេងៗរបស់ចៅក្រមស៊ើបសួរ។
- **អំណាចពិនិត្យ កែសម្រួល បំពេញបន្ថែមនីតិវិធី** ជាទូទៅសភាស៊ើបសួរអនុវត្តនៅពេលដែលទទួលបានបណ្តឹងអំពីសំណុំរឿងទាំងមូល។ ឧទាហរណ៍ បណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរជាដើម។ សភាស៊ើបសួរអាចបង្គាប់ឱ្យធ្វើកិច្ចស៊ើបសួរបំពេញបន្ថែម តាមដែលខ្លួនយល់ឃើញថាមានប្រយោជន៍[84]។ សភាស៊ើបសួរអាចចាត់សមាជិកណាម្នាក់របស់ខ្លួន ឬ ចៅក្រមស៊ើបសួរណាម្នាក់ដែលខ្លួនប្រគល់អំណាចឱ្យបំពេញកិច្ចស៊ើបសួរ ព្រមទាំងកំណត់អំពីអំណាច និងព្រំដែនដែលត្រូវស៊ើបសួរនេះ។ ក្នុងការបំពេញបន្ថែមនីតិវិធីនេះសភាស៊ើបសួរក៏អាចពន្លាតការចោទប្រកាន់ទៅលើបទល្មើស ក្នុងករណីដែលបទល្មើសនោះលេចចេញពីសំណុំរឿងដែលកំពុងធ្វើការស៊ើបសួរបំពេញបន្ថែមនេះ ហើយក៏អាចពន្លាតការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យដល់បុគ្គលដែលពាក់ព័ន្ធបានផងដែរ។ កាលណាការស៊ើបសួរត្រូវបានបំពេញរួចហើយ សំណុំរឿងត្រូវយកមកតម្កល់នៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ និង រង់ចាំសវនាការថ្មីដែលកំណត់កាលបរិច្ឆេទដោយប្រធានសភាស៊ើបសួរ។
- **អំណាចក្នុងការបន្តការស៊ើបសួរ** នៅពេលដែលសភាស៊ើបសួរបានទទួលបណ្តឹង សភាស៊ើបសួរអាចបន្តការស៊ើបសួរបានដោយខ្លួនឯងផ្ទាល់។ ក្នុងករណីដែលពិនិត្យឃើញថាមានកំហុសឆ្គងនៃនីតិវិធី ឬ សភាស៊ើបសួរពិនិត្យឃើញថាចៅក្រមស៊ើបសួរធ្វើមិនត្រឹមត្រូវតាមនីតិវិធី សភាស៊ើបសួរដកសមត្ថកិច្ចពីចៅក្រមស៊ើបសួរដែលប្រព្រឹត្តកំហុសរួច យកសំណុំរឿងមកស៊ើបសួរដោយខ្លួនឯងផ្ទាល់។ ការដកសំណុំរឿងមកស៊ើបសួរដោយខ្លួនឯងនេះ បានន័យថាសភាស៊ើបសួរចាត់សមាជិក

83 មាត្រា២៦១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

84 មាត្រា២៦២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

របស់ខ្លួនណាម្នាក់ឱ្យស៊ើបសួរ ហើយនៅពេលបិទបញ្ចាប់ការស៊ើបសួរ សមាជិកដែលត្រូវបានចាត់ឱ្យស៊ើបសួរនេះមិនអាចចេញដីកាដំណោះស្រាយបានទេ ពោលគឺសភាស៊ើបសួរជាអ្នកចេញសាលដីកាដំណោះស្រាយ ដោយសាលដីកាលើកលែងការចោទប្រកាន់ ឬ សាលដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។

- **អំណាចផ្នែកបត្យាប័ន** សភាស៊ើបសួរមានសមត្ថកិច្ចផ្តល់យោបល់យល់ព្រមលើបត្យាប័ន ឬ មិនព្រមបន្ទាប់ពីបានស្តាប់ចម្លើយបុគ្គលដែលគេទាមទារ សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី។ សភាស៊ើបសួរផ្តល់យោបល់ដោយសាលាដីកាបស់ខ្លួន។

## ៣.២ អំណាចផ្ទាល់របស់ប្រធានសភាស៊ើបសួរ

ប្រធានសភាស៊ើបសួរបានអំណាចជាបុគ្គលផ្ទាល់ក្នុងការរ៉ាប់រងលើការប្រព្រឹត្តទៅដ៏ល្អនៃមន្ទីរស៊ើបសួរ នៃចៅក្រមស៊ើបសួរ បានន័យថា ប្រធានសភាស៊ើបសួរមានអំណាចត្រួតពិនិត្យទៅលើកិច្ចផ្នែករដ្ឋបាលរបស់ចៅក្រមស៊ើបសួរ ដោយមានគោលបំណងធានារ៉ាប់រងការប្រព្រឹត្តទៅរបស់មន្ទីរស៊ើបសួរឱ្យបានល្អប្រសើរ ហើយដើម្បីជៀសវាងនូវការយឺតយ៉ាវ ដោយការអូសបន្លាយពេលវេលានៃនីតិវិធីដោយពុំសមហេតុផល។ ប្រធានសភាស៊ើបសួរត្រួតពិនិត្យទៅលើមន្ទីរស៊ើបសួរទាំងអស់ដែលនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួនដោយ៖

- ត្រួតពិនិត្យទៅលើបញ្ជីរាយនាមឈ្មោះរឿងទាំងអស់របស់ចៅក្រមស៊ើបសួរគ្រប់រូប នៅពេលដំណាច់ត្រីមាសនីមួយៗ ដែលចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេស ស្តីពីកិច្ចចុងក្រោយនៃការស៊ើបសួរដែលបានបំពេញ។ ប្រសិនបើបានបញ្ហាមិនប្រក្រតីប្រធានសភាស៊ើបសួរ អាចសុំឱ្យចៅក្រមស៊ើបសួរបំភ្លឺបាន។
- ធ្វើអធិការកិច្ច មានន័យថា ប្រធានសភាស៊ើបសួរអាចធ្វើអធិការកិច្ចទៅគ្រប់មន្ទីរស៊ើបសួរ និង ធ្វើរបាយការណ៍អំពីអធិការកិច្ចនេះផ្ញើទៅប្រធានសាលាឧទ្ធរណ៍។
- ធ្វើអធិបញ្ជារ ដោយការធ្វើអធិបញ្ជារនេះប្រធានសភាស៊ើបសួរធ្វើអធិបញ្ជារផ្ទាល់ទៅចៅក្រមស៊ើបសួរ ក្នុងករណីមានបណ្តឹងសុំឱ្យបិទការស៊ើបសួរ។ នៅពេលផុតថិរវេលា ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃចោទប្រកាន់ ជនត្រូវចោទសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ តែចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ១ (មួយ) ខែ ជនត្រូវចោទអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលប្រធានសភាស៊ើបសួរអាចធ្វើអធិបញ្ជារឱ្យចៅក្រមស៊ើបសួរសម្រេច។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីក៏អាចសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរបានផងដែរ បើសិនជាផុតរយៈពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃ

តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹង ចៅក្រមស៊ើបសួរត្រូវតែសម្រេច តែបើមិនបានសម្រេចទេដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលអាចធ្វើអធិបញ្ញាឱ្យចៅក្រមស៊ើបសួរសម្រេច។

### ៣.៣ បណ្តឹងឧទ្ធរណ៍ចំពោះដីកាបស់ចៅក្រមស៊ើបសួរ

បណ្តឹងឧទ្ធរណ៍ចំពោះដីកាបស់ចៅក្រមស៊ើបសួរ គឺជាការប្តឹងប្រឆាំងចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ហើយបុគ្គលដែលមានសិទ្ធិទើបអាចប្តឹងបានចំពោះដីកាសម្រេចនេះ ចំណែកឯកដីកាបង្គាប់មិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ទេ។ ឧទាហរណ៍ ដីកាបង្គាប់ឱ្យចូលខ្លួន ជាដើម។ បុគ្គលដែលមានសិទ្ធិប្តឹងត្រូវបានកំណត់ដូចខាងក្រោម៖

- **អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង ព្រះរាជអាជ្ញា** ដោយព្រោះតែអគ្គព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញា ជាតួអង្គសំខាន់ និង ជាតំណាងនៃស្ថាប័នអយ្យការទាំងមូល ដូច្នេះពួកគាត់អាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរ[85]។ ចំពោះរយៈពេលវិញត្រូវបានកំណត់ឱ្យអគ្គព្រះរាជអាជ្ញាអបសាលាឧទ្ធរណ៍ ធ្វើបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១ (មួយ) ខែ យ៉ាងយូរគិតចាប់ពីពេលប្រកាសដីកា។ ចំណែកឯ បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកា។
- **ជនត្រូវចោទ** សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍របស់ជនត្រូវចោទត្រូវបានកំណត់ទៅតាមប្រភេទដីកាសម្រេច មានន័យថា ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍បានចំពោះតែដីកា[86]៖
  - ➢ ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ
  - ➢ ដីកាមិនព្រមប្រគល់វត្ថុដែលចាប់ឱ្យទៅម្ចាស់ដើមវិញ
  - ➢ ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ
  - ➢ ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ ឬ សុំឱ្យធ្វើប្រតិកោសលវិច័យ
  - ➢ ដីកាស្តីពីរឿងឃុំខ្លួនបណ្តោះអាសន្ន និង ការត្រួតពិនិត្យតាមផ្លូវតុលាការ

  ក្រៅពីដីកាខាងលើជនត្រូវចោទមិនអាចប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចផ្សេងទៀតរបស់ចៅក្រមស៊ើបសួរបានទេ។ បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ត្រូវធ្វើក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតចាប់ពីការជូនដំណឹងពីដីកា។

---

85 មាត្រា២៦៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

86 មាត្រា២៦៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

– **ដើមបណ្តឹងរដ្ឋប្បវេណី** សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវបានកំណត់ផងទៅលើប្រភេទដីកាដែលអាចប្តឹងឧទ្ធរណ៍បាន។ ដីកាដែលដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងបានមាន[87]៖

- ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ
- ដីកាមិនព្រមស៊ើបសួរ
- ដីកាកំណត់ចំនួនទឹកប្រាក់
- ដីកាប្រកាសមិនទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
- ដីកាផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណី
- ដីកាមិនព្រមប្រគល់សងវត្ថុដែលចាប់យកទៅម្ចាស់ដើមវិញ
- ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ
- ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬ សុំឱ្យធ្វើប្រតិកោសលវិច័យ
- ដីកាដំណោះស្រាយ។

បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតចាប់ពីការជូនដំណឹងពីដីកា។

– **បុគ្គលនៅក្រៅនីតិវិធីដែលមានការពាក់ព័ន្ធផលប្រយោជន៍** បុគ្គលនៅក្រៅនីតិវិធីនេះសំដៅដល់បុគ្គលដែលពាក់ព័ន្ធនៅពេលដែលចៅក្រមស៊ើបសួរ ឬ អ្នកដែលអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរត្រូវបានចាប់យកវត្ថុណាមួយនៅពេលបំពេញកិច្ចនីតិវិធីឆែកឆេរ។ ហើយការប្តឹងឧទ្ធរណ៍របស់បុគ្គលនៅក្រៅនីតិវិធីនេះសំដៅទៅលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធមិនប្រគល់វត្ថុដែលរឹបអូសទៅម្ចាស់ដើមវិញ។ បណ្តឹងឧទ្ធរណ៍របស់បុគ្គលនៅក្រៅនីតិវិធីនេះ ត្រូវធ្វើក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតចាប់ពីការជូនដំណឹងពីដីកា។

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើតាមការប្រកាសប្តឹង នៅក្រឡាបញ្ជីនៃសាលាដំបូង និង ត្រូវចុះក្នុងបញ្ជីនៃបណ្តឹងឧទ្ធរណ៍ដោយក្រឡាបញ្ជី។ បន្ទាប់ពីបានទទួលបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីត្រូវជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ ហើយក្រឡាបញ្ជីត្រូវរៀបចំ និង បញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីនៃសភាស៊ើបសួរ ដោយមានសេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍។ ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយក៏ចៅក្រមស៊ើបសួរនៅតែអាចបន្តការស៊ើបសួររបស់របស់បានជាធម្មតាបានដែរ លើកលែងតែមានបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយតែប៉ុណ្ណោះដែលចៅក្រមស៊ើបសួរ

87 មាត្រា២៦៨ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

មិនអាចបន្តការស៊ើបសួរបាន ប៉ុន្តែប្រសិនបើមានសេចក្ដីសម្រេចណាមួយផ្ទុយរបស់ប្រធានសភាស៊ើបសួរ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវផ្អាកសិន ពោលគឺប្រធានសភាស៊ើបសួរសម្រេចផ្អាកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ ការសម្រេចនេះមិនអាចតវ៉ាបានឡើយ[88]។ ប្រសិនបើមានបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំបណ្ដោះអាសន្ន និង ដីកាលើកលែងការចោទប្រកាន់ ជនត្រូវចោទដែលកំពុងជាប់ឃុំនោះត្រូវរក្សាទុកក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ឬ រង់ចាំសេចក្ដីសម្រេចរបស់សភាស៊ើបសួរ ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍។

### ៣.៤ ការប្ដឹងសុំមោឃភាព

បណ្ដឹងសុំមោឃភាព គឺជាបណ្ដឹងដែលប្ដឹងទៅសភាស៊ើបសួរផ្ទាល់ សុំមោឃភាពទៅលើកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រង់លិខិតណាមួយ ឬ នីតិវិធីទាំងមូល ឬ ផ្នែកណាមួយ។ បុគ្គលដែលមានសិទ្ធិប្ដឹងត្រូវបានកំណត់ និង ផ្ដល់សិទ្ធិដល់[89]៖

- **ចៅក្រមស៊ើបសួរ** ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព ចៅក្រមស៊ើបសួរអាចប្ដឹងទៅសភាស៊ើបសួរ តាមដីកាដោយមានសំអាងហេតុ និង ជូនព័ត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី។
- **ព្រះរាជអាជ្ញា** ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាលិខិតណាមួយនៃនីតិវិធីមានមោឃភាព ព្រះរាជអាជ្ញាធ្វើពាក្យសុំដោយមានសំអាងហេតុ បញ្ជូនទៅសភាស៊ើបសួរ និង ជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ។
- **ជនត្រូវចោទ** ប្រសិនបើជនត្រូវចោទយល់ឃើញថាលិខិតណាមួយនៃនីតិវិធីមានមោឃភាព ជនត្រូវចោទធ្វើពាក្យសុំជូនដោយមានសំអាងហេតុជូនទៅសភាស៊ើបសួរ និង ជូនដំណឹងដល់ចៅក្រមស៊ើបសួរ។
- **ដើមបណ្ដឹងរដ្ឋប្បវេណី** ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថាលិខិតណាមួយនៃនីតិវិធីមានមោឃភាព ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើពាក្យសុំជូនដោយមានសំអាងហេតុជូនទៅសភាស៊ើបសួរ និង ជូនដំណឹងដល់ចៅក្រមស៊ើបសួរ។

ពាក្យសុំរបស់បុគ្គលដែលមានសិទ្ធិខាងលើត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ភ្លាមនោះ ក្រឡាបញ្ជីសុំឱ្យចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងនៃនីតិវិធីមកឱ្យខ្លួន។ ចំពោះដីកាដែលអាចត្រូវ

88 មាត្រា២៧៥ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
89 មាត្រា២៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ប្តឹងឧទ្ធរណ៍បាន មិនអាចធ្វើជាកម្មវត្ថុនៃបណ្តឹងសុំមោឃភាពបានឡើយ។ ភាគីក៏អាចបោះចង់សិទ្ធិមិនប្តឹងសុំមោឃភាពបានដែរ ទោះបីជាមានការបំពាន ឬ ទម្រង់ការសំខាន់ណាមួយបានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍នៃភាគីក៏ដោយ។ ការបោះបង់នេះត្រូវពិនិត្យ និង ធ្វើកំណត់ហេតុដោយចៅក្រមស៊ើបសួរ ។ ចំណែកឯដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនៃនីតិវិធីមុន ពេលដីកាដំណោះស្រាយដែលចូលជាស្ថាពររួចហើយមិនអាចប្តឹងមោឃភាពនៃនីតិវិធី ឬ លិខិតណាមួយបានទេ បើសិនជាបុគ្គលដែលមានសិទ្ធិប្តឹងមោឃភាពយល់ឃើញថាលិខិត ឬ កិច្ចណាមួយមានមោឃភាព ត្រូវតែប្តឹងមុនពេលដីកាដំណោះស្រាយចូលជាស្ថាពរ មិនអាចលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានឡើយ[90]។

គួរបញ្ជាក់ផងដែរថា ការមិនគោរពវិធានបញ្ញត្តិនាំឱ្យមានមោឃភាពចំពោះ វិធាន ឬ ទម្រង់ការដូចជា[91]៖

– ការមិនគោរពវិធានបញ្ញត្តិនៃការបើកការស៊ើបសួរ
– ការមិនគោរពវិធានបញ្ញត្តិនៃសមត្ថកិច្ចដែនដី
– ការមិនគោរពវិធានបញ្ញត្តិនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
– ការមិនគោរពវិធានបញ្ញត្តិនៃវិសាលភាពនៃការប្តឹង និង ការមិនគោរពវិធានបញ្ញត្តិនៃជំនួយរបស់ក្រឡាបញ្ជី។

នាំឱ្យមានមោឃភាពផងដែរ កាលណាការបំពានវិធាន ឬ ទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ឬ បទបញ្ញត្តិទាំងឡាយស្តីពីនីតិវិធីព្រហ្មទណ្ឌធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលទទួលរងការបំពាននេះ។ វិធាន និង ទម្រង់ការដែលមានលក្ខណៈសំខាន់នោះមានជាអាទិ៍ គឺវិធានទម្រង់ការដែលមានបំណងធានាការពារគោរពសិទ្ធិការពារខ្លួន។

នៅពេលដែលសភាស៊ើបសួរបានទទួលពាក្យសុំឱ្យមានមោឃកម្ម សភាស៊ើបសួរក៏អាចសម្រេចមិនទទួលដែលក្នុងករណី[92]៖

– ពាក្យប្តឹងសុំគ្មានសំអាងហេតុ
– ពាក្យប្តឹងសុំទាក់ទងនឹងដីកាដែលអាចប្តឹងឧទ្ធរណ៍បាន
– ពាក្យប្តឹងសុំគ្មានមូលកភាពយ៉ាងជាក់ស្តែង

90 មាត្រា២៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
91 មាត្រា២៥២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
92 មាត្រា២៧៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

កាលណាពាក្យប្តឹងសុំត្រូវបានប្រកាសមិនអាចទទួលបាន សំណុំរឿងត្រូវបង្វិលភ្លាមទៅចៅក្រមស៊ើបសួរវិញ។ សេចក្តីសម្រេចរបស់សភាស៊ើបសួរមិនអាចតវ៉ាបានទេ។ បើកាលណាពាក្យសុំត្រូវបានទទួលសុំមោឃកម្មចំពោះកិច្ច ឬ លិខិតណាមួយនៃនីតិវិធី សភាស៊ើបសួរនឹងសម្រេចពិនិត្យមើលថា តើមោឃកម្មនេះត្រូវធ្វើទៅលើកិច្ច ឬ លិខិតនៃនីតិវិធីផ្សេងទៀតដែរទេ[93]? បើសិនសភាស៊ើបសួរពិនិត្យឃើញថាកិច្ចនីតិវិធី ឬ លិខិតនីតិវិធីរបស់ចៅក្រមស៊ើបសួរណាមួយមានកំហុសនីតិវិធី ឬ មានកំហុសត្រង់កិច្ច ឬ លិខិតផ្សេងទៀតដែរ ដូច្នេះសភាស៊ើបសួរសម្រេចធ្វើមោឃភាពកិច្ចនោះ។ ចំពោះកិច្ចនីតិវិធី ឬ លិខិតនៃនីតិវិធីណាមួយមានកំហុស ត្រូវដកចេញពីសំណុំរឿងទុកនៅក្រឡាបញ្ជីនៃសភាស៊ើបសួរ។ ក្រោយពីបានសម្រេចមោឃកម្មរួច សភាស៊ើបសួរអាច[94]៖

- បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ
- ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត
- បន្តការស៊ើបសួរដោយខ្លួនឯង។

ការសម្រេចបន្តការស៊ើបសួរដោយខ្លួនឯងនេះសភាស៊ើបសួរចាត់សមាជិកណាម្នាក់របស់ខ្លួនដែលប្រើអំណាចចៅក្រមស៊ើបសួរ ដើម្បីបំពេញកិច្ចរបស់ខ្លួនក្នុងការស៊ើបសួរទៅលើសំណុំរឿងដែរដកទុកនៅការិយាល័យក្រឡាបញ្ជីនោះ។ បន្ទាប់ពីបានបញ្ចប់ សំណុំរឿងត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ដើម្បីរង់ចាំការកំណត់កាលបរិច្ឆេទរបស់ប្រធានសភាស៊ើបសួរក្នុងការបើកសវនាការ។ សភាស៊ើបសួរបិទការស៊ើបសួរតាមរយៈសាលដីកាដំណោះស្រាយ។ ក្នុងករណីដែលសភាស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំ សេចក្តីសម្រេចនេះត្រូវមានអនុភាពអនុវត្តភ្លាម។

93 មាត្រា២៨០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

94 មាត្រា២៨១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# ជំពូក៣

# ការបិទការស៊ើបសួរ

# ជំពូក៣

# ការបិទការស៊ើបសួរ

នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួររបស់ខ្លួនបានបំពេញកិច្ចគ្រប់គ្រាន់ហើយ ចៅក្រមស៊ើបសួរនឹងសម្រេចបិទការស៊ើបសួរ។ ការសម្រេចនេះជាឆន្ទៈផ្ទាល់របស់ចៅក្រមស៊ើបសួរ បន្ទាប់ពីបានអនុវត្តអំណាចរបស់ខ្លួនក្នុងការស៊ើបសួររួចមក។ គួរបញ្ជាក់ថា ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់ពេលវេលាជាក់លាក់ណាមួយដែលចៅក្រមស៊ើបសួរត្រូវសម្រេចបិទការស៊ើបសួររបស់ខ្លួនទេ ប៉ុន្តែប្រធានសភាស៊ើបសួរ ជាអ្នកធានាការរ៉ាបរងកុំឱ្យនីតិវិធីទាំងឡាយមានការយឺតយ៉ាវដោយមិនសមហេតុផល។ ចំណែកឯ ជនត្រូវចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចសុំឱ្យចៅក្រមស៊ើបសួរបិទបញ្ចប់ការស៊ើបសួរបានផងដែរ បន្ទាប់ពីការស៊ើបសួរ ឬ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងរយៈពេល ១ (មួយ) ឆ្នាំ។ មុននឹងចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយដើម្បីបិទការស៊ើបសួររបស់ខ្លួនចៅក្រមស៊ើបសួរជូនដំណឹងដល់ភាគីជាមុន (ផ្នែកទី១ និង ចេញដីកាដំណោះស្រាយជាក្រោយ (ផ្នែកទិ២)។

## ផ្នែកទី១ កិច្ចដាបឋមនៃការបិទការស៊ើបសួរ

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការបិទការស៊ើបសួរដល់ភាគីជាមុនដំបូង ដើម្បីអាចឱ្យភាគីមានឱកាសស្នើសុំដើម្បីបំពេញកិច្ចណាមួយ ដែលភាគីយល់ឃើញថាមានការខ្វះចន្លោះ ឬ ចង់ឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរបន្ថែម។ ការជូនព័ត៌មាននេះគឺដល់ ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទ។

### ១.១ ការជូនដំណឹងដល់ភាគី

នៅពេលដែលចៅក្រមស៊ើបសួរ យល់ឃើញថា ការស៊ើបសួរត្រូវបញ្ចប់ គាត់ជូនព័ត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និង មេធាវី[95]។ បន្ទាប់ពីបានជូនព័ត៌មានរួចមក ២ (ពី) ថ្ងៃក្រោយចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។ ក្នុងរយៈពេលនេះព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ក៏អាចស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរបន្ថែមបានផងដែរ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរទៀតនោះ ព្រះរាជអាជ្ញានឹងចេញដីកាចាត់ឱ្យស៊ើបសួរបន្ថែម។

95 មាត្រា២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង ១ (មួយ) ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ប៉ុន្តែក្នុងករណីដែលព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរថា ការស៊ើបសួរត្រូវបានបញ្ចប់ នោះព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និង មានសំអាងហេតុ ដោយអាចសុំឱ្យបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះ ឬ លើកលែងចោទប្រកាន់។ គួរបញ្ជាក់ផងដែរថា ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។

## ១.២ ការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម

ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរបានបន្ថែមបាន នៅគ្រប់ពេលវេលានៃការស៊ើបសួរ។

### ១.២.១ ការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍[96]។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដោយមានសំអាងហេតុ និង ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងថេរវេលាយ៉ាងខ្លីបំផុត។ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេលនេះ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរ ដែលអាចសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ១.២.២ ការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយជនត្រូវចោទ

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬ ស្តាប់ចម្លើយសាក្សី សួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែង ដោយពាក្យសុំជាលាយលក្ខណ៍អក្សរ និង មានសំអាងហេតុច្បាស់លាស់[97]។ បើសិនជាចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមពាក្យសុំរបស់ជនត្រូវចោទនេះ ចៅក្រមស៊ើបសួរនឹងចេញដីកាបដិសេធនៅក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីទទួលបានពាក្យសុំ ដោយមានសំអាងហេតុ និង ជូនដំណឹងដល់ព្រះរាជអាជ្ញា និង ជនត្រូវចោទ។ បើផុតរយៈពេល ១

96 មាត្រា១៣២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧
97 មាត្រា១៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

(មួយ) ខែ ចៅក្រមស៊ើបសួរមិនបានសម្រេចអំពីពាក្យសុំរបស់ខ្លួនទេ ជនត្រូវចោទអាចដាក់ពាក្យសុំផ្ទាល់ទៅសភាស៊ើបសួរដែលអាចសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ១.២.៣ ការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឱ្យចៅក្រមស៊ើបសួរស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែង បានគ្រប់ពេលវេលានៅក្នុងដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ ឬ នៅក្នុងកិច្ចរបស់ចៅក្រមស៊ើបសួរ។ ពាក្យសុំនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និង មានសំអាងហេតុ។ ក្នុងករណីដែលចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមពាក្យសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធ ដោយមានសំអាងហេតុ ក្នុងរយៈពេល ១ (មួយ) ខែ ក្រោយពីបានទទួលពាក្យសុំ និង ត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និង ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចប្តឹងទៅសភាស៊ើបសួរបានផងដែរ ប្រសិនបើចៅក្រមស៊ើបសួរមិនបានធ្វើការសម្រេចចំពោះពាក្យសុំរបស់ខ្លួនក្នុងរយៈពេល ១ (មួយ) ខែ ។

## ផ្នែកទី២ ដីកាដំណោះស្រាយ

នៅក្រោយពេលដែលចៅក្រមស៊ើបសួរ ជូនព័ត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវី រួចហើយ បើសិនជាគ្មានការសុំឱ្យបំពេញកិច្ចណាមួយទេ ឬ បានបំពេញកិច្ចតាមការសុំរួចរាល់អស់ហើយ ចៅក្រមស៊ើបសួរសម្រេចបិទការស៊ើបសួររបស់ខ្លួនដោយចេញដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយជាដីកាបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដែលមានចុះជាលាយលក្ខណ៍អក្សរ ចុះកាលបរិច្ឆេទ ចុះហត្ថលេខាចៅក្រមស៊ើបសួរ ព្រមទាំងក្រឡាបញ្ជី ហើយក៏កំណត់អំណត់អត្តសញ្ញាណរបស់ជនត្រូវចោទ ដូចជា នាម គោត្តនាម ទីកន្លែង និង ថ្ងៃខែឆ្នាំកំណើត លំនៅឋាន និង មុខរបបជាក់លាក់។ ដីកានេះកំណត់អំពីបទល្មើសដែលច្បាប់បានកំណត់ទៅលើបទល្មើសដែលជនត្រូវចោទបានប្រព្រឹត្ត និង មូលហេតុដែលមាន ឬ មិនមានបន្ទុកប្រឆាំងនឹងជនត្រូវចោទ។ ដូច្នេះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរអាចស្តែងឡើងតាមរយៈ ដីកាលើកលែងការចោទប្រកាន់ (ចំណុច ២.១) និង ដីកាបញ្ជូនទៅជំនុំជម្រះ (ចំណុច ២.២)។

### ២.១ ដីកាលើកលែងការចោទប្រកាន់

ក្រោយពីបានបើកការស៊ើបសួររួចមក មិនបានរកឃើញបន្ទុកដែលនាំឱ្យបញ្ជូនជនត្រូវចោទទៅជំនុំជម្រះទេ ចៅក្រមស៊ើបសួរសម្រេចលើកលែងការចោទប្រកាន់រ ដោយមានមូលហេតុច្បាស់លាស់។ ការសម្រេចនេះជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរផ្ទាល់ ពោលគឺមិនស្ថិតក្រោមកាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ។

### ២.១.១ មូលហេតុនៃការលើកលែងការចោទប្រកាន់

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចលើកលែងការចោទប្រកាន់ ចៅក្រមស៊ើបសួរផ្អែកលើករណីដូចខាងក្រោម៖

- អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ
- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ឬ ជនត្រូវចោទទទួលមរណៈភាព
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។

### ២.១.២ នីតិវិធីនៃការចេញដីកាលើកលែងការចោទប្រកាន់

ដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរនេះ ធ្វើឡើងក្រោយពេលដែលព្រះរាជអាជ្ញាបានបង្វិលសំណុំរឿងមកខ្លួនវិញ និង ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា។ ដីកានេះត្រូវតែមានសំអាងហេតុ ពោលគឺ មានមូលហេតុត្រឹមត្រូវ ច្បាស់លាស់ ដែលមិនអាចឱ្យចៅក្រមស៊ើបសួរបញ្ជូនទៅជំនុំជម្រះបាន។ នៅពេលដែលចេញដីកានេះចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា ជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរយៈពេលដ៏ខ្លីបំផុត។

### ២.១.៣ អានុភាពនៃដីកាលើកលែងការចោទប្រកាន់

ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ មានអនុភាពនាំឱ្យសម្រេច និង បញ្ចប់អំពី៖

- បញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន បានន័យថាបុគ្គលដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវបានដោះលេងឱ្យមានសេរីភាពវិញ។
- បញ្ចប់ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ បុគ្គលដែលត្រូវបានកំណត់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនឹងលែងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ ឬ កម្រិតទៅលើសិទ្ធិ សេរីភាព ទីកន្លែង ទៀតឡើយ ពោលគឺគាត់មានសេរីភាពពេញលេញធម្មតាវិញ។
- សម្រេចប្រគល់វត្ថុដែលបានចាប់យកទៅម្ចាស់ដើមវិញ ការប្រគល់នេះវត្ថុដែលបានចាប់យកក្នុងពេលអនុវត្តការឆែកឆេរ ឬ បានចាប់យក នឹងត្រូវប្រគល់ទៅឱ្យម្ចាស់ដើមវិញ ប៉ុន្តែវត្ថុខ្លះក៏មិនត្រូវបានប្រគល់ទៅឱ្យម្ចាស់ដើមវិញផងដែរ ចំពោះវត្ថុដែលនាំឱ្យប៉ះពាល់ប្រយោជន៍សាធារណៈ គឺត្រូវទុកជាសម្បត្តិរដ្ឋ ឬ ត្រូវបំផ្លាញចោល។

គួរបញ្ជាក់ផងដែរថា ការសម្រេចលើកលែងការចោទប្រកាន់នេះមិននាំឱ្យអាជ្ញាអស់ជំនុំទេ ពោលគឺប្រសិនបើពេលក្រោយព្រះរាជអាជ្ញាបានរកឃើញពិរុទ្ធភាព ឬ លេចឡើងនូវតម្រុយថ្មី ការស៊ើបសួរអាចបើកឡើងបានគ្រប់ពេល។

## ២.២ ដីកាបញ្ជូនទៅជំនុំជម្រះ

ដីកាបញ្ជូនទៅជំនុំជម្រះ ធ្វើឡើងនៅពេលដែលចៅក្រមស៊ើបសួរសម្រេចបិទបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន ដោយបានស្វែងរកនូវភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដែលបង្ហាញថាជនត្រូវចោទពិតជាបានព្រឹត្តនូវបទល្មើសដូចអ្វីដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់មែន ក៏ដូចជា ចៅក្រមស៊ើបសួរបានរកឃើញថាជនត្រូវចោទមានពិរុទ្ធភាពគ្រប់គ្រាន់ ស៊ីសង្វាក់នឹងអង្គហេតុ ឬ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីបញ្ជូនជននោះទៅជំនុំជម្រះ។ ការបញ្ជូនទៅជំនុំជម្រះអាចធ្វើទៅបានដោយមាន មូលហេតុនាំឱ្យមានការចេញដីកាបញ្ជូនទៅជំនុំជម្រះ (២.២.១) នីតិវិធីក្នុងកាចេញដីកាបញ្ជូនទៅជំនុំជម្រះ (២.២.២) និង អានុភាពនៃដីកាបញ្ជូនទៅជំនុំជម្រះ (២.២.៣)។

### ២.២.១ មូលហេតុដែលនាំឱ្យមានការចេញដីកាបញ្ជូនទៅជំនុំជម្រះ

មូលដែលអាចឱ្យចៅក្រមស៊ើបសួរចេញដីកាបញ្ជូនទៅជំនុំជម្រះបានមានដូចជា៖

- ចៅក្រមស៊ើបសួរយល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈឹម ឬ បទលហុ
- បុគ្គលដែលត្រូវបានចោទប្រកាន់ត្រូវបានរកឃើញថាបានប្រព្រឹត្តបទល្មើសពិតប្រាកដមេន
- ជនត្រូវចោទត្រូវបានគេស្គាល់អត្តសញ្ញាណ
- មានភស្តុតាសមល្មមអាចដាក់បន្ទុកលើជនត្រូវចោទបាន។

### ២.២.២ នីតិវិធីក្នុងការចេញដីកាបញ្ជូនទៅជំនុំជម្រះ

ក្រោយពេលដែលចៅក្រមស៊ើបសួរបានជូនព័ត៌មាន និង បញ្ជូនសំណុំរឿងដល់ព្រះរាជអាជ្ញារួចហើយ ចៅក្រមស៊ើបសួររង់ចាំព្រះរាជអាជ្ញាបង្វិលសំណុំរឿងមកវិញ រួចមកចៅក្រមស៊ើបសួរចេញដីកាបញ្ជូនទៅជំនុំជម្រះដោយយល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទបជ្ឈឹម ឬ បទលហុ។ ការសម្រេចនេះគឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរផ្ទាល់ ដោយមិនស្ថិតក្រោមគំនាបអនុវត្តតាមដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ ហើយផ្អែកលើការយល់ឃើញទៅលើមូលហេតុ ពោលគឺចៅក្រមស៊ើបសួរចេញដីកានេះដោយមានសំអាងហេតុ។ ដីកានេះរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និង ឈ្មោះបទល្មើសតាមច្បាប់។ ចៅក្រមស៊ើបសួរចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដោយត្រូវបញ្ជូនសំណុំរឿងទៅប្រធានតុលាការជាបន្ទាន់ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ[98]។ ដីកាដំណោះស្រាយនេះចៅក្រមស៊ើបសួរត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុត ដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី។ ចំណែកជនត្រូវចោទដែលកំពុងនៅជាប់ក្នុងឃុំបណ្ដោះអាសន្ន ត្រូវ

98 មាត្រា២៥០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

រក្សាទុកនៅក្នុងឃុំបណ្ដោះអាសន្នបន្តទៀត រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ ចំពោះជនដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏ត្រូវបានចៅក្រមស៊ើបសួររក្សាឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការផងដែរ។

### ២.២.៣ អនុភាពនៃដីកាបញ្ជូនទៅជំនុំជម្រះ

ដីកាបញ្ជូនទៅជំនុំជម្រះមានអានុភាពបង្ហាញឱ្យឃើញថា ជនត្រូវចោទពិតជាបានប្រព្រឹត្តនូវបទល្មើសដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញាពិតមែន ដោយយោងតាមការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរកន្លងមក។ ក្រោយពេលចៅក្រមស៊ើបសួរសម្រេចចេញដីកានេះរួចមក ជនត្រូវចោទនឹងក្លាយទៅជាជនជាប់ចោទ។ អ្វីដែលសំខាន់នោះ ដីកានេះបញ្ជូនសំណុំរឿងជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ដើម្បីធ្វើការផ្ដន្ទាទោសចំពោះអំពើដែលជននោះបានប្រព្រឹត្ត ។ ជាងនេះទៅទៀត ការបញ្ជូនទៅជំនុំជម្រះធ្វើឡើងនៅពេលចៅក្រមស៊ើបសួរបិទបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន ដោយបានស្វែងរកភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់បង្ហាញថា ជនត្រូវចោទបានប្រព្រឹត្តនូវបទល្មើសដូចការចោទប្រកាន់ ដើម្បីបញ្ជូនជននោះទៅជំនុំជម្រះ ។ ទន្ទឹមនឹងនេះដែរ ចៅក្រមស៊ើបសួរ ត្រូវចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដើម្បីបញ្ជូនជនជាប់ចោទទៅកាន់តុលាការជំនុំជម្រះពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដោយក្នុងដីកាចៅក្រមស៊ើបសួរត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ នៅក្រោយពេលចេញដីកាដំណោះស្រាយស្ដីពីការបញ្ជូនរឿងទៅជំនុំជម្រះ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនឹងត្រូវបានបញ្ចប់ ហើយសមត្ថកិច្ចបន្ទាប់ គឺស្ថិតនៅក្រោមការដឹកនាំរបស់ចៅក្រមជំនុំជម្រះ ដែលគាត់ជាអ្នកដឹកនាំនីតិវិធីក្នុងដំណាក់កាលជំនុំជម្រះ ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ចៅក្រមស៊ើបសួរ ជាចៅក្រមនៃមន្ទីស៊ើបសួរដែលមានទីតាំងនៅតាមសាលាដំបូងរាជធានី ខេត្តនីមួយៗ ជាអ្នកទទួលបន្ទុក និង ដឹកនាំនៅក្នុងដំណើរការនៃកិច្ចស៊ើបសួរទាំងអស់ ចាប់តាំងពីការចាប់ផ្តើមស៊ើបសួរ រហូតដល់ការបិទបញ្ចប់ការស៊ើបសួរស្វែងរកការពិតនៅក្នុងសំណុំរឿងមួយ។ មូលហេតុដែលនាំឱ្យចៅក្រមស៊ើបសួរធ្វើការបើកការស៊ើបសួរបាន ត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ចែកជា ២ (ពីរ) គឺ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និង ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ មិនត្រឹមតែប៉ុណ្ណោះក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិអំណាចឱ្យចៅក្រមស៊ើបសួរ អាចធ្វើការស៊ើបសួរស្វែងរកការពិត ទាំងដោះបន្ទុក និង ដាក់បន្ទុក។ ការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវធ្វើឡើងដោយខានពុំបានចំពោះបទឧក្រិដ្ឋ និង អាចធ្វើក៏បាន អត់ក៏បាន ចំពោះបទមជ្ឈិម ហើយការស៊ើបសួរត្រូវរក្សាការសម្ងាត់។ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចក្នុងការស្រាវជ្រាវដោយសម្រេចដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យ កោះហៅជនត្រូវចោទមកសួរចម្លើយ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្តាប់ចម្លើយសាក្សី សួរតទល់ ធ្វើការឆែកឆេរ ចាប់យកវត្ថុតាង កោសល្យវិច័យ ស្តាប់ទូរស័ព្ទជាដើម។ នៅក្នុងករណីចាំបាច់ដែលចៅក្រមស៊ើបសួរអាចអនុវត្តកិច្ចនីតិវិធីស៊ើបសួរដោយខ្លួនឯងផ្ទាល់បាន ចៅក្រមស៊ើបសួរអាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួសបាន ដោយដីកានេះចៅក្រមស៊ើបសួរអាចផ្ទេរសមត្ថកិច្ចរបស់ខ្លួនទៅឱ្យ ចៅក្រមស៊ើបសួរនៅតុលាការជាមួយគ្នា ឬ នៅតុលាការផ្សេង និង មន្ត្រីនគរបាលយុត្តិធម៌ អនុវត្តនីតិវិធីជំនួសខ្លួនបាន។ លើសពីនេះទៅទៀតចៅក្រមស៊ើបសួរមានអំណាចបង្ខំ ពោលគឺចៅក្រមស៊ើបសួរមានអំណាចអនុវត្តវិធានការណ៍និរន្តរាយ ដោយចេញដីកាផ្សេងៗទៅតាមគោលដៅជាក់ស្តែងដែលខ្លួនត្រូវការ ដូចជា ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និង ការរក្សាជនត្រូវចោទឱ្យនៅក្រោមការចាត់ចែងរបស់តុលាការដោយ ដីកាឃុំខ្លួនបណ្តោះអាសន្ន និង ដីកាដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ទោះជាយ៉ាងណាក្តីចៅក្រមស៊ើបសួរត្រូវអនុវត្តកិច្ចនីតិវិធីរបស់ខ្លួនដោយហ្មត់ចត់ ទៅតាមនីតិវិធីដែលច្បាប់កំណត់ ដោយសារតែមានសភាពិសេសនៃសាលាឧទ្ធរណ៍ គឺសភាស៊ើបសួរដែលជានាយឋានានុក្រមរបស់ចៅក្រមស៊ើបសួរ ដែលមានសមត្ថកិច្ចត្រួតពិនិត្យការ និង រ៉ាប់រងលើការប្រព្រឹត្តិទៅដ៏ល្អ រាល់អនុវត្តកិច្ចការនានារបស់ចៅក្រមស៊ើបសួរនៃមន្ទីស៊ើបសួរទាំងអស់ដែលនៅក្រមសមត្ថកិច្ចរបស់ខ្លួន។ មិនត្រឹមតែប៉ុណ្ណោះភាគីដែលពាក់ព័ន្ធមានដូចជា ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរដើម្បីប្រឆាំងនឹងដីការបស់ចៅក្រមស៊ើបសួរ និង អាចប្តឹងសុំមោឃភាពចំពោះកិច្ចនីតិវិធី ឬ លិខិតណាមួយរបស់ចៅក្រមស៊ើបសួរបានផងដែរ។ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួររបស់ខ្លួនត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរនឹងជូនដំណឹងដល់ភាគី និង បញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា

ដើម្បីត្រួតពិនិត្យ និង ធ្វើសេចក្តីសន្និដ្ឋានត្រឡប់មកវិញ។ ចៅក្រមស៊ើបសួរបិទបញ្ចប់ការស៊ើបសួររបស់ខ្លួន ដោយចេញដីកាដំណោះស្រាយ ដោយបញ្ជូលទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់។

# អនុសាសន៍

# អនុសាសន៍

យោងតាមរយៈការសិក្សា ស្រាវជ្រាវទៅលើប្រធានបទ **ចៅក្រមស៊ើបសួរ** កន្លងមកយើងខ្ញុំបានពិនិត្យឃើញថា បញ្ញត្តច្បាប់របស់កម្ពុជាពិតជាល្អ និង មានលក្ខណៈប្រសើ ដែលមានការកំណត់បែងចែកយ៉ាងច្បាស់លាស់អំពីតួនាទី សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។ ម្យាងវិញទៀតសិទ្ធិរបស់គូភាគី ក៏ត្រូវបានគោរពបានយ៉ាងហ្មត់ចត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌនេះ។ គ្រប់នីតិវិធីទាំងអស់គឺត្រូវបានគិតគូរ និង ចែងចែកយ៉ាងល្អិតល្អន់ ដោយផ្តល់ឱ្យភាគីនូវយុត្តិធម៌ ឥតលម្អៀង ការគោរពសិទ្ធិ ទំនុកចិត្ត ការពារនូវការបំពានបានយ៉ាងល្អគាប់ប្រសើ។ ប៉ុន្តែបើក្រឡេកទមើលការអនុវត្តកិច្ចនីតិវិធី ឬ ការបំពេញការកាតព្វកិច្ចរបស់អ្នកអនុវត្តវិញ ជាពិសេសអ្នកមានសិទ្ធិអំណាចក្នុងការប្រើប្រាស់នីតិវិធីដើម្បីបំពេញកិច្ចស៊ើបសួរនេះ គឺចៅក្រមស៊ើបសួ យើងឃើញថា មានការខ្វះចន្លោះមួយចំនួនដែលមិនទាន់មានការអនុវត្តឱ្យបានពេញលេញ ហ្មត់ចត់ នៅឡើយទេ។ យើងខ្ញុំសូមសំណូមពរឱ្យមានការអនុវត្តឱ្យមានការបើកការស៊ើបសួរ នីតិវិធីនៃការស៊ើបសួរ ការបិទការស៊ើបសួរ ឱ្យត្រឹមត្រូវទៅតាមនីតិវិធីច្បាប់ និង គោរពនូវក្រមវិជ្ជាជីវៈជាអ្នកវិជ្ជាជីវៈ ដោយធានាឱ្យបាននូវ សេចក្តីថ្លៃថ្នូរ យុត្តិធម៌ តម្លាភាព គោរពសិទ្ធិ ឥតរើសអើង ប្រកាន់បក្សពួក ភក្តីភាព និង ភាពស្មោះត្រង់អស់ពីដួងចិត្ត។ ដំណាក់កាលស៊ើបសួរជាដំណាក់កាលដែលសំខាន់ និង មានភាពស្មុកស្មាញ ក្នុងការសម្តែងឱ្យឃើញនូវការពិតនៅក្នុងអំពើ ឬ បទល្មើសមួយ ដូច្នេះទាមទារឱ្យមានការអនុវត្តដោយយកចិត្តទុកដាក់ ទំនួលខុសត្រូវ មិនត្រូវបំពានតួនាទី និង សមត្ថកិច្ចនោះទេ។ យើងខ្ញុំសូមឱ្យមានការគោរពសិទ្ធិភាគីឱ្យបានហ្មត់ចត់ ទៅតាមវិធានច្បាប់ដែលបានកំណត់ចែងរបស់កម្ពុជា ក៏ជាសន្ធិសញ្ញា កតិកាសញ្ញាផ្សេងៗដែលកម្ពុជាបានទទួលស្គាល់ ដូចជាការគោរពសិទ្ធិជនត្រូវចោទ ជាពិសេសការគោរពសិទ្ធិជនត្រូវចោទដែលជាអនីតិជន ហើយការអនុវត្តនីតិវិធីសូមជៀសវាងឱ្យបាននូវការអូសបន្លាយពេលវេលានៃរឿងក្តី និង សូមប្រាប់ជនត្រូវចោទអំពីសិទ្ធិដែលគាត់មាន។ ចំពោះនីតិវិធីនៃការស៊ើបសួរដូចជា សួរចម្លើយជនត្រូវចោទ ស្តាប់ចម្លើយសាក្សី ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សូមធានាឱ្យបានថាចៅក្រមស៊ើបសួរជាអ្នកសួរ ឬ ស្តាប់ជនទាំងនោះផ្ទាល់ និង មិនត្រូវផ្ទេរសមត្ថកិច្ចស៊ើបសួរនេះទៅបុគ្គលផ្សេងឱ្យអនុវត្តកិច្ចដែលមិនត្រូវបានអនុញ្ញាត្តដោយក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ។ ចំណែកឯការអនុវត្តផ្សេងទៀតដូចជា ការឆែកឆេរ សូមអនុវត្តឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ ជៀសវាងការរំលោភបំពាន និង មានការចេញដីកាឱ្យបានត្រឹមត្រូវ។ វិធានការណ៍និរន្តរាយ សូមអនុវត្តដោយមានមូលហេតុត្រឹមត្រូវ សមស្រប វិនិច្ឆ័យឱ្យបានច្បាស់លាស់កុំឱ្យមានការរំលោភបំពានសិទ្ធិបុគ្គលកើតឡើង។ ដោយឡែកក្នុងការធ្វើកោសលវិច័យ ត្រូវធ្វើឡើងដោយមានអ្នកជំនាញច្បាស់លាស់ និង ត្រូវមានឧបករណ៍បច្ចេកទេត្រឹមត្រូវ។ ដូច្នេះជាចុងក្រោយយើងខ្ញុំសូមស្នើសុំឱ្យមាន ពង្រឹងការបណ្តុះបណ្តាលមន្ត្រីតុលាការ ក៏ដូចជាមន្ត្រីជំនាញផ្សេងឱ្យបានច្រើន និង ជ្រើសរើសយក

អ្នកដែលមានសមត្ថភាពពិតប្រាកដ បង្កើននូវការពង្រឹងវិជ្ជាជីវៈ ត្រួតពិនិត្យឱ្យបានហ្មត់ចត់ និង មានការដាក់ពិន័យរាល់ការបំពាន ឬ កំហុសចេតនាផ្សេងៗ សូមធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់មានទំនុកចិត្តលើតុលាការ។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារច្បាប់

- ❖ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៩
- ❖ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
- ❖ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ❖ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- ❖ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

## ២. ឯកសារមេរៀន

- ❖ មេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណរិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣-២០១៤ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
- ❖ មេរៀននីតិវិធីព្រហ្មទណ្ឌ_កិច្ចសហប្រតិបត្តិការបារាំង គំរោងទ្រទ្រង់នីតិរដ្ឋ រាជបណ្ឌិតសភាវិជ្ជាជីវៈ តុលាការ

## ៣. ឯកសារផ្សេងៗ

- ❖ វីឌីអូនៃកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងកម្មវិធីទូរទស្ស ទទក បកស្រាយដោយ ឯកឧត្តម កើត រិទ្ធ ឯកឧត្តម ផូវ សំភី និង ឯកឧត្តម ប៊ុន ហុន។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

ឧបសម្ព័នទី១៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ឧបសម្ព័នទី២៖ កំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ

ឧបសម្ព័នទី៣៖ កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

ឧបសម្ព័នទី៤៖ កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សី

ឧបសម្ព័នទី៥៖ កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ

ឧបសម្ព័នទី៦៖ ដីកាបង្គាប់ឱ្យចូលខ្លួន

ឧបសម្ព័នទី៧៖ ដីកាបង្គាប់ឱ្យនាំខ្លួន

ឧបសម្ព័នទី៨៖ ដីកាបង្គាប់ឱ្យចាប់ខ្លួន

ឧបសម្ព័នទី៩៖ ដីកាបង្គាប់ឱ្យឃុំខ្លួន

ឧបសម្ព័នទី១០៖ ដីកាសម្រេចឱ្យពន្យាការឃុំខ្លួនបណ្ដោះអាសន្ន

ឧបសម្ព័នទី១១៖ ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ឧបសម្ព័នទី១២៖ ដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន

ឧបសម្ព័នទី១៣៖ លិខិតជូនដំណឹង

ឧបសម្ព័នទី១៤៖ ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

ឧបសម្ព័នទី១៥៖ ដីកាសន្និដ្ឋានស្ថាពរ

ឧបសម្ព័នទី១៦៖ លិខិតជូនដំណឹងស្ដីពីការលើកលែងចោទប្រកាន់

ឧបសម្ព័នទី១៧៖ ដីកាសម្រេចលើកលែងចោទប្រកាន់

ឧបសម្ព័នទី១៨៖ លិខិតជូនដំណឹងស្ដីពីការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

ឧបសម្ព័នទី១៩៖ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

**ឧបសម្ព័នទី១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ៖

**ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០**

លេខ៖ ......................**អ.យ.ទ**

# <u>ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ</u>

យើង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញរបាយការណ៍បញ្ជូនលេខៈ រ.ប.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃក្រសួងមហាផ្ទៃ[99]។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា មានតម្រុយសន្មតបានថា ៖**

| | |
|---|---|
| នាមត្រកូល និងនាមខ្លួន ៖ | ភេទប្រុស អាយុ ១៧ ឆ្នាំ |
| ទីកន្លែងកំណើត | ៖ ភូមិមេសាង ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង |
| លំនៅបច្ចុប្បន្ន | ៖ ក្រុមហ៊ុនសន្តិសុខ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ |
| មុខរបរ | ៖ សន្តិសុខ |
| សញ្ជាតិ | ៖ ខ្មែរ |
| នៅលីវ ☑ | ☐ ប្តីឬប្រពន្ធឈ្មោះ |
| ឪពុកឈ្មោះ ៖ | ម្តាយឈ្មោះ ៖ |

[99] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌

**បានប្រព្រឹត្តអំពើដូចតទៅ**[100] ៖

កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ នៅចំណុចបណ្តោយផ្លូវសហព័ន្ធរុស្សី សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ មានជនសង្ស័យឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ កំពុងរកទិញថ្នាំញៀនយកមកប្រើប្រាស់ ក៏បានជួបនឹងសមត្ថកិច្ច ហើយសមត្ថកិច្ចបាននាំខ្លួនមកមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ដើម្បីធ្វើការសាកសួរ និងធ្វើតេស្តិ៍ស្វែងរកសារធាតុញៀនជាលទ្ធផលវិជ្ជមាន គឺមានសារធាតុមេតំហ្វេតាមីន។ ក្រោយពីធ្វើការសាកសួរទទួលបានលទ្ធផលថា ពេលទិញគ្រឿងញៀនបានយកមកប្រើប្រាស់ គឺជនឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ យកមកចែកគ្នាប្រើប្រាស់ជាមួយមិត្តភក្តិ។ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនសង្ស័យ រួចកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញដើម្បីចាត់ការតែម្តង។

**អំពើខាងលើជាបទល្មើសះ**

- **ប៉ុនប៉ងចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តដោយឈ្មោះ **ចយ** ភេទប្រុស អាយុ១៧ឆ្នាំ ប្រព្រឹត្តចំណុចផ្លូវសហព័ន្ធរុស្សី សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា ២៩ និងមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

បានឃើញមាត្រា **៤៤** និងមាត្រា **១២៤** នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**

សម្រេច

**បើកការស៊ើបសួរលើអង្គហេតុខាងលើ និងះ**

☑ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ[101]

ឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ (**មានខ្លួន**)

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[102]

☑ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[103]

---

100 សេចក្តីសង្ខេបអង្គហេតុ

101 ឈ្មោះជនត្រូវចោទ

102 កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា ២២៣

103 មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចែងនៅក្នុងមាត្រា ២០៥

**១- ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ។**

**២- បង្កាបទល្មើសកុំឱ្យកើតជាថ្មី ។**

ថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី២**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ស៊ើបសួរ ”**ង**”

សំណុំរឿងព្រហ្មទណ្ឌលេខ:

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២០

[illegible]

## <u>កំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ</u>

(មាត្រា**១៤៣** មាត្រា**១៤៥** និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរឆ្នាំពាន់ម្ភៃ ខែមិថុនា ថ្ងៃទីដប់ប្រាំ វេលាម៉ោងដប់បួន និងម្ភៃទីរសៀល។

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក ជាក្រឡាបញ្ជី។

បានបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទនៅក្នុងមន្ទីរស៊ើបសួរ នៅចំពោះមុខយើងជនដែលមានអត្តសញ្ញាណដូចខាងក្រោម:

នាមត្រកូល-នាមខ្លួន: ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ កម្មករសំណង់ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិគោក ឃុំម្រោម ស្រុកអង្គរជ័យ ខេត្តកំពត ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ប្រពន្ធឈ្មោះ (រស់) មានកូនចំនួន ០៣នាក់ ឪពុកឈ្មោះ "រស់" ម្ដាយឈ្មោះ "ស្លាប់" នីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ ។

□ ជននេះបានប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម១០(ដប់)ឆ្នាំដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

□ ជននេះ បានប្រាប់ថា ចេះអាន និងចេះសរសេរភាសាខ្មែរ

□ ជននេះបានប្រាប់ថាមិនចេះអាន និងមិនចេះសរសេរភាសាខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ឈ្មោះនេះ យើងបានប្រាប់ដល់ជននេះឱ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្ដឹងមកយើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: .**ត** ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ ដែលជាហេតុនាំឱ្យជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ និងការឃុំខ្លួន បណ្ដោះអាសន្នតាមដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ.......................ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។

ជនត្រូវចោទអមដោយលោក.....................................ជាមេធាវី

យើងបានសួរចម្លើយឈ្មោះនេះ ហើយឈ្មោះនេះបានឆ្លើយប្រាប់យើងដូចខាងក្រោមថាៈ

**សួរ-ឆ្លើយៈ** ខ្ញុំអាចឆ្លើយដោយខ្លួនឯងបានដោយពុំចាំបាច់មានមេធាវី។

**សួរ-ឆ្លើយៈ** ខ្ញុំបាទសូមរក្សាទុកនូវចម្លើយដែលខ្ញុំបាទបានឆ្លើយនៅចំពោះមុខសមត្ថកិច្ច និងតំណាងអយ្យការទុកជាបានការដដែលដោយគ្មានការកែប្រែ។

<u>**សួរ-ឆ្លើយៈ**</u> កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១៥ និង០០នាទី ខ្ញុំបាទបានទៅទិញគ្រឿង

ញៀនពីមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែល២០ឆ្នាំជាង សម្បុរខ្មៅ សម្បុរខ្មៅស្រអែម កំពស់ប្រហែលមួយម៉ែត្រហុកសិប ពុំស្គាល់អាសយដ្ឋាននោះទេ នៅម្តុំសំណង់អណាធិបតេយ្យមាត់ទន្លេមុខផ្សារតូច ចំនួន ២កញ្ចប់ ក្នុងតម្លៃ **១០០ ០០០៛**(ដប់ម៉ឺនរៀល) ដើម្បីយកទៅប្រើប្រាស់ផ្ទាល់ខ្លួន។ លុះពេលខ្ញុំបាទទិញគ្រឿងញៀនខាងលើបានហើយ ខ្ញុំបាទក៏បានយកគ្រឿងញៀនខាងលើទៅលាក់ទុកនៅនឹងម្ជុកការពារសុវត្ថិភាព និងបានធ្វើដំណើរត្រឡប់មកផ្ទះវិញ ស្រាប់តែធ្វើដំណើរមកដល់ចំណុចភូមិផ្សារតូច សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បានជួបសមត្ថកិច្ចប៉េអឹមនៅតាមផ្លូវ និងបានហៅខ្ញុំបាទឱ្យឈប់ ហើយបានឆែកឆេររកឃើញគ្រឿងញៀនចំនួន ២កញ្ចប់ ដែលខ្ញុំបាទលាក់ទុកនៅក្នុងម្ជុកការពារសុវត្ថិភាព ក៏បានបញ្ជូនខ្ញុំបាទមកកាន់សាលាដំបូងរាជធានីភ្នំពេញតែម្តង។

<u>**សួរ-ឆ្លើយៈ**</u> ខ្ញុំបាទចេះប្រើប្រាស់គ្រឿងញៀនរយៈពេលមួយឆ្នាំមកហើយ។

<u>**សួរ-ឆ្លើយៈ**</u> ខ្ញុំបាទមិនមែនជាអ្នកជួញដូរគ្រឿងញៀនទេ គឺគ្រាន់តែជាអ្នកប្រើប្រាស់គ្រឿងញៀនប៉ុណ្ណោះ។

<u>**សួរ-ឆ្លើយៈ**</u> ចំពោះគ្រឿងញៀនដែលសមត្ថកិច្ចដកហូតចំនួន ២កញ្ចប់ គឺពិតជារបស់ខ្ញុំបាទប្រាកដមែន ហើយគ្រឿងញៀន គឺខ្ញុំបាទបានទិញពីមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ ចំនួន **១០០ ០០០៛**(ដប់ម៉ឺរៀល)។

**សួរ-ឆ្លើយៈ** ខ្ញុំសំណូមពរតុលាការឱ្យជួយបន្ធូបន្ថយទោសឱ្យខ្ញុំបាទផង និងសូមសន្យាថា ឈប់ប្រើប្រាស់គ្រឿងញៀន និងអំពើខុសច្បាប់ផ្សេងៗទៀតហើយ។

□ យើងបានឱ្យជនត្រូវចោទឱ្យអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួនដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេឱ្យចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។

□ បានអានឱ្យស្តាប់ចប់សព្វគ្រប់ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើងនិងក្រឡាបញ្ជី។

□ បានអាចចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាឬផ្តិតមេដៃជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ។

**ជនត្រូវចោទ** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ឧបសម្ព័នទី៣**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

**មន្ទីរស៊ើបសួរ "ង"**
សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២០
សំណុំរឿងស៊ើបសួរលេខ
ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២០

## កំណត់ហេតុ

## ស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

(មាត្រា**១៥០** និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃមួយ ខែកុម្ភៈ ថ្ងៃទីពីរ វេលាម៉ោងប្រាំបួន និងដប់ប្រាំនាទីព្រឹក។

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក ជាក្រឡាបញ្ជី។

បានមកបង្ហាញខ្លួនក្នុងនាមជា**ដើមបណ្តឹងរដ្ឋប្បវេណី** នៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើងជនដែលមានអត្តសញ្ញាណដូចខាងក្រោមៈ

ឈ្មោះ អត្តលេខ ២១២៤T និងកញ្ញាមេធាវី អត្តលេខ ១៩១៤ ជាសមាជិកមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងការិយាល័យមេធាវី **ប៊ុន និងសហការី** ដែលមានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ២៩ ផ្ទះលេខ២៩៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមហ៊ុន

□ ជននេះ □ចេះនិយាយ □ចេះអាន □ចេះសរសេរអក្សរខ្មែរ

□ ជននេះ[104] □ មិនចេះអាននិយាយ □ មិនចេះអាន □មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឱ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវ ដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ ២០២០។

យើងបានសួរ និងស្តាប់ចម្លើយឈ្មោះនេះដូចខាងក្រោមថាៈ

**សួរៈ** តើលោកមេធាវី និងកញ្ញា មានលិខិតផ្ទេរសិទ្ធិពីដើមបណ្តឹងរដ្ឋប្បវេណី( ដែរឬទេ?

**ឆ្លើយៈ** យើងខ្ញុំមានលិខិតផ្ទេរសិទ្ធិពីដើមបណ្តឹងរដ្ឋប្បវេណី( ) តាមរយៈលិខិតពឹងពាក់មេធាវី និងផ្ទេរសិទ្ធិ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។

**សួរៈ** សូមលោកមេធាវី និងកញ្ញាមេធាវីរៀបរាប់អំពីរឿងហេតុ ដែលបានកើតឡើងទាក់ទងរឿងក្រុមហ៊ុន ប្តឹងពីឈ្មោះ ?

**ឆ្លើយៈ** កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ ឈ្មោះ ភេទស្រី អាយុ ៣៦ឆ្នាំ បានចូលមកបំរើការងារនៅក្រុមហ៊ុន មានតួនាទីជាបុគ្គលិកផ្នែកលក់ ដោយមានភារកិច្ចលក់គ្រឿងឧបភោគ ដែលមានដូចជា

---

104 ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

**១៧។** ទៅឱ្យអតិថិជន នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប។ បន្ទាប់មកនៅអំឡុងខែវិច្ឆិកា ឆ្នាំ២០២០ ឈ្មោះ បានលក់គ្រឿងឧបភោគ ទៅឱ្យអតិថិជន ប៉ុន្តែឈ្មោះនេះមិនបានប្រគល់ប្រាក់ដែលបានពីអតិថិជន មកឱ្យក្រុមហ៊ុនវិញនោះទេ គឺឈ្មោះ បានយកលុយខាងលើទៅចាយវាយផ្ទាល់ខ្លួនទៅវិញ។ លុះមកដល់ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ២០២០ ផ្នែកគណនេយ្យរបស់ក្រុមហ៊ុនបានពិនិត្យឃើញថា ឈ្មោះ បានទទួលប្រាក់ពីអតិថិជនរួចហើយ ប៉ុន្តែឈ្មោះ មិនព្រមប្រគល់ប្រាក់មកឱ្យក្រុមហ៊ុនវិញ ទើបក្រុមហ៊ុនបានប្ដឹងទៅសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលភ្នំពេញថ្មី ធ្វើការសាកសួរ និងដាក់ពាក្យបណ្ដឹងមកតុលាការតាមនីតិវិធីច្បាប់។

**សួរ៖** តើទឹកប្រាក់ដែលឈ្មោះ គៃបំបាត់ពីក្រុមហ៊ុនមានចំនួនប៉ុន្មាន?

**ឆ្លើយ៖** ទឹកប្រាក់ដែលឈ្មោះ គៃបំបាត់ពីក្រុមហ៊ុនមានចំនួន **៩២១៤.៩៧$** (ប្រាំបួនពាន់ពីររយដប់បួនដុល្លារអាមេរិក និងប៉ែតសិបប្រាំពីរសេន)។

យើងខ្ញុំស្នើសុំដល់តុលាការ ផ្ដន្ទាទោសឈ្មោះ តាមផ្លូវច្បាប់ និងស្នើសុំតុលាការសម្រេចឱ្យឈ្មោះ សងប្រាក់ដែលយកពីក្រុមហ៊ុនចំនួន **៩២១៤.៩៧$** (ប្រាំបួនពាន់ពីររយដប់បួនដុល្លារអាមេរិក និងប៉ែតសិបប្រាំពីរសេន) ព្រមទាំងសំណងជម្ងឺចិត្តជាប្រាក់ចំនួន **២០ ០០០ ០០០៛** (ម្ភៃលានរៀល)។

☐យើងបានឱ្យដើមបណ្ដឹងឱ្យអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬផ្ដិតមេដៃ លើកំណត់ហេតុនេះ។

☐បានអានចប់សព្វគ្រប់ ហើយដើមបណ្ដឹងរដ្ឋប្បវេណីមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយ យើង និងក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយដើមបណ្ដឹងរដ្ឋប្បវេណីមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្ដិតម្រាមដៃជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ។[៤]

**មេធាវី** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី៤**

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

**មន្ទីរស៊ើបសួរ "ង"**
សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី**៣** ខែ**វិច្ឆិកា** ឆ្នាំ**២០២០**
ស៊ើបសួរលេខ
ចុះថ្ងៃទី**៤** ខែ**វិច្ឆិកា** ឆ្នាំ**២០២០**

## កំណត់ហេតុ

## ស្តីពីការស្តាប់ចម្លើយសាក្សី

(មាត្រា**១៥៣** និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃ ខែធ្នូ ថ្ងៃទីប្រាំបី វេលាម៉ោងដប់ និងដប់នាទីព្រឹក។

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក ជាក្រឡាបញ្ជី។

បានមកបង្ហាញខ្លួនក្នុងនាមជាសាក្សីនៅក្នុងមន្ទីរស៊ើបសួរ នៅចំពោះមុខយើងជនដែលមានអត្តសញ្ញាណដូចខាងក្រោមៈ

ឈ្មោះ ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ បុគ្គលិកនៅតាមក្លឹប សាសនាព្រះពុទ្ធ ទីកន្លែងកំណើតខណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះលេខ២៣៥ ក្រុម៣ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ ស្រីពេជ្រ មានកូន ០១នាក់ (លែងលះ) ឪពុកឈ្មោះ "ស្លាប់" ម្តាយឈ្មោះ "រស់" ជានីតិជន ប្រវត្តិផ្តន្ទាទោស គ្មាន។

☐ ជននេះ ☐ចេះនិយាយ ☐ចេះអាន ☐ចេះសរសេរអក្សរខ្មែរ

☐ ជននេះ[105] ☐ មិនចេះអាននិយាយ ☐ មិនចេះអាន ☐មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឱ្យដឹងយ៉ាង ច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី៤ ខែវិច្ឆកា ឆ្នាំ២០២០។

☐ ជននេះបានស្បថរួចហើយ

☐ ជននេះមិនព្រមស្បថ[106]

☐ សាក្សីត្រូវបានអនុញ្ញាតឱ្យរួចពីសម្បថ

យើងបានសួរ និងស្តាប់ចម្លើយឈ្មោះនេះដូចខាងក្រោមថាៈ

**សំណួរៈ** ចូរលោករៀបរាប់អំពីអង្គហេតុដែលលោកបានឃើញ នៅថ្ងៃកើតហេតុ?

**ចម្លើយៈ** កាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ៨ព្រឹក ខ្ញុំបាទកំពុងតែដេកនៅក្នុងផ្ទះ ស្រាប់តែពេលនោះ ម្តាយរបស់នាងខ្ញុំឈ្មោះ និងប្អូនស្រីឈ្មោះ បានស្រែកថា "ពូណាងចាក់ម៉ាក់ហើយៗ" បន្ទាប់

---

[105] ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

[106] ក្នុងករណីដែលជននេះមិនព្រមស្បថ ចម្លើយរបស់ជននេះគ្រាន់តែជាពត៌មានធម្មតា

មកខ្ញុំបាទក៏ក្រោកឡើង ឃើញម្ដាយរបស់ខ្ញុំបាទ មានកាំបិតជាប់នៅនឹងខ្នង ហើយខ្ញុំបាទក៏បានស្ទុះទៅចាប់ពូឈ្មោះ

ដើម្បីប្រគល់ជូនសមត្ថកិច្ច និងបានជូនម្ដាយរបស់ខ្ញុំបាទយកទៅព្យាបាលជម្ងឺនៅមន្ទីរពេទ្យ។

**សំណួរ៖** តើមូលហេតុអ្វីបានជាឈ្មោះ ជា សំណាង យកកាំបិតទៅចាក់លើឈ្មោះ ជា សុភាព?

**ចម្លើយ៖** មូលហេតុកបណ្ដាលមកពីពូឈ្មោះ ជា សំណាង ខឹងនឹងម្ដាយរបស់ខ្ញុំមិនឱ្យគាត់ផឹកស្រា។

☐ យើងបានឱ្យសាក្សីឱ្យអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខា ឬផ្ដិតមេដៃ លើកំណត់ហេតុនេះ។

☐ បានអានចប់សព្វគ្រប់ ហើយសាក្សីមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយ យើង និង ក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយសាក្សីមិនមានបដិសេធចំណុចណាទេ និងបានចុះ ហត្ថលេខា ឬផ្ដិតមេដៃជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ។[៤]

**សាក្សី** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី៥**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ស៊ើបសួរ “**ង**”

សំណុំរឿងព្រហ្មទណ្ឌលេខ

ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១

## កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ

(មាត្រា**២០៣** និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

**ឆ្នាំពីរពាន់ម្ភៃមួយ ខែមករា ថ្ងៃទីដប់បួន វេលាម៉ោងដប់បួន និងសាមសិបនាទីរសៀល។**

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក ជាក្រឡាបញ្ជី។

បុគ្គលដែលនៅចំពោះមុខយើងបានផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖

នាមត្រកូល-នាមខ្លួន: ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅស្រុកព្រះស្ដេច ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួនមិនពិតប្រាកដ ប្រពន្ធឈ្មោះ កូនគ្មាន ឪពុកឈ្មោះ "រស់" ម្ដាយឈ្មោះ កម្រិតវប្បធម៌ រៀនថ្នាក់ទី១២ "រស់" ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ **គ្មាន។**

តើអ្នកឯងចេះអាននិងសរសេរភាសាខ្មែរដែរឬទេ?

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ **លួច**(**ម៉ូតូ**) ប្រព្រឹត្តនៅចំណុចផ្លូវព្រះស៊ីសុវត្ថិ ភូមិ៣ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិតាមមាត្រា**៣៥៣** ចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៦** នៃក្រមព្រហ្មទណ្ឌ។

□ ដោយមានលោក/លោកស្រីមេធាវី ............... ដែលជនត្រូវចោទបានជ្រើសរើសពឹងពាក់ដោយខ្លួនឯង ឬដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានមកបង្ហាញខ្លួននៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះមើលសំណុំរឿង និងបានធ្វើទំនាក់ទំនងដោយសេរីជាមួយនឹងជនត្រូវចោទនៅពេលបង្ហាញខ្លួនជាលើកដំបូង។

យើងបានប្រាប់ដល់ជនត្រូវចោទថា៖

-យើងមានបំណងសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន។

-ជនត្រូវចោទអាចស្នើសុំពន្យារពេលដើម្បីរៀបចំការពារខ្លួន។

-យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ននៅថ្ងៃនេះ។

ជនត្រូវចោទបានប្រកាសប្រាប់ថាៈ.........................................................................................................
.........................................................................................................។

ការពិភាក្សាដេញដោលចំពោះមុខទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នៈ

 ត្រូវបានធ្វើ

 ត្រូវបានលើកទៅថ្ងៃទី........ខែ.............ឆ្នាំ............តាមសំណូមពររបស់.................

តំណាងអយ្យការបានបង្ហាញនូវសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោមៈ

.........................................................................................................................................
.....................................................................................................។

ជនត្រូវចោទបានបង្ហាញសេចក្តីសង្កេតរបស់ខ្លួនដូចខាងក្រោមៈ...........................................................
.......................................................................................................... ។

លោក-លោកស្រីមេធាវី.........................................បានបង្ហាញសេចក្តីសន្និដ្ឋានការពារដូចខាងក្រោមៈ
..........................................................................................................

..............................................................................................................................។

យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួននៅថ្ងៃនេះ។

 យើងបានអញ្ជើញជនត្រូវចោទឱ្យអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួនដែលយើងបានកត់ចម្លងក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេឱ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

 បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចទេ និងបានចុះហត្ថលេខាជាមួយយើងនិងក្រឡាបញ្ជី។

 បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើងក្រឡាបញ្ជីនិងអ្នកបកប្រែ។

**ជនត្រូវចោទ** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី៦**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រឡាបញ្ជី

បន្ទប់ ដ ជាន់ទី៤

Tel:

**សាលាដំបូងរាជធានីភ្នំពេញ**

## <u>ដីកាបង្គាប់ឱ្យចូលខ្លួន</u>

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** មាត្រា**១៨៦** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**-បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** សំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ដែលបានចោទប្រកាន់លើ

ឈ្មោះ **ស៊ា ណារី** ភេទស្រី អាយុ ៣៨ឆ្នាំ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៦០៩៥២៥៦១ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៥០ ផ្លូវលេខ០៩ (បុរីពិភពថ្មីទួលសង្កែ) សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

ពីបទ: **លួចលក់អចលនវត្ថុរបស់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា**២៥៥** នៃច្បាប់ភូមិបាល។

## <u>បង្គាប់មក</u>

ឈ្មោះ ភេទស្រី អាយុ ៣៨ឆ្នាំ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៦០៩៥២-៥៦១ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៥០ ផ្លូវលេខ០៩ (បុរីពិភពថ្មីទួលសង្កែ) សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ជានីតិជន។

ឱ្យចូលមកកាន់ **សាលាដំបូងរាជធានីភ្នំពេញ បន្ទប់ “ង” ជាន់ទី៤** នៅថ្ងៃទី**.......** ខែ**សីហា** ឆ្នាំ**២០២០** វេលាម៉ោង......... និង**..........**នាទីព្រឹក/រសៀល ដើម្បីសាកសួរពីដំណើររឿង: **លួចលក់អចលនវត្ថុរបស់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា**២៥៥** នៃច្បាប់ភូមិបាល។

សាមីខ្លួនត្រូវយកលិខិតផ្សេងៗដែលទាក់ទងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមានក្នុងករណីមិនចូល ខ្លួនតាមកាលកំណត់ខាងលើនេះទេ ***<u>យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន</u>*** ។

ថ្ងៃ.........................ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី........... ខែ............... ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

យើង........................................ជា.......

ដីកាបង្គាប់ឱ្យចូលខ្លួននេះអោយឈ្មោះ...........................................................

លេខ...............ផ្លូវ..............ភូមិ.......................ឃុំ-សង្កាត់...................ស្រុក-ខណ្ឌ .................... ខេត្ត-រាជធានី......... នៅថ្ងៃទី........ខែ...........ឆ្នាំ២០២០ ហើយយើងបានប្រាប់ថាសាមីខ្លួនត្រូវប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលដែលខ្លួនចូលទៅចំពោះមុខសាលាដំបូងរាជធានីភ្នំពេញ។

**<u>អ្នកទទួល</u>** **<u>អ្នកប្រគល់</u>**

**ហត្ថលេខា ឬផ្តិតមេដៃ**

**ឧបសម្ព័ន្ធទី៧**

# ព្រះរាជាណាចក្រកម្ពុជា

ក្រឡាបញ្ជី

## ជាតិ សាសនា ព្រះមហាក្សត្រ

បន្ទប់ ដ ជាន់ទី៤

**សាលាដំបូងរាជធានីភ្នំពេញ**

## ដីកាបង្គាប់ឱ្យនាំខ្លួន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** មាត្រា**១៨៩** និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**បានឃើញ** សំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

ដែលចោទប្រកាន់លើឈ្មោះ ភេទស្រី អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ ប្រធានក្រុមហ៊ុន ទីកន្លែងកំណើតភូមិកោះចំរើន ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នផ្ទះលេខ៣ បុរីឌីផ្លូវ៉ា វិថីឌីផ្លូវ៉ា១ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្តីឈ្មោះ (លែងលះ)"រស់" មានកូន ០២នាក់ ឪពុកឈ្មោះ "ស្លាប់" ម្តាយឈ្មោះ "ស្លាប់" ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ពីបទ៖ **ឆបោក និងមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ និងថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៧៧** និងមាត្រា**៣៧៨** នៃក្រមព្រហ្មទណ្ឌ និងមាត្រា**២៣១** នៃច្បាប់ស្តីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

**បានឃើញ** ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ជនត្រូវចោទមិនព្រមចូលខ្លួនតាមការកោះហៅរបស់តុលាការឡើយ **ហេតុដូច្នេះ** ដើម្បីធានាដល់ការស៊ើបសួរឱ្យបានពេញលេញ គប្បីសម្រេចនាំខ្លួនឈ្មោះ ភេទស្រី អាយុ ៤៧ឆ្នាំ មកចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីបំភ្លឺការពិត។

ហេតុដូច្នេះសម្រេច

**១**-ឱ្យនាំខ្លួនឈ្មោះ ភេទស្រី អាយុ ៤៧ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើនេះ។

**២**-បង្គាប់មកកងកម្លាំងសាធារណៈ ឱ្យនាំខ្លួនឈ្មោះខាងលើនេះមកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញឱ្យបានមុន**ថ្ងៃទី**...... **ខែ**........... **ឆ្នាំ២០២១** ដើម្បីចាត់ការតាមច្បាប់។

**៣**-បុគ្គលនេះត្រូវតែនាំទៅបង្ហាញខ្លួនយ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ។

ថ្ងៃ........................... ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី....... ខែវិច្ឆិកា ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី៨**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

ក្រឡាបញ្ជី

បនប់ "ង" ជាន់ទី៤

បន្ទប់ស៊ើបសួរ **"ង"**

លេខ.............. "ង" ដ.ច.ន

# **<u>ដីកាបង្គាប់ឱ្យចាប់ខ្លួន</u>**

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** មាត្រា**១៩៥** និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨របស់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** សំណុំរឿងស៊ើបសួរលេខៈ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាបង្គាប់ឱ្យចូលខ្លួនលេខៈ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

ក្រោយពីបានពិនិត្យលើសំណុំរឿងចប់សព្វគ្រប់ ឃើញថាៈ

**១**-ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៣៣ ផ្លូវលេខ១៣២ សង្កាត់ផ្សារដេប៉ូ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ត្រូវដាក់ក្រោមការត្រួតពិនិត្យពីបទៈ **ធ្វើឱ្យខូចខាតដោយចេតនា និងគំរាមកំហែងថាសម្លាប់** ប្រព្រឹត្តនៅចំណុច ផ្ទះលេខ១២អា ផ្លូវលេខ១ បុរីលឹមឈាងហោ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា**៤១០** មាត្រា**៤១១** និងមាត្រា**២៣៣** នៃក្រមព្រហ្មទណ្ឌ។

**២**-យល់ឃើញថាៈ តាមចំណាររបស់មន្ត្រីអនុវត្តដីកាបានបញ្ជាក់ថា ជនត្រូវចោទបានចេញពីលំនៅឋាន បច្ចុប្បន្នមិនដឹងរស់នៅទីណា។ តំណាងអយ្យការ ស្នើសុំឱ្យចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនត្រូវចោទ តាមនីតិវិធី ព្រោះជនត្រូវចោទមានសាវតាជាតិគ្រប់គ្រាន់។

**៣**-យល់ឃើញថាៈ ដើម្បីធានាដល់ការស៊ើបសួរឱ្យបានពេញលេញ គប្បីសំរេចឱ្យចាប់ខ្លួនឈ្មោះ ភេទប្រុស អាយុ ៣៣ឆ្នាំ យកមកចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីបំភ្លឺការពិតក្នុងរឿងក្តីនេះ។

<u>ហេតុដូច្នេះសម្រេច</u>

**១**-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ ភេទប្រុស អាយុ ៣៣ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើនេះ។

**២**-បញ្ជូនដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ខ្លួន និងនាំខ្លួនឈ្មោះខាងលើនេះមកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់។

**៣**-ឱ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់សហការអនុវត្តឱ្យបានល្អ នៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

ថ្ងៃ.......................ខែ............ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......... ខែ............ ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័នទី៩**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

## ដីកាបង្គាប់ឱ្យឃុំខ្លួន

បន្ទប់ស៊ើបសួរ "ង"

លេខ:............. **"ង" ង.ឃ.ង**

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** មាត្រា២០៦ មាត្រា**២១៩** មាត្រា**២២០** មាត្រា**២២១** និងមាត្រា**២២២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ដែលទាក់ទងនឹង៖

ឈ្មោះ ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិក្រូច ឃុំស្វាយភ្លើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់ផ្ទះជួល ភូមិទួលពង្រ សង្កាត់ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ កម្រិតវប្បធម៌ រៀនថ្នាក់ទី៧ "រស់" ជានីតិជន។

**ឃាត់ខ្លួននៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០។**

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **គ្មាន ។**

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **លួចមានស្ថានទម្ងន់ទោស(ឆក់ទូរសព្ទ)** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិកន្ទោកខាងត្បូង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិតាមមាត្រា**៣៥៣** ចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

-**បានឃើញ** ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ:........... "ង"ង.ព.ស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០។

<u>បង្គាប់</u>

**១**-ឱ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ ភេទប្រុស អាយុ ២៥ឆ្នាំ **ទៅមណ្ឌលអប់រំកែប្រែទី១(ម១)** ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់។

**២**-ឱ្យ**មណ្ឌលអប់រំកែប្រែទី១(ម១)** ទទួល និងឃុំខ្លួនជននេះ រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

**៣**-ឱ្យគ្រប់ភ្នាក់ងារនៃកម្លាំងសាធារណៈទាំងអស់សហការអនុវត្តឱ្យបានល្អ នៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

ថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១០**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ “**ង**”

លេខ........................ង.ព.ស **<u>ដីកាសម្រេចឱ្យពន្យារការឃុំខ្លួនបណ្តោះអាសន្ន</u>**

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

អមដោយលោក ជាក្រឡាបញ្ជី។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** សំណុំរឿងស៊ើបសួរលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

**<u>ដែលទាក់ទងនឹងជនត្រូវចោទៈ</u>**

ឈ្មោះ ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ រើសអេតចាយ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិសំរោង ឃុំពន្លៃ ស្រុកអង្គបូរី ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅបន្ទប់ជួលផ្លូវលំ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ
‹‹ស្លាប់›› ម្តាយឈ្មោះ ‹‹ស្លាប់›› ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ជននេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា**៤0** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**យល់ឃើញថា៖** ជននេះត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈឹម ដែលច្បាប់ដាក់ពន្ធនាគារស្មើ ឬលើសពី ១ឆ្នាំ។

**យល់ឃើញថា៖** ការពិភាក្សាដេញដោលចំពោះមុខត្រូវធ្វើឡើងតាមនីតិវិធីរួចរាល់ហើយ។

**យល់ឃើញថា៖** កាតព្វកិច្ចទាំងឡាយនៃការត្រួតពិនិត្យតាមផ្លូវតុលាការមានលក្ខណៈមិនគ្រប់គ្រាន់ដោយធៀបនឹងគោលដៅ ដែលមានចែងក្នុងមាត្រា**២០៣** និងមាត្រា**២០៥** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**យល់ឃើញថា៖** ការឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ គឺជាមធ្យោបាយតែមួយគត់ដើម្បី ៖

-រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ

-រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

-បញ្ចប់ ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី

-រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

-ធានារក្សាជនត្រូវចោទទុកជូនតុលាការតាមនីតិវិធី

-ធានារក្សាសណ្ដាប់ធ្នាប់សាធារណៈ

-កុំឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស។

## <u>ហេតុដូច្នេះសម្រេច</u>

-ពន្យារឃុំខ្លួនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ៣០ឆ្នាំ ជាបណ្ដោះអាសន្ន ហើយយើងនឹងបង្គាប់ឱ្យពន្យារការឃុំខ្លួនជននេះតាមអំណាចដីកាបង្គាប់ឱ្យពន្យារឃុំខ្លួន។

ថ្ងៃ........................... ខែ............... ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ........... ខែសីហា ឆ្នាំ២០២០

**ក្រឡាបញ្ជី** ចៅក្រមស៊ើបសួរ

<u>**បានទទួលដំណឹងរួចហើយ**</u>

រាជធានីភ្នំពេញ ថ្ងៃទី........ ខែសីហា ឆ្នាំ២០២០

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី១១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឡាយ លីចេង

បន្ទប់ "ង" ជាន់ទី៤

**សាលាដំបូងរាជធានីភ្នំពេញ**

**ចៅក្រមស៊ើបសួរ "ង"**

លេខ៖............ "ង" ដ.ស.ព

**<u>ដីកាសម្រេច</u>**

**<u>ដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ</u>**

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី ជាក្រឡាបញ្ជី។

-**បានឃើញ** មាត្រា ២២៣ និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ ។

-**បានឃើញ** សុំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ ។

-**បានឃើញ** ដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នលេខ........................"ង"ព.ស.ព ចុះថ្ងៃទី .........ខែមិថុនា ឆ្នាំ២០២០ ។

-**បានឃើញ** ដីកាបង្គាប់ឱ្យដោះលែងលេខ.............. "ង" ដ.ឃ.ដ ចុះថ្ងៃទី........ខែមិថុនា ឆ្នាំ២០២០ ។

<u>សំអាងហេតុ</u>

**១/. យល់ឃើញថា** ជនត្រូវចោទឈ្មោះ (ZHENG HAI CHENG) ភេទប្រុស អាយុ៣៧ ឆ្នាំ ជនជាតិចិន ត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ ឆបោក ប្រព្រឹត្តនៅចំណុចមហាវិថីសហ ព័ន្ធរុស្សីទល់មុខអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពី ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រ កម្ពុជា ។

**២/. យល់ឃើញថា** ជនត្រូវចោទត្រូវបានសម្រេចអនុញ្ញាតឱ្យមានសេរីភាពជាបណ្តោះអាសន្ន ។

**៣/. យល់ឃើញថា** ដើម្បីធានាជនត្រូវចោទមានវត្តមានចំពោះមុខតុលាការ និងដើម្បីជៀសវាងការរាំងស្ទះ ដល់ការស៊ើបសួរ គប្បីសម្រេចដាក់ជនត្រូវចោទឱ្យជាប់កាតព្វកិច្ចស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

<u>ហេតុដូច្នេះសម្រេច</u>

ដាក់ជនត្រូវចោទឈ្មោះ                (ZHENG HAI CHENG) ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិ ចិន ទីកន្លែងកំណើតនៅស្រុកមុីចូវស៊ីងលីង ខេត្តគ័រតុង ប្រទេសចិន ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះលេខ២៧$E_0$ ផ្លូវលេខ២៨០ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ដែលត្រូវចោទប្រកាន់ពីបទ៖              ប្រព្រឹត្តនៅចំណុចមហាវិថីសហព័ន្ធរុស្សីទល់មុខអាកាសយាន ដ្ឋានអន្តរជាតិភ្នំពេញ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ ។

**<u>ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងតម្រូវឱ្យគោរពកាតព្វកិច្ចដូចខាងក្រោម៖</u>**

**ក**. មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

**ខ**. មិនត្រូវចេញក្រៅព្រំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាត ។

**គ**. ត្រូវចូលបង្ហាញខ្លួននៅសាលាដំបូងរាជធានីភ្នំពេញក្នុងរយៈពេល ០១ (មួយ) ខែ ម្តងរៀងរាល់សប្តាហ៍ទី៤ ក្នុងខែនីមួយៗ នៅបន្ទប់ "ដ"ជាន់ទី៤ ។

**ឃ**. ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

**ង**. មិនត្រូវធ្វើសកម្មភាពផ្គត់ផ្គង់សេវា ឬលក់ទិញ ឬផ្សាយពាណិជ្ជកម្មផ្នែកវេជ្ជសាស្រ្តពាក់ព័ន្ធ នឹងជម្ងឺរលាកផ្លូវដង្ហើម (COVID-19) ជាដាច់ខាត ។

ប្រសិនបើជនត្រូវចោទ គេចវេសដោយចេតនាពីកាតព្វកិច្ចដូចបានកំណត់ខាងលើយើងនឹងសម្រេចឃុំខ្លួន ជនត្រូវចោទជាថ្មីឡើងវិញ តាមបញ្ញត្តិមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ។

| | |
|---|---|
| ***បានទទួលសំណើ*** | *ថ្ងៃ...........................ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤* |
| *ថ្ងៃ...........................ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤* | រាជធានីភ្នំពេញ, ថ្ងៃទី.......ខែមិថុនា ឆ្នាំ២០២០ |
| រាជធានីភ្នំពេញ, ថ្ងៃទី...... ខែមិថុនា ឆ្នាំ២០២០ | **ក្រឡាបញ្ជី        ចៅក្រមស៊ើបសួរ** |
| **តំណាងអយ្យការ** | |

**ឧបសម្ព័ន្ធទី១២**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

បន្ទប់ "ង" ជាន់ទី៤

**សាលាដំបូងរាជធានីភ្នំពេញ**

## ដីកាសម្រេច

## អនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្ន

យើង កេត សុជាតិ ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី។

-**បានឃើញ** មាត្រា**២១៥** មាត្រា**២១៦** មាត្រា**២១៧** និងមាត្រា**២១៨** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** សុំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ពាក្យសុំអនុញ្ញាតនៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ របស់ឈ្មោះ ភេទប្រុស អាយុ ២៧ឆ្នាំ។

-**បានឃើញ** ដីកាបញ្ជូនឱ្យឆ្លើយ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**ក្រោយពីបានពិនិត្យលើសំណុំរឿងចប់សព្វគ្រប់**

យល់ឃើញថា

១-តាមពាក្យសុំអនុញ្ញាតនៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ របស់ឈ្មោះ ភេទប្រុស អាយុ ២៧ឆ្នាំ ដែលជាជនត្រូវចោទបានស្នើសុំឱ្យតុលាការសម្រេចអនុញ្ញាតឱ្យខ្លួននៅ ក្រៅឃុំបណ្តោះអាសន្នដោយហេតុថា៖ ការឃុំខ្លួនជាបណ្តោះអាសន្ន គឺបណ្តាលឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារគ្មាន អ្នករកស៊ីចិញ្ចឹមគ្រួសារ ដោយខ្លួន

សន្យាថា មិនគេចវេសទៅណា នឹងចូលខ្លួនតាមការកំណត់ក្នុងនីតិវិធីរបស់តុលាការនៅពេលដែលមានដីកាកោះហៅ និងមិនផ្លាស់ប្តូរអាសយដ្ឋានដោយមិនមានការអនុញ្ញាតឡើយ ដូចនេះ **គប្បីតុលាការពិចារណា។**

២-ជនត្រូវចោទមានទីលំនៅច្បាស់លាស់ ដែលអាចធានាថាជនត្រូវចោទមិនរត់គេចខ្លួនដែលបណ្តាលឱ្យមានការប៉ះពាល់ដល់នីតិវិធីរបស់តុលាការនាពេលបន្ទាប់ឡើយ។ ម្យ៉ាងទៀតការឃុំខ្លួនជនត្រូវចោទបន្តអាចបណ្តាល ឱ្យមានការប៉ះពាល់ដល់ជីវភាពគ្រួសារជនត្រូវចោទ។

៣-គ្រឿងញៀនដែលសមត្ថកិច្ចបានដកហូតមានទម្ងន់ **០.៤៩**(សូន្យក្បៀសសែសិបប្រាំបួន)ក្រាម ដែលមានចំនួនតិចតួចមិនមានព្យសនកម្មធ្ងន់ធ្ងរដល់សង្គម នឹងទណ្ឌកម្មដែលជនត្រូវចោទ បានទទួលរងក្នុងពន្ធនាគារជាបណ្តោះអាសន្នកន្លងមក។

៤- ជនត្រូវចោទគ្មានឥទ្ធិពល និងអំណាចណាមួយក្នុងការបំផ្លាញភស្តុតាងដែលបណ្តាលឱ្យមានការលំបាក នៃនីតិវិធីនៃការស៊ើបសួរទេ។ ម្យ៉ាងទៀតការស៊ើបសួរបានចប់សព្វគ្រប់ហើយ ដូចនេះ ការដោះលែងជនត្រូវចោទ ឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន គឺមិនប៉ះពាល់ដល់នីតិវិធីនៃការស៊ើបសួរឡើយ។

៥-តំណាងអយ្យការដែលជាម្ចាស់បណ្តឹងអាជ្ញា បានផ្តល់យោបល់យល់ព្រមអោយនៅក្រៅឃុំជាបណ្តោះ អាសន្នតាមការស្នើរសុំរបស់ជនត្រូវចោទផងដែរ។

**ហេតុដូច្នេះ** គប្បីតុលាការសម្រេចឱ្យជនត្រូវចោទមានសេរីភាពជាបណ្តោះអាសន្ន ដោយគ្រាន់តែអនុវត្តន៍ វិធានត្រួតពិនិត្យតាមផ្លូវតុលាការតាមមាត្រា**២១៧** និងមាត្រា**២១៨** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>ហេតុដូច្នេះសម្រេច</u>

អនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នលើជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិត្រពាំងរនៀម ឃុំពន្សាំង ស្រុកអង្គស្នួល ខេត្តកណ្តាល ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិកោះរងៀង សង្កាត់បន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" ប្រពន្ធឈ្មោះ "រស់" មានកូន **០១នាក់** នីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។

(ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១)

<u>**ជននេះត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យបទៈ**</u> **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិត្រពាំងរនាម សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ថ្ងៃ.......................ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...... ខែសីហា ឆ្នាំ២០២១

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

<u>**បានទទួលដំណឹង**</u>

រាជធានីភ្នំពេញ ថ្ងៃទី......ខែសីហា ឆ្នាំ២០២១

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី១៣**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រឡាបញ្ជី

បន្ទប់ "ង" ជានទី៤

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ស៊ើបសួរ "ង"

## លិខិតជូនដំណឹង

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខៈ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរលេខ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** សំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

**សូមជម្រាបជូន**

**តំណាងអយ្យការ** នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**បានដឹងថាៈ** ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែមករា ឆ្នាំ ដែលបានបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ យើងបានចាត់ការស៊ើបសួរចប់សព្វគ្រប់ហើយ។

ដូច្នេះយើងសម្រេចបិទការស៊ើបសួរលើសំណុំរឿងខាងលើនេះ ចាប់ពីពេលនេះតទៅ។

អាស្រ័យហេតុនេះ សូម **លោក/លោកស្រី** តំណាងអយ្យការ ជ្រាបជាព័ត៌មាន។

ថ្ងៃ.................. ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី....... ខែកក្កដា ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**

**យោបល់របស់តំណាងអយ្យការ**

..............................................................................................

...........................................................................................

ថ្ងៃ..........................ខែ............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី.........ខែកក្កដា ឆ្នាំ២០២១

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី១៤**

# ព្រះរាជាណាចក្រកម្ពុជា

ក្របញ្ជី

## ជាតិ សាសនា ព្រះមហាក្សត្រ

បន្ទប់ "ង" ជាន់ទី៥

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ស៊ើបសួរ "**ង**"

លេខ....................**ព្រ.ទ**

## <u>ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ</u>

យើង កេត សុជាតិ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** មាត្រា**២៤៦** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះeថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរលេខ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** សំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

**<u>ដែលទាក់ទងនឹងជនត្រូវចោទ:</u>**

**១**-ឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតស្រុកព្រះស្តេច ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួនមិនពិតប្រាកដ ប្រពន្ធឈ្មោះ កូនគ្មាន ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" នីតិជន។ (**ក្នុងឃុំ**)

ឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលកែប្រែទី១(**ម១**)តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**២**-ឈ្មោះ ភេទប្រុស អាយុ ៣៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតសង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនមិនពិតប្រាកដ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" នៅលីវ ជានីតិជន។ (**ក្នុងឃុំ**)

ឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលកែប្រែទី១(**ម១**)តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

ពីបទ លួច (ម៉ូតូ) ប្រព្រឹត្តនៅចំណុចផ្លូវព្រះស៊ីសុវត្ថិ ភូមិ៣ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២១ ជាបទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៦** នៃក្រមព្រហ្មទណ្ឌ។

**ត្បិត**សំណុំរឿងព្រហ្មទណ្ឌលេខ          ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ដែលបានធ្វើការស៊ើបសួរចប់សព្វគ្រប់តាមនីតិវិធីហើយ។

ដូច្នេះ **យើងសម្រេចបញ្ជូនសំណុំរឿងស៊ើបសួរនេះទៅព្រះរាជអាជ្ញា** ដើម្បីធ្វើសេចក្តីសន្និដ្ឋាន ឬផ្តល់យោបល់ទៅតាមនីតិវិធី។

ថ្ងៃ.........................ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

**<u>បានទទួលអនុវត្ត</u>**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......ខែកក្កដា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

**ចៅក្រមស៊ើបសួរ**

យោបល់របស់តំណាងអយ្យការ

យើង..............................................តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យខាងលើ

បានឃើញសំណុំរឿងស៊ើបសួរទាក់ទិននឹងឈ្មោះ

..............................................................................................................................................................
.............................

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ស្នើសុំ:

□...........................................................................................................................
.............................................................................................................

□ចោទប្រកាន់បន្ថែម តាមដីកាដែលមានភ្ជាប់ជាមួយ

□បន្តការស៊ើបសួរ

□បញ្ជូនសំណុំរឿងទៅសភាព្រហ្មទណ្ឌនៃសាលាដំបូង..................................................□លើកលែងចោទប្រកាន់

□រក្សាជនត្រូវចោទឱ្យនៅក្នុងឃុំបណ្តោះអាសន្ន

□ឱ្យដោះលែងជនត្រូវចោទនៅក្រៅឃុំ

ថ្ងៃ.......................ខែ..........ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី.......ខែកក្កដា ឆ្នាំ២០២១

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី១៥**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៤២៤

ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១

លេខ..........................អ.យ.ទ

## ដីកាសន្និដ្ឋានស្ថាពរ

យើង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ អ.យ.ទ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងស៊ើបសួរលេខ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ

-បានឃើញលិខិតជូនដំណឹង ឬជូនព័ត៌មានលេខ "ជ១" ព្រ.ទ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យលេខ "ជ១" ព្រ.ទ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានពិនិត្យឯកសារខាងលើយល់ឃើញថា ៖

១-នាមត្រកូល និងនាមខ្លួន ៖ ភេទប្រុស កើតឆ្នាំ១៩៩២ ជនជាតិខ្មែរ មុខរបរ ជាងឈើ

ទីកន្លែងកំណើត ៖ សង្កាត់គីឡូម៉ែត្រលេខ៩ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ

លំនៅបច្ចុប្បន្ន ៖ បន្ទប់ជួល សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

នៅលីវ ☑ ☐ ប្ដីឬប្រពន្ធឈ្មោះ

ឪពុកឈ្មោះ ៖ ម្ដាយឈ្មោះ ៖

ទោសពីមុន ៖ គ្មាន

| | |
|---|---|
| ២-នាមត្រកូល និងនាមខ្លួន | ៖ **ពីររររ** ភេទប្រុស ជនជាតិខ្មែរ |
| លំនៅបច្ចុប្បន្ន | ៖ ម្តុំភូមិតាព្រហ្ម សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ |
| កាន់លេខទូរស័ព្ទ | ៖ ០៩៦ ៦៦៦ ៩៥៤១ |

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខស្ថានីយ៍ប្រេងតេលា មុខវត្តកំសាន្ត សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

ឃើញថា[107]៖ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១៣ និង៤០នាទី នៅចំណុចមុខស្ថានីយ៍ប្រេងតេលា មុខវត្តកំសាន្ត សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កម្លាំងសមត្ថកិច្ចប្រឆាំងជំនួញគ្រឿងញៀន នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានធ្វើការចុះបង្រ្កាបបទល្មើសគ្រឿងញៀនជាក់ស្តែង ដោយប្រទះឃើញជនត្រូវចោទម្នាក់ឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៩២ ហើយបានឆែកឆេររកឃើញក្រោមពណ៌សថ្លាសង្ស័យជាសារធាតុញៀនចំនួន០២កញ្ចប់ទម្ងន់ ៣,៤៥ (បីក្បៀសសែសិបប្រាំ) ក្រាម សមត្ថកិច្ចបានដកហូតវត្ថុតាង និងនាំខ្លួនជនត្រូវចោទដើម្បីយកមកធ្វើការសាកសួរ។ ក្រោយពីធ្វើការសាកសួរទទួលបានលទ្ធផលថាគ្រឿងញៀនទាំងនោះជនត្រូវចោទឈ្មោះ បានទិញពីឈ្មោះ ភេទប្រុស កាន់ទូរស័ព្ទលេខ ក្នុងតម្លៃ ៥០០.០០០ (ហាសិបម៉ឺន) រៀល នៅម្តុំភូមិតាព្រហ្ម សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ ដើម្បីយកទៅលក់បន្តឱ្យម៉ូយនៅមុខស្ថានីយ៍ប្រេងតេលាមុខវត្តកំសាន្ត ហើយក៏ត្រូវសមត្ថកិច្ចប្រទះឃើញតែម្តង។ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនសង្ស័យ និងកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

ឃើញថា៖ **នៅដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ មានភស្តុតាងដូចតទៅ៖**

-ជនត្រូវចោទឈ្មោះ បានឆ្លើយថា ៖ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនម៉ាទឹកកក ប្រហែល០៥ខែកន្លងមកហើយតាមរយៈមិត្តភក្តិ។ គ្រឿងញៀនដែលខ្លួនប្រើប្រាស់នោះ គឺមិត្តភក្តិជាអ្នកទៅទិញ ហើយយកទៅប្រើប្រាស់នៅតាមព្រៃក្បែរផ្ទះ។ ក្នុងមួយថ្ងៃខ្លួនប្រើប្រាស់គ្រឿងញៀនចំនួនពីរដង។ ក្រោយមកខ្លួនបានស្គាល់បុរសម្នាក់ឈ្មោះ តាមរយៈមិត្តភក្តិ កាន់លេខទូរស័ព្ទ ដែលជាអ្នកលក់គ្រឿងញៀននៅម្តុំ

---

[107] រៀបរាប់សង្ខេបអង្គហេតុ និងរាល់ចំណាត់ការនៃនីតិវិធីតាមលំដាប់ (ឧទាហរណ៍ អង្គហេតុដែលបានកើតឡើង ចំណាត់ការរបស់មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ)

ភូមិតាព្រហ្ម សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ ខ្លួនក៏បានទិញគ្រឿងញៀនពីបុរសខាងលើបានបីដងកន្លងមកហើយដើម្បីយកទៅប្រើប្រាស់។ លុះដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ១១ ជាង មាននារីម្នាក់ទូរស័ព្ទមករកទិញគ្រឿងញៀនពីខ្លួនចំនួន០១ជីក្នុងតម្លៃ ៥០ម៉ឺនរៀល ខ្លួនក៏បានទៅយកគ្រឿងញៀនពីបុរសខាងលើនៅម្តុំភូមិតាព្រហ្ម សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ ដាក់ស្តែង លុះដល់ម៉ោងប្រហែល ១៣ជាង ថ្ងៃខែឆ្នាំដដែល នៅចំណុចមុខស្ថានីយ៍ប្រេងតេលា ក្លោងទ្វារវត្តកំសាន្ត សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ខណៈពេលដែលខ្លួនកំពុងរង់ចាំប្រគល់គ្រឿងញៀនទៅឱ្យម៉ូយខាងលើ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ត្រួតពិនិត្យឆែកឆេរឃើញវត្ថុតាងគ្រឿងញៀនចំនួនពីរកញ្ចប់នៅនឹងខ្លួនតែម្តង។

-កំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាងលេខ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បង្ហាញថាក្រាមពណ៌សថ្លាទម្ងន់ ៣,៤៥ ក្រាមចេញពណ៌លឿងទុំសង្ស័យមានតម្រុយជាគ្រឿងញៀន ជាប្រភេទមេតំហ្វេតាមីនដែលស្ថិតនៅក្នុងចំណាត់ថ្នាក់សារធាតុញៀនហាមឃាត់ក្នុងតារាង II នៃឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

ឃើញថា៖ **នៅដំណាក់កាលស៊ើបអង្កេតរបស់តំណាងអយ្យការ មានភស្តុតាងដូចខាងក្រោម**

យោងតាមរបាយការណ៍សំយោគលេខ ៈថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អយ្យការបានកសាងសំណុំរឿង និងបានបើកការស៊ើបសួរខាងលើតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ ដោយបានកត់យកចម្លើយដូចខាងក្រោម៖

-ជនត្រូវចោទឈ្មោះ បានឆ្លើយថា ៖ ខ្លួនពិតជាបានទិញថ្នាំញៀនពីឈ្មោះ ដើម្បីយកមកលក់បន្តឱ្យគេមែន។

ឃើញថា៖ **នៅដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ មានភស្តុតាងដូចខាងក្រោម**

-ជនត្រូវចោទឈ្មោះ បានរក្សាចម្លើយដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងនៅដំណាក់កាលអយ្យការ និងបានឆ្លើយថា៖ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១១ និង ០០នាទី មានមនុស្សស្រីម្នាក់មិនស្គាល់ឈ្មោះបានទូរស័ព្ទមកទិញថ្នាំញៀនពីខ្លួនទម្ងន់០១ជី តម្លៃ៥០ម៉ឺនរៀល ពេលនោះខ្លួនក៏បានប្រាប់មនុស្សស្រីម្នាក់នោះឱ្យទៅចាំយកគ្រឿងញៀននៅម្តុំមុខវត្តកំសាន្ត។ បន្ទាប់មកខ្លួនក៏បានទៅយកគ្រឿងញៀនពីឈ្មោះ ចំនួន០២កញ្ចប់ ទម្ងន់០១ជី តម្លៃ ៤៥ម៉ឺនរៀល យកមកលក់ចំណេញបាន ៥ ម៉ឺនរៀល។ ពេលទិញថ្នាំញៀនពីឈ្មោះ បានហើយ លុះដល់ម៉ោងប្រហែល ១២ថ្ងៃត្រង់ ខ្លួនក៏បានយកថ្នាំញៀនទៅឱ្យមនុស្សស្រីម្នាក់នោះនៅម្តុំមុខវត្តកំសាន្ត ពេលទៅខ្លួនកំពុងអង្គុយចាំម៉ូយទិញគ្រឿងញៀននៅចំណុចខាងលើ ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនរួមនិងវត្ថុតាងគ្រឿងញៀនតែម្តង។ ខ្លួនទើបធ្វើសកម្មភាពលក់គ្រឿងញៀនជាលើកទី១ទេ។ ខ្លួនទើបតែស្គាល់ឈ្មោះ មុនពេលកើតហេតុ២ទៅ៣ថ្ងៃនេះទេ ស្គាល់តាមរយៈមិត្ត

ភក្តិណែនាំឱ្យស្គាល់ ខ្លួនមិនស្គាល់ទីលំនៅវាទេ ស្គាល់តែទូរស័ព្ទ ០៩៦ ៦៦៦ ៩៥ ៤១។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល០៤ទៅ០៥ខែមកហើយ តែមិនដែលបានទិញគ្រឿងញៀនយកមកប្រើខ្លួនឯងនោះទេ គឺមិត្តភក្តិឈ្មោះ ហា ភេទប្រុស អាយុប្រហែល២៥ឆ្នាំ ជាអ្នកយកមកឱ្យប្រើ។ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបានថ្នាំញៀនចំនួន០២កញ្ចប់ទម្ងន់០១ជី។

-ជនត្រូវចោទឈ្មោះ ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្ន តាមដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ដ.ព.ស ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ និងដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ដ.ឃ.ដ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ ។

-ដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានប្រគល់សិទ្ធិឱ្យ **ឯកឧត្តមនាយកមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន** ដើម្បីបំពេញកិច្ចស៊ើបសួររកអត្តសញ្ញាណលើជនត្រូវចោទ ភេទប្រុស។

យល់ឃើញថា[108]

-អង្គហេតុខាងលើបានកើតឡើងស្ថិតនៅចំណុចមុខស្ថានីយ៍ប្រេងតេលា មុខវត្តកំសាន្ត សង្កាត់ព្រែកប្រាខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ហេតុដូច្នេះជាសមត្ថកិច្ចរបស់អយ្យការ និងសាលាដំបូងរាជធានីភ្នំពេញ តាម **មាត្រា ៣៩ មាត្រា ១២៣ និងមាត្រា ២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។**

-គិតចាប់ពីពេលដែលបទល្មើសកើតឡើងអាជ្ញាយុកាលនៃបទល្មើសមិនទាន់ផុតនៅឡើយទេ ដូច្នេះអយ្យការ និងសាលាដំបូងរាជធានីភ្នំពេញ នៅតែមានសមត្ថកិច្ចចាត់ការលើសំណុំរឿងនេះ តាមមាត្រា ១០ និងមាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-នៅគ្រប់ដំណាក់កាលនៃកិច្ចស៊ើបអង្កេត និងដំណាក់កាលស៊ើបសួរ ជនត្រូវចោទឈ្មោះ **សុខ ខា** ភេទប្រុស កើតឆ្នាំ១៩៩២ បានឆ្លើយសារភាពថា កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ខ្លួនពិតជាបានធ្វើសកម្មភាពលក់គ្រឿងញៀនឱ្យទៅម៉ូយ ដើម្បីទទួលបានប្រាក់ចំណេញពិតប្រាកដមែន ដោយគ្រឿងញៀននោះគឺទិញពីឈ្មោះ **ពីររយ** ភេទប្រុស ។

-អំពើរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៩២ ដែលបានទិញគ្រឿងញៀនយកមករំលែកលក់បន្ត ដើម្បីទទួលបានប្រាក់ចំណេញ ត្រូវបានច្បាប់បញ្ញត្តិជាអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិ**មាត្រា ៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

[108] សំអាងហេតុ សំអាងច្បាប់

-ជនត្រូវចោទឈ្មោះ ។ ភេទប្រុស កើតឆ្នាំ១៩៩២ ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ម្យ៉ាងទៀតជនត្រូវចោទពិតជាមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តអំពើល្មើស។

-មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៩២ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខស្ថានីយ៍ប្រេងតេលា មុខវត្តកំសាន្ត សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

-តាមដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ ង១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានប្រគល់សិទ្ធិឱ្យ **ឯកឧត្តមនាយកមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន** ដើម្បីបំពេញកិច្ចស៊ើបសួររកអត្តសញ្ញាណលើជនត្រូវចោទឈ្មោះ ភេទប្រុស ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខស្ថានីយ៍ប្រេងតេលា មុខវត្តកំសាន្ត សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ប៉ុន្តែរហូតមកដល់ពេលនេះ តុលាការមិនទាន់ទទួលបានលទ្ធផល នៃការឆ្លើយតបឱ្យស្រាវជ្រាវនេះនៅឡើយ។ ហេតុនេះ ជនដែលប្រព្រឹត្តបទល្មើសឈ្មោះ ភេទប្រុស នៅតែមិនស្គាល់ គួរគប្បីលើកលែងការចោទប្រកាន់ តាមបញ្ញត្តិមាត្រា២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧, មាត្រា៣៦៨ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ហេតុដូច្នេះសម្រេច

ប្តឹងសុំទៅចៅក្រមស៊ើបសួរ៖

១-លើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ ភេទប្រុស (**គ្មានអត្តសញ្ញាណគ្រប់គ្រាន់**) ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខស្ថានីយ៍ប្រេងតេលា មុខវត្តកំសាន្ត សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

២-ជនត្រូវចោទឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៩២ (**ក្នុងឃុំ**) ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខស្ថានីយ៍ប្រេងតេលា មុខវត្តកំសាន្ត សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** និងសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ទៅជំនុំជម្រះ ។

ថ្ងៃព្រហស្បតិ៍ ០១កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី១៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រឡាបញ្ជី

បន្ទប់ “ដ” ជាន់ទី៤

**សាលាដំបូងរាជធានីភ្នំពេញ**

**លេខសំណុំរឿង “ដ”**

## <u>លិខិតជូនដំណឹងស្តីពីការលើកលែងចោទប្រកាន់</u>

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** មាត្រា**២៤៧** កថាខណ្ឌ**៦** នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា**២៤៧** មាត្រា**៣៦៩** មាត្រា**៣៧៣** និងមាត្រា**៣៨២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** សំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**<u>ជូនដំណឹងមក</u>**

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទស្រី កើតឆ្នាំ១៩៩១ មានអាសយដ្ឋានបច្ចុប្បន្ន ភូមិព្រៃបន្លិច សង្កាត់អាចារលាក់ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ។**

**បានដឹងថា៖ ត្បិត**សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២ យើងបានចាត់ការស៊ើបសួរចប់សព្វគ្រប់រួចហើយ យើងបានសម្រេចលើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស អាយុ ៣១ឆ្នាំ តាមដីកាសម្រេចលើកលែងចោទប្រកាន់លេខ:............ “ដ” ដ.ដ ចុះថ្ងៃទី........ខែមេសា ឆ្នាំ២០២២ រួចហើយ។

អាស្រ័យហេតុនេះ សូមប្រាប់**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** ជាការជូនដំណឹង។

ថ្ងៃ...........................ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី.......ខែមេសា ឆ្នាំ២០២២

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១៧**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុបញ្ជី

បន្ទប់ "ង" ជាន់ទី៤

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ស៊ើបសួរ **"ង"**

លេខ........................**ង.ង**

# <u>ដីកាសម្រេចលើកលែងចោទប្រកាន់</u>

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

អមដោយលោក ជាក្រឡាបញ្ជី។

-**បានឃើញ** ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខៈ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-**បានឃើញ** មាត្រា**២៤៧ថ្មី** នៃច្បាប់ស្តីពីការវិសោធនកម្មមាត្រា**២៤៧** មាត្រា**៣៦៤** មាត្រា**៣៧២** និងមាត្រា**៣៨៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** សំណុំរឿងស៊ើបសួរលេខៈ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យលេខៈ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខៈ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

<u>សំអាងហេតុ</u>

**១**-ចៅក្រមស៊ើបសួរបានចេញដីកាចាត់ឱ្យស៊ើបសួរជំនួសលេខៈ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ ដោយប្រគល់សិទ្ធិជូន **លោកមេបញ្ជាការនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ** ចាត់កម្លាំងជំនាញចុះស្រាវ

ជ្រាវអត្តសញ្ញាណលើអញ្ញាតជន(មនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ២០ឆ្នាំជាង) ប៉ុន្តែតាមរបាយការណ៍លេខ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានបញ្ជាក់ថាៈ ការិយាល័យបានចាត់តាំងកម្លាំងជំនាញ ឱ្យចុះធ្វើការស្រាវជ្រាវរកអត្ត សញ្ញាណជនត្រូវចោទខាងលើ តែជនត្រូវចោទមិនមានអាសយដ្ឋានស្នាក់នៅពិតប្រាកដនោះទេ ធ្វើឱ្យកម្លាំងជំនាញ របស់កងរាជអាវុធហត្ថរាជធានីភ្នំពេញ ពិបាកក្នុងការស្រាវជ្រាវរក។ ក្រោយពីការខិតខំស្រាវជ្រាវរកសាវតាររបស់ជន ត្រូវចោទខាងលើកន្លងមក គឺរកមិនឃើញនោះទេ។ ដូច្នេះឃើញថា ពុំមានអត្តសញ្ញាណគ្រប់គ្រាន់ ដើម្បីចោទប្រកាន់ និងបញ្ជូនជនត្រូវចោទជាអញ្ញាតជននេះទៅជំនុំជម្រះឡើយ។ គប្បីលើកលែងចោទ ប្រកាន់លើជនត្រូវចោទអញ្ញាតជន(ជនដែលគ្មានអត្តសញ្ញាណគ្រប់គ្រាន់) ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៥ ក្រុម៥ ភូមិផ្សារតូច សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា**៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយពុំមានអត្តសញ្ញាណគ្រប់គ្រាន់ តាមប្បញត្តិមាត្រា**២៤៧ថ្មី** នៃច្បាប់ស្តីពីការវិសោធនកម្មមាត្រា**២៤៧** មាត្រា**៣៦៨** មាត្រា**៣៧២** និងមាត្រា**៣៨៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២**-តំណាងអយ្យការ ដែលជាម្ចាស់បណ្តឹងអាជ្ញាបានប្តឹងសុំឱ្យលើកលែងចោទប្រកាន់លើអញ្ញាតជនដោយគ្មាន អត្តសញ្ញាណគ្រប់គ្រាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០។

គប្បីចៅក្រមស៊ើបសួរ សម្រេចលើកលែងចោទប្រកាន់លើអញ្ញាតជន (ជនគ្មានអត្តសញ្ញាណគ្រប់គ្រាន់) តាម ប្បញ្ញត្តិមាត្រា **២៤៧ថ្មី** នៃច្បាប់ស្តីពីវិសោធនកម្មនីតិវិធីព្រហ្មទណ្ឌ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្ត នៅចំណុចលើផ្លូវជាតិលេខ៥ ក្រុម៥ ភូមិផ្សារតូច សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា**៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

<u>ហេតុដូច្នេះសម្រេច</u>

-លើកលែងចោទប្រកាន់លើជនត្រូវចោទដែលជាអញ្ញាតជន (ជនដែលគ្មានអត្តសញ្ញាណគ្រប់គ្រាន់)តាម ប្បញ្ញត្តិមាត្រា **២៤៧ថ្មី** នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចលើផ្លូវជាតិលេខ៥ ក្រុម៥ ភូមិផ្សារតូច សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា**៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ថ្ងៃ.......................ខែ...........ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី........ខែសីហា ឆ្នាំ២០២០

**<u>បានទទួលដំណឹង</u>**

រាជធានីភ្នំពេញ ថ្ងៃទី..........ខែសីហា ឆ្នាំ២០២០

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី១៨**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រឡាបញ្ជី

បន្ទប់ "ង" ជាន់ទី៤

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ស៊ើបសួរ "**ង**"

**<u>លិខិតជូនដំណឹងស្តីពីការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ</u>**

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** មាត្រា**២៤៧** កថាខណ្ឌ**៦** នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា**២៤៧** មាត្រា**៣៦៨** មាត្រា**៣៧៣** និងមាត្រា**៣៨២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** សំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**<u>ជូនដំណឹងមក</u>**

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទស្រី អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិព្រែកថ្មី១ សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។**

**បានដឹងថា៖** ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ យើងបានចាត់ការស៊ើបសួរចប់សព្វគ្រប់រួចហើយ យើងបានសម្រេចបញ្ជូនសំណុំរឿងព្រហ្មទណ្ឌនេះទៅជំនុំជម្រះ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៖................. "ង" ដ.ជ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ រួចហើយ។

អាស្រ័យហេតុនេះ សូមជូនដំណឹងមកដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជាការជូនដំណឹង។

ថ្ងៃចន្ទ ១០កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១៩**

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមពិភា

បន្ទប់ "ង" ជាន់ទី៤

**សាលាដំបូងរាជធានីភ្នំពេញ**

បន្ទប់ស៊ើបសួរ "ង"

## <u>ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ</u>

លេខ........................**ង.ង** យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

អមដោយលោក ជាក្រឡាបញ្ជី។

-**បានឃើញ** មាត្រា**២៤៧ថ្មី** នៃច្បាប់ស្ដីពីការវិសោធនកម្មមាត្រា**២៤៧** មាត្រា**៣៦៨** មាត្រា**៣៧២** និងមាត្រា**៣៨៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា**២៤៩** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** សំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យលេខ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

### <u>ក្រោយពីបានស៊ើបសួរមូលចប់សព្វគ្រប់លើជនជាប់ចោទ:</u>

**១**-ឈ្មោះ ភេទប្រុស អាយុ ១៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ សិស្ស សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ ៤ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅស្នាក់ភូមិតាងៅ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ "រស់" ម្ដាយឈ្មោះ "រស់" នៅលីវ ជាអនីតិជន។ (**ក្នុងឃុំ**)

ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅមណ្ឌលកែប្រែទី២(**ម២**)តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ □ង□ **ង.ឃ.ង** ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**២**-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ រត់ម៉ូតូកង់បី សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិត្របែកប្រហោង សង្កាត់តាសួស ខណ្ឌស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅស្នាក់ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" នៅលីវ ជាអនីតិជន។ (**ក្នុងឃុំ**)

ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលកែប្រែទី២(**ម២**)តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**៣**-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ សិស្ស សាសនាព្រះពុទ្ធ ទីកន្លែងកំណើតផ្ទះគ្មានលេខ ស្រុកស្អាង ខេត្តកណ្តាល ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅស្នាក់ផ្ទះគ្មានលេខ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ "ស្លាប់" ម្តាយឈ្មោះ "រស់" នៅលីវ ជាអនីតិជន។ (**ក្នុងឃុំ**)

ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលកែប្រែទី២(**ម២**)តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**៤**-ឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៥ សញ្ជាតិខ្មែរ មុខរបរ សិស្ស សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ខេត្តស្វាយរៀង ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅស្នាក់ផ្ទះគ្មានលេខ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" នៅលីវ ជាអនីតិជន។ (**ក្នុងឃុំ**)

ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលកែប្រែទី២(**ម២**)តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**៥**-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ សិស្ស សាសនាព្រះពុទ្ធ ទីកន្លែងកំណើតសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅស្នាក់ផ្ទះគ្មានលេខ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" នៅលីវ ជាអនីតិជន។ (**ក្នុងឃុំ**)

ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលកែប្រែទី២(**ម២**)តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**៦**-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ សិស្ស សាសនាព្រះពុទ្ធ ទីកន្លែងកំណើតសង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅស្នាក់ផ្ទះលេខ១៤C ភូមិបាក់ទូក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "ស្លាប់" នៅលីវ ជាអនីតិជន។ (**ក្នុងឃុំ**)

ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលកែប្រែទី២(**ម២**)តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

ត្រូវបានចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោស (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ជាបទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

<u>អង្គហេតុនៃរឿងមានដូចតទៅៈ</u>

កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង១៤ និង៣០នាទី ជនរងគ្រោះឈ្មោះ ភេទស្រី អាយុ ១៧ឆ្នាំ និងមិត្តភក្តិឈ្មោះ ជិះម៉ូតូ ០១គ្រឿងម៉ាក Honda Zoomer-X ពណ៌សលាយក្រហម ពាក់ផ្លាកលេខ ភ្នំពេញ 1DD-9673 ទៅផឹកកាហ្វេ ពេលមកដល់ចំណុចដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ស្រាប់តែមានជនត្រូវចោទចំនួន **០៦**នាក់ ដោយឈ្មោះ និងឈ្មោះ ជិះម៉ូតូមួយគ្រឿងម៉ាក Honda C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ ស្វាយរៀង 1Q-2353 ឈ្មោះ និងឈ្មោះ ជិះម៉ូតូម៉ាក Honda C125 ពាក់ផ្លាកលេខ ភ្នំពេញ 1IN-4203 និង ០២នាក់ទៀតឈ្មោះ និងឈ្មោះ ជិះម៉ូតូម៉ាក Honda C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1 IQ-1068 តាមជនរងគ្រោះពីក្រោយ ពេលនោះជនត្រូវចោទ **០៤**នាក់ បានជិះម៉ូតូ០២គ្រឿង ដើម្បីបិទគូថពីក្រោយ ដើម្បីកុំឱ្យសមត្ថកិច្ច និងអ្នកធ្វើដំណើរតាមផ្លូវជួយដេញតាមពីក្រោយ រួចជនត្រូវចោទឈ្មោះ និងជនត្រូវចោទឈ្មោះ ក៏បានជិះម៉ូតូទៅអែបខាងឆ្វេង រួចជនត្រូវចោទឈ្មោះ បានឆក់ខ្សែកប្លាកទីនចំនួន ០១ខ្សែ មានបន្តោង ដាំពេជ្រ ពណ៌ស ពីជនរងគ្រោះបានសម្រេច រួចនាំគ្នាជិះម៉ូតូគេចខ្លួនបាត់ តែជនរងគ្រោះបានជិះតាមពីក្រោយ ហើយស្រែកថា ***ចោរៗ*** ក៏មានកម្លាំងសមត្ថកិច្ចដែលកំពុងល្បាតជួយដេញតាមហូតទៅដល់ត្រង់ចំណុចដីឡូតិ៍មួយកន្លែងម៉ូតូរបស់ជនត្រូវចោទឈ្មោះ និងឈ្មោះ បានដួលហើយជ្រុះបាត់ខ្សែកនោះ ពេលនោះសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនជនត្រូវចោទទាំង ០៦នាក់ខាងលើតែម្តង និងបានកសាងសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

<u>សំអាងហេតុ</u>

ក្រោយពីបានពិនិត្យនីតិវិធី និងឯកសារផ្សេងៗ នៃសំណុំរឿងចប់សព្វគ្រប់ ឃើញថាៈ

**១**-តាមរបាយការណ៍សំយោគលេខ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងតាមដីកាសន្និដ្ឋានស្ថាពរលេខ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឃើញថា កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ចំណុចដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ពិតជាមានករណី **លួចមានស្ថានទម្ងន់ទោស** ( **ឆក់ខ្សែក** ) ប្រាកដមែន។

**២**-តាមចម្លើយជនជាប់ចោទ និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង អាចឱ្យតុលាការកំណត់បានថា ជនត្រូចចោទឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ និងឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថាន់ទម្ងន់ទោស** ( **ឆក់ខ្សែក** ) ប្រាកដមែន។

**៣**-ជនត្រូវចោទឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ និងឈ្មោះ បានបង្ហាញឱ្យឃើញនូវចេតនាទុច្ចរិត ដើម្បីឆក់យកទ្រព្យសម្បត្តិរបស់អ្នកដទៃដែលបង្កឱ្យមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិឯកជនរបស់អ្នកដទៃ និងរបៀបរៀបរយសង្គម កើតចេញពីអំពើដោយផ្ទាល់របស់ជនត្រូវចោទ ហើយអំពើនេះត្រូវបានកំណត់ថាជាអំពើ **លួចមានស្ថានទម្ងន់ទោស** ( **ឆក់ខ្សែក** ) តាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា។

**៤**-អំពើរបស់ជនត្រូវចោទឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ និងឈ្មោះ ធ្វើឡើងដោយមានស្មារតីទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្ត ដោយជន

ជាប់ចោទខាងលើនេះជានីតិជន មានសមត្ថភាព មាននីតិសម្បទាបរិបូរណ៍ ពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានបញ្ហាវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសឡើយ។

**៥**-តាមដីកាសន្និដ្ឋានស្ថាពរលេខ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្ដឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ និងឈ្មោះ ទៅជំនុំជម្រះពីបទ **លួចមានស្ថានទម្ងន់ទោស** (**ឆក់ខ្សែក**) ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ជាបទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

**៦**-មានភស្តុតាងគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកលើជនត្រូវចោទឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ ឈ្មោះ និងឈ្មោះ ពីបទ **លួចមានស្ថានទម្ងន់ទោស** (**ឆក់ខ្សែក**) ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ជាបទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

<u>ហេតុដូច្នេះសម្រេច</u>

**១**-បញ្ជូនជនត្រូវចោទ៖

**ក**-ឈ្មោះ ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ

**ខ**-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ

**គ**-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ

**ឃ**-ឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៥ ជនជាតិខ្មែរ

**ង**-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ

**ច**-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដែលមានអត្តសញ្ញាណដូចខាងលើនេះ

ទៅជំនុំជម្រះពីបទ **លួចមានស្ថានទម្ងន់ទោស** (**ឆក់ខ្សែក**) ប្រព្រឹត្តនៅចំណុចដីឡូតិ៍គ្មានលេខ ផ្លូវបេតុង ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ជាបទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

**២**-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ **១៣៤៤** ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ ព្រមទាំងបញ្ជីរាយនាមជនដែលទាក់ទិននៅក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញ ដើម្បីកំណត់កាលបរិច្ឆេទជំនុំជម្រះ។

**៣**-**រក្សាទុក**ជនត្រូវចោទ៖

**ក**-ឈ្មោះ ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ដែលត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**ខ**-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដែលត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ □**ដ**□ **ដ.ឃ.ដ** ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**គ**-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដែលត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**ឃ**-ឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៥ ជនជាតិខ្មែរ ដែលត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

ង-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដែលត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

ច-ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដែលត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**បានទទួលដំណឹង**

ថ្ងៃចន្ទ កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក

រាជធានីភ្នំពេញ ថ្ងៃទី.....ខែកក្កដា ឆ្នាំ២០២១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែកក្កដា ឆ្នាំ

**តំណាងអយ្យការ** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**